# កម្ពុជា

KAMBUJA

លេខ២៣៨ ខែ កញ្ញា ២០២២



យោងរបាយការណ៍មន្ទីរទេសចរណ៍ខេត្តសៀមរាប បានឱ្យដឹងថា ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលដើរកម្សាន្តនៅតាមរមណីយដ្ឋាននានា ក្នុងខេត្តសៀមរាប នាថ្ងៃបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរឆ្នាំ២០២២ មានចំនួន ១៤៣,៤៧០នាក់។

រូបថត៖ មន្ទីរទេសចរណ៍ខេត្តសៀមរាប

កម្ពុជា

លេខ ២៣៥
ខែកញ្ញា ២០២២

KAMBUJA

# មាតិកា


- មជ្ឈភាពអាស៊ាន គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់យន្តការនានាក្នុងគោលដៅរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍនៅក្នុងតំបន់ និងពិភពលោក ........ ៣
- សម្តេចតេជោ ហ៊ុន សែន អញ្ជើញបើកការដ្ឋានសាងសង់ស្ពានអាកាសក្នុងរាជធានីភ្នំពេញចំនួន០២ ដែលមានតម្លៃសរុបជាង ៤៦លានដុល្លារអាមេរិក ........ ៨
- ពិធីបុណ្យសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ញឹម តេង មាតាក្មេកលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ........ ១២
- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ចូលរួមពិធីរាប់បាត្រ បង្សុកូល ឧទ្ទិសកុសលផលបុណ្យដល់ព្រលឹងអ្នកស្លាប់នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ........ ១៦
- សាខាគយ និងរដ្ឋាករ ខេត្តស្វាយរៀងប្រមូលចំណូលបានចំនួន ១៨៨,៥៦ ប៊ីលានរៀលនៅឆមាសទី១ ឆ្នាំ២០២២ ........ ១៩
- កិច្ចប្រជុំក្រុមប្រឹក្សាភិបាលស្តីពីទឹក នៃសភាអាស៊ីលើកទី ៥ គ្រោងរៀបចំប្រជុំនៅឆ្នាំ២០២៣នៅកម្ពុជា ........ ២២
- គុយបា កោតសរសើរកម្ពុជាអំពីភាពជោគជ័យក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ........ ២៥
- រដ្ឋមន្ត្រីក្រសួងការងារ៖ របបសន្តិសុខសង្គមផ្នែកប្រាក់សោធន ជារបបសន្តិសុខសង្គមថ្មីដ៏ល្អប្រសើរមួយដើម្បីរក្សាផលប្រយោជន៍ជូនកម្មករ-និយោជិត ........ ២៧
- ឯកឧត្តម ហង្ស សាមឿន អញ្ជើញចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ី-ប៉ាស៊ីហ្វិកស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០២២ នៅប្រទេសអូស្ត្រាលី ........ ៣៣
- សម្តេចតេជោ ហ៊ុន សែន រីករាយជាមួយពលរដ្ឋក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ស្របពេលដែលកម្ពុជាទទួលបានភ្ញៀវទេសចរសរុបជាង១លាន២សែននាក់ នាពិធីភ្ជុំបិណ្ឌ ........ ៣៦
- ស្ថាបនិកក្រុមហ៊ុន ខ្មែរ យ៉ូរីយូ ជាជនជាតិជប៉ុន ជួយប្រជាកសិករខ្មែរនៅខេត្តបាត់ដំបងឱ្យមានមុខរបរ និងប្រាក់ចំណូល ........ ៣៩
- ពិធីបុណ្យកាន់បិណ្ឌនឹងភ្ជុំបិណ្ឌ ឆ្នាំ២០២២ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោកជំទាវទទួលកាន់វេនបិណ្ឌ ចំនួន ៣វត្ត ក្នុងរាជធានីភ្នំពេញ ........ ៤២
- បញ្ជីរាយនាមថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងព័ត៌មាន ចូលរួមចាប់មគ្គផលក្នុងពិធីកាន់បិណ្ឌវេនទី១ និងវេនទី៧ ........ ៤៨
- ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ប្រកាសជួយសាងសង់ទីលានបាល់ទាត់ជូនវិទ្យាល័យសម្តេចតេជោ

ហ៊ុន សែន ៣រាំង ............................................................................................................. ៥៤
❖ ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា សន្យាជួយជួសជុលផ្លូវលំមួយខ្សែក្នុងឃុំពពេល និងជំរុញឱ្យមានការការពារសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ ........................................................................................ ៥៧
❖ ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញចូលរួមមហាសន្និបាតនៃសមាគមអគ្គលេខាធិការសភាប្រើប្រាស់ភាសាបារាំងនៅទីក្រុងរ៉ាបាតប្រទេសម៉ារ៉ុក .................................................................................................. ៦០
❖ លោកជំទាវ ខៀវទេព រង្សីកាញារីទ្ធ និងប្រតិភូអញ្ជើញកាន់បិណ្ឌវេនទី៥ នៅវត្តដំណាក់ព្រីង និងវត្តមហាលាភក្នុងឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម ................................................................ ៦៣
❖ កំណើននៃប្រភេទផ្លែឈើស្រស់កម្ពុជានាំចេញទៅចិន រំលេចចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ....................................................................................................................... ៦៨
❖ រយៈពេល ៥ឆ្នាំ ក្រសួងព័ត៌មានរកឃើញព័ត៌មានក្លែងក្លាយជាង ៤ពាន់មាតិកា ប៉ុន្តែមិនបានបញ្ជូនសំណុំរឿងទៅតុលាការនោះទេ ............................................................................................................ ៧១
❖ ក្រសួងធនធានទឹក និងឧតុនិយមបង្ហាញសមិទ្ធផលរយៈពេល ៥ឆ្នាំ ដែលសម្រេចបាន ............................... ៧៣
❖ កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ចូលរួមឧបត្ថម្ភនិងដំឡើងបង្គោលនិងអំពូលសូឡាតាមបណ្តោយផ្លូវស្របដងទន្លេមេគង្គ នៅតំបន់រមណីយដ្ឋានព្រែកកាំពី អន្លង់ផ្សោតកាំពី និងតំបន់ជុំវិញ ......... ៧៦
❖ GBV Safe App ជាកម្មវិធីទូរស័ព្ទវៃឆ្លាតនឹងផ្តល់ភាពងាយស្រួលក្នុងការផ្តល់ព័ត៌មានអំពីករណីរំលោភបំពានសិទ្ធិស្ត្រីនិងកុមារដែលងាយរងគ្រោះ .................................................................................... ៨០
❖ យុទ្ធនាការអន្ទាក់សូន្យដើម្បីអភិរក្សសត្វព្រៃឱ្យនៅគង់វង្សក្នុងព្រៃធម្មជាតិកម្ពុជា ........................................... ៨២
❖ កីឡាការិនីជម្រើសជាតិហែលទឹកកម្ពុជាដណ្តើមបានកិត្តិយស និងកិត្យានុភាពជូនជាតិតាមរយៈការឈ្នះមេដៃមាស ០៣គ្រឿង និងសម្រាប់០១គ្រឿង .............................................................................. ៨៧
❖ ការស្រាវជ្រាវរកឃើញវត្តមានសត្វក្ងាន់ក្នុងខេត្តក្រចេះដែលនឹងធ្វើឱ្យកិត្តិនាមរបស់កម្ពុជាលេចត្រដែតលើឆាកអន្តរជាតិ ផ្នែកការងារអភិរក្សជីវៈចម្រុះ ........................................................................................ ៩១
❖ ឯកឧត្តម លី វ៉ាន់ហុង ផ្ញើសារលិខិតជូនពរនិងអបអរសារ ឯកឧត្តម ខៀវ កាញារីទ្ធ ក្នុងឱកាសខួបកំណើត ....... ៩៥
❖ អនុក្រឹត្យតែងតាំង លោក ជ្រឹង ឆេងលឹម ជាប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងព័ត៌មាន ............................................................................................................ ៩៦

ចេញផ្សាយដោយ
អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP
បោះពុម្ពដោយ រោងពុម្ពក្រសួងព័ត៌មាន
ទូរស័ព្ទ : ០១២ ៨២៨ ៤០៥
E-mail : Sath.Sophal@gmail.com




# មជ្ឈភាពអាស៊ាន គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់យន្តការនានា ក្នុងគោលដៅរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍ នៅក្នុងតំបន់ និងពិភពលោក

*អត្ថបទ ៖ យូ សំបូរ, រូបថត៖ ហ៊ិន យុទ្ធគុណ*

*« ខ្ញុំគាំទ្រ និងជឿជាក់លើគោលការណ៍គ្រឹះនានាដែលមានចែងក្នុងធម្មនុញ្ញរបស់អាស៊ាន ជាពិសេសការឯកភាពជាឯកច្ឆន្ទ និងមជ្ឈភាពអាស៊ាន គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់យន្តការនានា ដែលដឹកនាំដោយអាស៊ានក្នុងគោលដៅរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍនៅក្នុងតំបន់ និងពិភពលោក » ។*

នេះជាប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ និងកិច្ចប្រជុំពាក់ព័ន្ធថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ ដែលរៀបចំឡើងដោយក្រសួងពាណិជ្ជកម្មកម្ពុជា ប្រារព្ធធ្វើនៅសណ្ឋាគារសុខា ខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចតេជោបានគូសបញ្ជាក់ថា កម្ពុជាពិតជាមានកិត្តិយសក្នុងនាមជាប្រធានអាស៊ានឆ្លាស់វេនឆ្នាំ២០២២ និងជាម្ចាស់ផ្ទះទទួលរៀបចំកិច្ចប្រជុំសំខាន់ៗនានា ក្រោមសសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន។ កម្ពុជាបន្តគាំទ្រការធ្វើសមាហរណកម្មក្នុងអាស៊ានបន្ថែមទៀត និងធ្វើសមាហរណកម្មជាមួយប្រទេសជាដៃគូសេដ្ឋកិច្ចតំបន់ និងសកលលោកតាមរយៈកិច្ចសហការ និងការចូលរួមវិភាគទានជាមួយបណ្តារដ្ឋជាសមាជិកអាស៊ានទាំង៩ទៀត ក្នុងការកសាងសហគមន៍




# មជ្ឈភាពអាស៊ាន គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់យន្តការនានា ក្នុងគោលដៅរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍ នៅក្នុងតំបន់ និងពិភពលោក

*អត្ថបទ ៖ យូ សំបូរ, រូបថត៖ ហ៊ុន យុទ្ធគុណ*

*« ខ្ញុំគាំទ្រ និងជឿជាក់លើគោលការណ៍គ្រឹះនានាដែលមានចែងក្នុងធម្មនុញ្ញរបស់អាស៊ាន ជាពិសេសការឯកភាពជាឯកច្ឆន្ទ និងមជ្ឈភាពអាស៊ាន គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់យន្តការនានា ដែលដឹកនាំដោយអាស៊ានក្នុងគោលដៅរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍនៅក្នុងតំបន់ និងពិភពលោក » ។*

នេះជាប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ និងកិច្ចប្រជុំពាក់ព័ន្ធថ្ងៃទី១៤ខែកញ្ញា ឆ្នាំ២០២២ ដែលរៀបចំឡើងដោយក្រសួងពាណិជ្ជកម្មកម្ពុជា ប្រារព្ធធ្វើនៅសណ្ឋាគារសុខា ខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចតេជោបានគូសបញ្ជាក់ថា កម្ពុជាពិតជាមានកិត្តិយសក្នុងនាមជាប្រធានអាស៊ានឆ្លាស់វេនឆ្នាំ២០២២ និងជាម្ចាស់ផ្ទះទទួលរៀបចំកិច្ចប្រជុំសំខាន់ៗនានា ក្រោមសសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន។ កម្ពុជាបន្តគាំទ្រការធ្វើសមាហរណកម្មក្នុង អាស៊ាន បន្ថែមទៀត និងធ្វើសមាហរណកម្មជាមួយប្រទេសជាដៃគូសេដ្ឋកិច្ចតំបន់ និងសកលលោកតាមរយៈកិច្ចសហការ និងការចូលរួមវិភាគទានជាមួយបណ្តារដ្ឋជាសមាជិកអាស៊ានទាំង៩ទៀត ក្នុងការកសាងសហគមន៍



សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅខេត្តសៀមរាប

ដោយសារការផ្លាស់ប្តូរឥតឈប់ឈរ នៃនិម្មាបនកម្មសេដ្ឋកិច្ច-ពាណិជ្ជកម្មតំបន់ និងសកល ដែលបណ្តាលមកពីបញ្ហាស្មុគស្មាញប្រទាក់ក្រឡាគ្នាជាច្រើនដូចជា៖ ការបន្តអូសបន្លាយនៃជំងឺកូវីដ-១៩ បញ្ហាសង្គ្រាមនៅអ៊ុយក្រែន ការកើនឡើងនៃការបែងចែកប្លុក និងប្រព័ន្ធពហុប៉ូល សង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យា និងការប្រែប្រួលអាកាសធាតុជាដើម។ កត្តាទាំងនេះបានធ្វើឱ្យអត្រាអតិផរណាកើនឡើងយ៉ាងគំហុក បន្ទច់បង្អាក់ខ្សែច្រវាក់តម្លៃ និងផលិតភាពសកល និងជាពិសេសធ្វើឱ្យសន្ទុះនៃការងើបឡើងវិញនៃសេដ្ឋកិច្ចសកល និងតំបន់មានការថមថយគួរឱ្យកត់សម្គាល់។ ក្នុងបរិបទនេះកម្ពុជា ក្នុងនាមជាប្រធានអាស៊ានឆ្នាំ ២០២២ ជាមួយមូលបទ«អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា» បានផ្តោតអាទិភាពលើការធានាឱ្យបាននូវប្រសិទ្ធភាពរបស់អាស៊ានក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈម និងហានិភ័យទាំងនេះ ជាពិសេសពន្លឿនការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញប្រកបដោយចីរភាព បរិយាប័ន្ន និងភាពធន់ ។ក្នុងស្មារតីនេះកម្ពុជាបានកំណត់គោលដៅយុទ្ធសាស្ត្រចំនួន៤នៅក្រោមសសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ានរួមមាន៖ ១-ការពង្រឹងការតភ្ជាប់ឌីជីថល វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ២-ការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ ដើម្បីភាពប្រកួតប្រជែងរបស់អាស៊ាន។ ៣-ការជំរុញសមាហរណកម្ម បរិយាបន្ន ភាពធន់ និងភាពប្រកួតប្រជែងអាស៊ានឱ្យខ្លាំងជាងមុន និង ៤-អាស៊ានជាសកលសម្រាប់ភាពរីកចម្រើន និងការអភិវឌ្ឍ។

ក្នុងពេលដែលពិភពលោកកំពុងប្រឈមនឹងឧបសគ្គជាច្រើន ការអភិវឌ្ឍ អាស៊ានត្រូវតែផ្តល់សារៈសំខាន់កាន់តែខ្លាំងថែមទៀតដល់ការក្សាឱ្យបាននូវប្រព័ន្ធពាណិជ្ជកម្មឈរលើ



គណៈប្រតិភូភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អញ្ជើញចូលរួម

វិធានច្បាប់ គោលការណ៍ សកលភាវូបនីយកម្ម យន្តការពហុភាគីនិយម និងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងវិនិយោគក្នុងតំបន់ ការប្រឆាំងនឹងការគាំពារនិយម ការលើកកម្ពស់ភាពធន់រឹងមាំនៃច្រវាក់ផ្គត់ផ្គង់តំបន់ និងសកល ការតភ្ជាប់និងភ័ស្តុភារកម្ម ការកសាងសេដ្ឋកិច្ចឌីជីថល កិច្ចការពារបរិស្ថាន ការប្រើប្រាស់ថាមពលស្អាត និងការអភិវឌ្ឍប្រកបដោយ





ប្រតិភូរាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អញ្ជើញចូលរួម

ចីរភាព និងការរក្សាសន្តិសុខស្បៀង ទន្ទឹមគ្នានឹងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងកូវីដ-១៩ និងកិច្ចខិតខំប្រឹងប្រែងឱ្យបានខ្លាំងជាងមុនក្នុងការស្តារឡើងវិញសេដ្ឋកិច្ចតំបន់ និងសកលលោកដែលមានភាពធន់ និងចីរភាព។ បន្ថែមលើនេះចក្ខុវិស័យអាស៊ានក្រោយឆ្នាំ២០២៥ដែលអាស៊ានកំពុងរៀបចំនេះ គួរផ្តោតការគិតគូជាយុទ្ធសាស្ត្រលើបញ្ហាថ្មីៗរួមមាន ៖ ការវិវត្តរីកចម្រើននៃវិស័យសេដ្ឋកិច្ចឌីជីថល និងការកាត់បន្ថយគម្លាតឌីជីថលក្នុងតំបន់ ការពង្រឹងភាពធន់អាស៊ានទៅនឹងគ្រោះមហន្តរាយនិងជំងឺឆ្លងរាតត្បាតនានា ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង ការការពារពលករចំណាកស្រុក ការអភិវឌ្ឍពលកម្មជំនាញ និងការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមជាដើម។ អាស៊ានគួរបន្តបង្កើនការភ្ជាប់ទំនាក់ទំនងជាមួយដៃគូខាងក្រៅដោយឈរលើគោលការណ៍សមភាព និងការផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកតាមរយៈការទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់អាស៊ាន និងអាស៊ានបូក១ ដែលមានស្រាប់ ដោយការដំឡើងកម្រិតបន្ថែមជាពិសេសការអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ( អាសិប) ដែលបានចូលជាធរមានកាលពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ កន្លងទៅនេះ។ ទាក់ទងនឹងការទាញយកអត្ថប្រយោជន៍ជាអតិបរិមា ពីកិច្ចព្រមព្រៀងអាសិប ប្រទេសជាសមាជិកគួរខិតខំអនុវត្តនូវការសន្យានានា ហើយបន្តចរចាបើកច្រកទីផ្សារសំដៅទាក់ទាញការចូលរួមពីបណ្តាប្រទេសដែលមានសេដ្ឋកិច្ច ធំៗដទៃទៀតក្នុងកិច្ចព្រមព្រៀងនេះ។ កិច្ចព្រមព្រៀងអាសិបត្រូវតែមានលេខាធិការដ្ឋានរបស់ខ្លួនមួយដែលឯករាជ្យ និងម្ចាស់ការ ហើយដើរតួនាទីសំខាន់ក្នុងការងារសម្របសម្រួលជំរុញ និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងនេះ។ កម្ពុជានៅតែមានចំណាប់អារម្មណ៍ និងផ្តល់គ្រប់លទ្ធភាពនិងសម្បទានក្នុងការទទួលយកលេខាធិការដ្ឋាននេះ។

បញ្ហាសំខាន់មួយទៀត ដែលអាស៊ានត្រូវគិតគូបន្ថែមទៀតគឺការឆ្លើយតបឱ្យបានទាន់ពេលវេលាទៅនឹងនិន្នាការថ្មីៗ នៅក្នុងនិម្មាបនកម្មពាណិជ្ជកម្មសកល។ ពិតណាស់ថា បញ្ហាថ្មីៗ





ការសម្តែងសិល្បៈជូនប្រតិភូ ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទស្សនា
ក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី ៥៤

រួមមានវិបត្តិប្រេងឡើងថ្លៃ អត្រាអតិផរណាខ្ពស់ បរិស្ថាន បម្រែបម្រួលអាកាសធាតុ ជំងឺឆ្លងរាតត្បាតជាដើម កំពុងជំរុញឱ្យមាននិន្នាការឆ្ពោះទៅរកការធ្វើ ពាណិជ្ជកម្មក្នុង គន្លងថ្មីក្នុងតំបន់ និងក្នុងពិភពលោក ក៏ប៉ុន្តែមិនមានន័យថាបញ្ហាទាំងនេះនឹងតម្រូវឱ្យបណ្តាប្រទេសនៅក្នុងពិភពលោកប្រើប្រាស់ជាឧបករណ៍គាំពារនិយម បង្កើតជារបាំងពាណិជ្ជកម្ម និងបន្ទច់បង្អាក់ដល់ខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសកលលោក ឬខិតខំកសាងច្បាប់ និងកិច្ចព្រមព្រៀងអន្តរជាតិ ដែលបម្រើឱ្យតែប្រទេសខ្លួន ឬក្រុមប្រទេសមួយក្តាប់តូច ដែលជាបក្សពួកខ្លួននោះឡើយ។ ក្នុងន័យនេះអាស៊ានគួររួមគ្នាជាធ្លុងមួយ ដើម្បីសម្របសម្រួល និងជំរុញឱ្យមានការរៀបចំក្របខ័ណ្ឌជាសកលសម្រាប់ពាណិជ្ជកម្មអន្តរជាតិ ដែលបម្រើឱ្យផលប្រយោជន៍គ្រប់ប្រទេសទាំងអស់ប្រកបដោយតម្លាភាព និងគ្មានការរើសអើង។ នាពេលបច្ចុប្បន្ននេះ ពិភពលោក និងអាស៊ានកំពុងប្រឈមនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០៣០ អាស៊ានគួរពិចារណាលើគំនិតផ្តួចផ្តើមបង្កើតក្របខ័ណ្ឌកិច្ចព្រមព្រៀងបៃតងអាស៊ាន (ASEAN Green Deal) ដែលបានលើកឡើងក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥និងកិច្ចប្រជុំពាក់ព័ន្ធ។ កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតឱ្យតំបន់របស់យើងអាចប្រែក្លាយបន្តិចម្តងៗឆ្ពោះទៅកាន់អនាគតបៃតងដែលមានចីរភាព ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ភាពធន់រឹងមាំ និងភាពប្រកួតប្រជែងក្នុងផ្នែកសេដ្ឋកិច្ច។ សម្តេចតេជោបានបន្តទៀតថា អាស៊ាននឹងបន្តធ្វើដំណើរទៅមុខប្រកបដោយភាពរឹងមាំ សាមគ្គីភាព និងមិត្តភាព ដើម្បីជម្នះរាល់បញ្ហាប្រឈមនានា និងការកសាងសហគមន៍អាស៊ានប្រកបដោយបរិយាប័ន្នយ៉ាងពិតប្រាកដស្របតាមស្មារតីស្នូលរបស់អាស៊ាន គឺ«ចក្ខុវិស័យមួយ អត្តសញ្ញាណមួយ និងសហគមន៍តែមួយ» និងឈរលើជំហរនៃការឯកភាពគ្នាសម្រាប់កិច្ចសហប្រតិបត្តិការ និងដើម្បីផលប្រយោជន៍ទៅវិញទៅមក ជាពិសេសប្រយោជន៍រួមរបស់ប្រជាជន និងតំបន់របស់យើង ៕

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញបើកការដ្ឋានសាងសង់ស្ពានអាកាស ក្នុងរាជធានីភ្នំពេញចំនួន០២ ដែលមានតម្លៃសរុបជាង ៤៦លានដុល្លារអាមេរិក

អត្ថបទ៖ យូ សំបូរ , រូបថត៖ AKP, Press OCM




សម្តេចតេជោ ហ៊ុន សែន អញ្ជើញបើកការដ្ឋានសាងសង់ស្ពានអាកាស ក្នុងរាជធានីភ្នំពេញ

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីបើកការដ្ឋានសាងសង់ស្ពានអាកាស ក្នុងរាជធានីភ្នំពេញចំនួន០២ បន្ថែមទៀត ដែលមានតម្លៃសរុបជាង ៤៦លានដុល្លារអាមេរិក កាលពីថ្ងៃពុធ៥កើត ខែភទ្របទ ឆ្នាំខាលចត្វាស័កព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២។

ស្ពានអាកាស ដែលសាងសង់បន្ថែម ក្នុងរាជធានីភ្នំពេញនេះគឺទី១ ស្ថិតនៅចំណុចប្រសព្វមហាវិថីសម្តេចតេជោ **ហ៊ុន សែន** មហាវិថី **ព្រះមុនីវង្ស** ជាមួយវិថីកងយោធពល



ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលអញ្ជើញចូលរួម



ប្រជាពលរដ្ឋ មន្ត្រីរាជការ អញ្ជើញចូលរួម



សម្តេចតេជោ ហ៊ុន សែន អញ្ជើញបើកការដ្ឋានសាងសង់ស្ពានអាកាស ក្នុងរាជធានីភ្នំពេញ


ឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ

ខេមរភូមិន្ទ (ផ្លូវលេខ២៧១) ក្នុងទឹកដីខណ្ឌចំការមន និងខណ្ឌមានជ័យ។ ទី២ ស្ថិតនៅចំណុចប្រសព្វមហាវិថីសហព័ន្ធរុស្ស៊ីជាមួយមហាវិថីសម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតីស្រឹង្គារ **គង់ សំអុល** (ផ្លូវលេខ២០០៤) ក្នុងខណ្ឌពោធិ៍សែនជ័យ។ ស្ពានអាកាសទាំងពីរនេះ សាងសង់ដោយក្រុមហ៊ុន វិនិយោគទុនអាណិកជនកម្ពុជា (OCIC) ដោយចំណាយថវិកាសរុប ៤៦ ៧៧៥ ០០០ដុល្លារអាមេរិក ក្នុងនោះស្ពានអាកាសចំណុចប្រសព្វមហាវិថីសម្តេចតេជោ **ហ៊ុន សែន** មហាវិថី **ព្រះមុនីវង្ស** ជាមួយវិថីកងយោធពលខេមរភូមិន្ទ (ផ្លូវលេខ២៧១) ចំណាយថវិកា ៣៦ ៧៧៥ ០០០ដុល្លារ និងចំណាយពេលសាងសង់ ៣៦ខែ ដោយឡែកស្ពានអាកាសចំណុចប្រសព្វមហាវិថីសហព័ន្ធរុស្ស៊ីជាមួយមហា វិថី សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតីស្រឹង្គារ **គង់ សំអុល** ចំណាយថវិកា ១០ ០០០ ០០០ ដុល្លារអាមេរិក ចំណាយពេលសាងសង់១៦ខែ។ សម្តេចតេជោបានសម្រេចដាក់ឈ្មោះឱ្យស្ពានអាកាសចំណុចប្រសព្វមហាវិថី **ព្រះមុនីវង្ស** មហាវិថីសម្តេចតេជោ និងវិថីកងយោធពលខេមរភូមិន្ទថា «**ស្ពានអាកាសព្រះមុនីវង្ស**» រីឯស្ពានអាកាសចំណុចប្រសព្វផ្លូវ២០០៤ និងមហាវិថីសហព័ន្ធរុស្ស៊ីបានដាក់ឈ្មោះថា «**ស្ពានអាកាសគង់សំអុល**»។

សម្តេចតេជោ **ហ៊ុន សែន** បានបង្ហាញនូវក្តីរីករាយអញ្ជើញបើកការដ្ឋានសាងសង់ស្ពានអាកាសចំនួនពីរបន្ថែមទៀតក្នុងទីក្រុងភ្នំពេញដោយមានប្រសាសន៍រំលឹកថា កាលពីទសវត្សរ៍៨០ និង៩០ តម្រូវការរបស់ប្រជាពលរដ្ឋខុសឆ្ងាយពីពេលបច្ចុប្បន្ន ដែលពីមុនតម្រូវការខ្ពស់បំផុត គឺត្រឹមជាស្បៀងអាហារតែប៉ុណ្ណោះ ក៏ប៉ុន្តែសម្រាប់បច្ចុប្បន្ននេះវិញប្រជាពលរដ្ឋមិនមែនខ្វះស្បៀងអាហារទៀតនោះទេ គឺពួកគាត់មានតម្រូវការប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធសម្រាប់ធ្វើដំណើរវិញ។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងស្ពានអាកាសក្នុងរាជធានីភ្នំពេញ គឺជា


ប្រជាពលរដ្ឋ មន្ត្រីរាជការ អញ្ជើញចូលរួម




សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចុចប៊ូតុងបើកការដ្ឋានសាងសង់ស្ពានអាកាស ក្នុងរាជធានីភ្នំពេញ

ការប្រើយុទ្ធសាស្ត្រយកស្លឹកត្នោតខ្ចប់ស្ករត្នោត មានន័យថា យកលុយចំណូលពីការវិនិយោគក្នុងរាជធានីមកអភិវឌ្ឍរាជធានីភ្នំពេញវិញ។ រហូតមកដល់ពេលបច្ចុប្បន្នរាជធានីភ្នំពេញបានចំណាយលើការសាងសង់ទាំងស្ពានឆ្លងទន្លេ និងស្ពានអាកាសសរុបថវិកាជាង ២២៦លានដុល្លារអាមេរិក ហើយសម្ដេចតេជោក៏បានមានប្រសាសន៍បង្ហើបថា រាជរដ្ឋាភិបាលកំពុងសិក្សាបង្កើតក្រុងល្វាឯម នាពេលខាងមុខផងដែរ។

ទាក់ទងទៅនឹងរឿងប្រជាពលរដ្ឋប្រមូលផ្ដុំនៅភ្នំគូលែន ដែលអ្នកខ្លះរត់ចោលផ្ទះ រត់ចោលការងារនោះ សម្ដេចតេជោ **ហ៊ុន សែន** សូមអភ័យទោសចំពោះរដ្ឋាភិបាលកូរ៉េ ជប៉ុន និងថៃ និងសូមកុំឱ្យដាក់ពាក្យបណ្ដឹងលើពលករ ដែលរត់ចោលការងារ ព្រោះចាញ់បោកការឃោសនារបស់ លោក **ខឹម វាសនា** ។ សម្ដេចតេជោបានមានប្រសាសន៍ឱ្យដឹងថា បំណងលោក **ខឹម វាសនា** ចង់បានការប្រើកម្លាំង ដើម្បីប្រែក្លាយពីរឿងជំនឿទៅជារឿងនយោបាយ។ ភ្លាមៗសម្ដេចបានបញ្ជាទៅកងកម្លាំងត្រូវប្រយ័ត្ន មិនឱ្យចូលក្នុងអន្ទាក់របស់លោក **ខឹម វាសនា** នោះឡើយ ទោះជាយ៉ាងណាក៏ដោយសម្ដេចតេជោបានថ្លែងថា លោក **ខឹម វាសនា** អត់បានអំពាវនាវឱ្យប្រជាពលរដ្ឋងើបបះបោរផ្ដួលរាជរដ្ឋាភិបាល ឬឱ្យបរទេសកាត់ជំនួយពីកម្ពុជានោះឡើយ។ នៅពេលកើតមានព្រឹត្តិការណ៍ជួបជុំនៅចម្ការលោក **ខឹម វាសនា** សម្ដេចបានដាក់ចេញបទបញ្ជាចំនួនពីរ ទី១៖ ត្រូវការពារសន្តិសុខឱ្យបាន កុំឱ្យបាត់ដៃទី២ឆ្លៀតប្រើបង្កើតរឿងផ្សេងៗ និងទី២៖ ដាច់ខាតមិនឱ្យទៅដណ្ដើមដីនៅរុនតាឯកនោះទេ។ សម្ដេចតេជោ **ហ៊ុន សែន** បានបញ្ជាក់ថា ដីនៅរុនតាឯកអត់មានត្រូវបែកចែកឱ្យអ្នកគាំទ្រ **ខឹម វាសនា** នោះឡើយ បើ **ខឹម វាសនា** ចិត្តល្អគួរបែងចែកដីចម្ការ ១២ហិកតា នោះឱ្យទៅអ្នកគាំទ្រទៅ។



សម្ដេចតេជោ **ហ៊ុន សែន** ណែនាំឱ្យអភិបាលខេត្តសៀមរាបរៀបចំរថយន្តជួយដឹកអ្នកគាំទ្រលោក **ខឹម វាសនា** ត្រឡប់ទៅផ្ទះវិញ បើមានអ្នកអត់មានមធ្យោបាយត្រឡប់ទៅផ្ទះ





គំនូរប្លង់ ស្ពានអាកាស ក្នុងរាជធានីភ្នំពេញ




*សម្តេចតេជោ ហ៊ុន សែន បង្ហាញនូវក្តីរីករាយ អញ្ជើញចុចប៊ូតុងបើកការដ្ឋានសាងសង់ស្ពានអាកាស*

ហើយត្រូវរៀបចំបាយទឹកជូនពួកគាត់ផងដែរ។ សម្តេចតេជោបានស្នើលោក **ខឹម វាសនា** ឱ្យបញ្ឈប់សកម្មភាព និងកុំបង្ខាំងប្រជាពលរដ្ឋ ត្រូវអនុញ្ញាតឱ្យពួកគេត្រឡប់ទៅផ្ទះវិញ និងបានអំពាវនាវឱ្យពលរដ្ឋនៅក្នុងចម្ការលោក **ខឹម វាសនា** ដើរចេញពីចម្ការ ដោយអាជ្ញាធរត្រៀមរថយន្តដឹកត្រឡប់ទៅផ្ទះ និងរៀបចំបាយទឹកជូន។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានអបអរសាទរចំពោះសមិទ្ធផលស្ពានអាកាសចំនួនពីរបន្ថែមទៀត និងចុងបញ្ចប់សម្តេចតេជោក៏បានអញ្ជើញចុចប៊ូតុងបើកការដ្ឋានសាងសង់ស្ពានអាកាសចំនួនពីរចាប់ពីពេលនេះតទៅ។

សូមបញ្ជាក់ថា នៅរសៀលថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម **ឃួង ស្រេង** អញ្ជើញចូលរួមក្នុងពិធីក្រុងពលីតាមបែបសាសនា បួងសួងសុំសេចក្តីសុខ សេចក្តីចម្រើនពីម្ចាស់ទឹកម្ចាស់ដី ដើម្បីបើកការដ្ឋានសាងសង់ស្ពានអាកាសពីរកន្លែងព្រមគ្នានៅចំណុចប្រសព្វផ្លូវ៦០ម៉ែត្រ(ក្បាលថ្នល់) និងនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី ត្រង់ចំណុចប្រសព្វផ្លូវ២០០៤ ពិធីក្រុងពលីបានធ្វើឡើងមុនមួយថ្ងៃ មុននឹងប្រារព្ធពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសពីរកន្លែង។ ឯកឧត្តម **ឃួង ស្រេង** បានលើកឡើងថា នេះជាសមិទ្ធផលថ្មីបន្ថែមទៀតដែលនឹងលេចចេញជារូបរាងក្នុងពេលឆាប់ៗខាងមុខក្នុងរាជធានីភ្នំពេញក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យរាជធានីភ្នំពេញមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ បម្រើឱ្យសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងទីក្រុង ពិសេសកាត់បន្ថយការកកស្ទះចរាចរណ៍ គ្រោះថ្នាក់ចរាចរ និងសម្រួលដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញដែលមានការកើនឡើងទាំងចំនួនមនុស្ស និងមធ្យោបាយធ្វើដំណើរ។

*(ប្រភព៖ pressocm.gov.kh)*



*ប្រជាពលរដ្ឋ មន្ត្រីរាជការ អញ្ជើញចូលរួម*



*គំនូរប្លង់ ស្ពានអាកាស ក្នុងរាជធានីភ្នំពេញ*

# ពិធីបុណ្យសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ញឹម តេង មាតាក្មេក លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ AKP- ទា ផូលីន*



សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំប្រតិភូចូលរួមគោរពវិញ្ញាណក្ខន្ធសព ព្រឹទ្ធមហាឧបាសិកាសាសនូបត្ថម្ភក៍ ញឹម តេង

ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** មាតាក្មេក លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានទទួលមរណភាព កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២ វេលាម៉ោង ១៣:00 និង ៤0 នាទី ត្រូវនឹង ថ្ងៃអាទិត្យ ទី ៩ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ក្នុងជន្មាយុ ៩៤ឆ្នាំ ដោយជរាពាធ។ សពត្រូវបានតម្កល់ធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនានៅគេហដ្ឋាន ផ្ទះលេខ១ ផ្លូវលេខ៥ ស្ថិតក្នុងបុរីប៉េងហួត ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

ក្នុងពិធីតម្កល់សព ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** នេះដែរ មានប្រតិភូគ្រប់លំដាប់ថ្នាក់ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួងស្ថាប័ន រាជធានី-ខេត្ត ភ្ញៀវកិត្តិយសជាតិ អន្តរជាតិយ៉ាងច្រើនកុះករ បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធជាបន្តបន្ទាប់ ដោយបានសំដែងនូវសមានទុក្ខដ៏ក្រៀមក្រំអាឡោះអាល័យនិងក្តីរន្ធត់ឥតឧបមា ចំពោះការបាត់បង់ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភន៍ ញឹម តេង ដែលជាមាតាជាជីដូន ជីដូនទួត ប្រកបដោយព្រះព្រហ្មវិហារធម៌ និងចរិយា







ធម៌ដ៏ពិសិដ្ឋ របស់កូនចៅ ចៅទួត និងញាតិសន្តាន ។ ទន្ទឹមជាមួយគ្នានោះដែរ ក៏មានព្រះរាជសារ លិខិតចូលរួមរំលែកទុក្ខ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរព សក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបានព្រះរាជទានចំពោះ មរណភាព របស់ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** រួមជាមួយថ្នាក់ដឹកនាំជាតិគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាច្រើនផងដែរ ។ ក្នុងនោះដែរក៏មាន សារលិខិតរំលែកទុក្ខ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។

លោកជំទាវកិត្តិសង្គបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក៏បានថ្លែងអំណរគុណក្នុងនាមគ្រួសារ ខ្ញុំម្ចាស់នាងខ្ញុំ សូមសំដែងអំណរព្រះគុណនិងអរគុណយ៉ាងជ្រាលជ្រៅចំពោះ ជូនចំពោះសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេច





ឯកឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អញ្ជើញដឹកនាំប្រតិភូចូលរួមគោរពវិញ្ញាណក្ខន្ធសពព្រឹទ្ធមហាឧបាសិកាសាសនូបត្ថម្ភក៍ ញឹម តេង




ព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង សម្តេចព្រះរាជាគណៈគ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួងស្ថាប័ន រាជធានី-ខេត្ត ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ព្រមទាំងញាតិមិត្តជិតឆ្ងាយ ទាំងអស់ដែលមានសមានចិត្ត និងមនោសញ្ចេតនាជ្រាលជ្រៅ អញ្ជើញចូលរួមដោយផ្ទាល់ និងឬបាន





ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន អញ្ជើញដឹកនាំប្រតិភូចូលរួមគោរពវិញ្ញាណក្ខន្ធ
សពព្រឹទ្ធមហាឧបាសិកាសាសនូបត្ថម្ភក៍ ញឹម តេង










ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អញ្ជើញដឹកនាំប្រតិភូចូលរួមគោរពវិញ្ញាណក្ខន្ធសព
ព្រឹទ្ធមហាឧបាសិកាសាសនូបត្ថម្ភក៍ ញឹម តេង



ចាត់ប្រតិភូចូលរួមក្នុងពិធីបុណ្យសព ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ញឹម តេង** ត្រូវជាម្តាយ ម្តាយក្មេក យាយ យាយទួត ជាអ្នកមានគុណរបស់យើងខ្ញុំទាំងអស់គ្នា នឹងបានផ្ញើសារលិខិតរំលែកទុក្ខដ៏ក្រៀមក្រំ និងការសោកស្តាយជាពន់ពេកជាមួយក្រុមគ្រួសារយើងខ្ញុំ ។

ខ្ញុំម្ចាស់ នាងខ្ញុំ សូមលំឱនកាយ សម្តែងនៅកតញ្ញូតាធម៌ និងការដឹងគុណដ៏ជ្រាលជ្រៅចំពោះកាយវិការដ៏ប្រពៃណី សបញ្ជាក់ឱ្យឃើញច្បាស់នៅទឹកចិត្តស្រឡាញ់រាប់អានដ៏ឧត្តុង្គឧត្តម ចំពោះ






លោកឧកញ៉ា ផៃ ហុកឈួន និងលោកជំទាវឧកញ៉ា អ៊ឹង ស៊ីស្រ៊ន អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព ព្រឹទ្ធមហាឧបាសិកាសាសនូបត្ថម្ភក៍ ញ៉ឹម តេង





ក្រុមគ្រួសារយើងខ្ញុំ ដែលធ្វើឱ្យយើងខ្ញុំទាំងអស់គ្នាមិនអាចបំភ្លេចបាននូវសមានចិត្តដ៏ប្រពៃថ្លៃថ្លាទាំងនេះបានឡើយនិងសូមប្រទានពរថ្វាយព្រះពរនិងជូនពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង សម្តេចព្រះរាជាគណៈគ្រប់គ្រងព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវអ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី-ខេត្ត ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ព្រមទាំងញាតិមិត្តជិតឆ្ងាយទាំងអស់ សូមបានប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ៕




លោកឧកញ៉ា ស៊ន សុខណា អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព ព្រឹទ្ធមហាឧបាសិកាសាសនូបត្ថម្ភក៍ ញ៉ឹម តេង

# លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ប្រារព្ធពិធីរាប់បាត្រ បង្សុកូល ឧទ្ទិសកុសលផលបុណ្យ ដល់ព្រលឹងអ្នកស្លាប់នៅសារមន្ទីរ ប្រល័យពូជសាសន៍ទួលស្លែង

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ទា ផូលីន*



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញចូលរួមពិធីបង្សុកូល រាប់បាត្រឧទ្ទិសកុសលផលបុណ្យដល់ព្រលឹងអ្នកស្លាប់ក្នុងរបបប្រល័យពូជសាសន៍នៅសារមន្ទីរទួលស្លែង





ពិធីសូត្រមន្ត

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិមន្តព្រះសង្ឃ សូត្រមន្ត រាប់បាត្រ បង្សុកូលឧទ្ទិសកុសលផលបុណ្យដល់ព្រលឹងអ្នកស្លាប់ជាង១ម៉ឺន៨ពាន់នាក់ នៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃកាន់បិណ្ឌវេនទី៧ នៃបុណ្យភ្ជុំបិណ្ឌ ត្រូវនឹងថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០២២ ។



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញអុជធូបឧទ្ទិសដល់ព្រលឹងអ្នកស្លាប់ក្នុងបរិវេណមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ក្នុងពិធីនេះ ក៏មានការចូលរួមពីសំណាក់លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រួមជាមួយគណៈគ្រប់គ្រងមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងថ្នាក់ដឹកនាំមន្ត្រីរាជការ ប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះករ ។

លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** និងលោកជំទាវ **ភឿង សកុណា** តែងនាំមន្ត្រីរាជការរៀបចំពិធីបង្សុកូល រាប់បាត្រឧទ្ទិសកុសលផលបុណ្យដល់ជនរងគ្រោះ ដែលបាត់



បង់ជីវិតនៅក្នុងរបបប្រល័យពូជសាសន៍ នៅមុនពេលពិធីបុណ្យចូលឆ្នាំខ្មែរនិងពេលថ្ងៃកាន់បិណ្ឌនៃពិធីបុណ្យភ្ជុំបិណ្ឌ ដើម្បីឧទ្ទិសដល់ប្រជាជនខ្មែរទាំងអស់ ដែលអ្នកខ្លះស្លាប់ទៅដោយពុំមានក្រុមគ្រួសារនិងអ្នកខ្លះបាត់បង់ជីវិតទាំងគ្រួសារតែម្តង ហើយការឧទ្ទិសនៅថ្ងៃនេះ គឺឧទ្ទិសដល់អ្នកបាត់បង់ជីវិតនៅក្នុង



លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន និងភ្ញៀវកិត្តិយសអញ្ជើញអុជធូបឧទ្ទិសដល់ព្រលឹងអ្នកស្លាប់ក្នុងបរិវេណមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



ថ្នាក់ដឹកនាំ និងភ្ញៀវកិត្តិយសអញ្ជើញរាប់បាត្រប្រគេនព្រះសង្ឃ





ថ្នាក់ដឹកនាំ និងភ្ញៀវកិត្តិយសអញ្ជើញរាប់បាត្រប្រគេនព្រះសង្ឃ

មជ្ឈមណ្ឌលឧក្រិដ្ឋកម្មទួលស្លែងនេះ និងក៏ឧទ្ទិសដល់អ្នកដែលបាត់បង់ជីវិតរាប់លាននាក់ នៅទូទាំងប្រទេសផងដែរ ។

លោកជំទាវកិត្តិសង្គហបណ្ឌិត បានមានប្រសាសន៍បន្តថា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភាព្រឹទ្ធសភានិងអធិការកិច្ច និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ តែងនាំមន្ត្រីរាជការក្រសួង រៀបចំពិធីបង្សុកូលរាប់បាត្រ ដើម្បីឧទ្ទិសកុសលផលបុណ្យដល់ជនរងគ្រោះ ដែលបានបាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ ជារៀងរាល់ឆ្នាំ ពោលគឺនៅពេលពិធីបុណ្យចូលឆ្នាំខ្មែរនិងនៅពេលថ្ងៃកាន់បិណ្ឌនៃពិធីបុណ្យភ្ជុំបិណ្ឌ សំដៅឧទ្ទិសដល់បងប្អូនប្រជាជនខ្មែរទាំងអស់នោះ ដែលបានបាត់បង់ជីវិតទាំងគ្រួសារ

នៅក្នុងមជ្ឈមណ្ឌលឧក្រិដ្ឋកម្មទួលស្លែងនេះ និងក៏ឧទ្ទិសដល់អ្នកដែលបាត់បង់ជីវិតរាប់លាននាក់ នៅទូទាំងប្រទេស ។

ជាមួយនេះ លោកជំទាវកិត្តិសង្គហបណ្ឌិត ក៏បានបួងសួងជូនពរ ដល់ប្រមុខរាជរដ្ឋាភិបាលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងប្រជាពលរដ្ឋនៅទូទាំងប្រទេស សូមបានប្រកបនិងជួបប្រទះតែសេចក្តីសុខ សន្តិភាព និងសេចក្តីចម្រើនគ្រប់ៗគ្នាជារៀងរហូត ៕



រូបថតអនុស្សាវរីយ៍

# សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង ប្រមូលចំណូលបាន ចំនួន ១៨៨,៥៦ ប៊ីលានរៀល នៅឆមាសទី១ ឆ្នាំ២០២២

*អត្ថបទ៖ ឡាយ សារ៉ុម , រូបថត៖ អ៊ុង ហុងលៀង*



*ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់អគារសាខាគយខេត្តស្វាយរៀង*

«ការប្រមូលចំណូលនៅឆមាសទី១ ឆ្នាំ២០២២ សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង ប្រមូលចំណូលបានចំនួន១៨៨,៥៦ ប៊ីលានរៀល ស្មើជាង៩៤ភាគរយ នៃផែនការ បើ ធៀបរយៈពេលដូចគ្នានៅឆ្នាំ២០២១ ពោលកើនឡើងប្រមាណ៤០,២៩ប៊ីលានរៀល ស្មើជាង២៧ភាគរយ» ។ នេះជាប្រសាសន៍របស់លោក **ហេង សំបូរ** ប្រធានសាខាគយនិងរដ្ឋាករខេត្តស្វាយរៀងបានលើកឡើងនៅក្នុងពិធីសម្ពោធ ដាក់ឱ្យប្រើប្រាស់អគារសាខាគយខេត្តស្វាយរៀងក្រោមអធិបតីភាព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ នាព្រឹកថ្ងៃសុក្រ ចុងឆ្នាំ២០២២ ដោយមានការអញ្ជើញចូលរួម



*លោក ហេង សំបូរ ប្រធានសាខាគយខេត្តស្វាយរៀងធ្វើបទបង្ហាញជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន*



ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន អញ្ជើញពិនិត្យតារាងពន្ធគយ



ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្នជួបសំណេះសំណាល
ជាមួយមន្ត្រីគយ

ពីឯកឧត្តមបណ្ឌិត **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាប្រតិភូអមដំណើរព្រមទាំងមន្ត្រីពាក់ព័ន្ធជាច្រើនរូបទៀត។

នៅក្នុងឱកាសនោះឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងនូវការកោតសរសើរ ដល់រដ្ឋបាលខេត្តស្វាយរៀង ដែលមានឯកឧត្តម **ម៉ែន វិបុល** ជាអភិបាលខេត្ត និងមន្ត្រីរាជការសាខាគយនិងរដ្ឋាករខេត្តស្វាយរៀងទាំងអស់




ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសាខាគយខេត្តស្វាយរៀង



*ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ជួបសំណេះសំណាល ជាមួយមន្ត្រីគយ*



*ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន និងលោក ហេង សំបូរ ប្រធានសាខាគយខេត្តស្វាយរៀងថតរូបអនុស្សាវរីយ៍*

បានចូលរួមចំណែកក្នុងការប្រមូលពន្ធជូនរដ្ឋធ្វើឱ្យកំណើនថវិកាចំណូលចូលរដ្ឋពីមួយឆ្នាំទៅមួយឆ្នាំមានការកើន ឡើងជាបន្តបន្ទាប់។ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ក៏បានជំរុញដល់សាខាគយ និងរដ្ឋាករខេត្តស្វាយរៀងក៏ ដូចជាមន្ត្រីគយទាំងអស់ត្រូវខិតខំបំពេញភារកិច្ចតួនាទីរបស់ខ្លួនឱ្យបានល្អ ជាពិសេស ត្រូវចូលរួមសហការជាមួយរដ្ឋបាលខេត្តគ្រប់ភាគី ដែលពាក់ព័ន្ធទាំងអស់ ដើម្បីជំរុញឱ្យការប្រមូលពន្ធជូនរដ្ឋមានការកើនឡើង ដែលធ្វើឱ្យសេដ្ឋកិច្ចជាតិកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា ទីតាំងអគារថ្មីរបស់សាខាគយ និងរដ្ឋាករខេត្តស្វាយរៀង ដែលបានសម្ពោធឱ្យប្រើប្រាស់នៅថ្ងៃនោះ ស្ថិតនៅលើផ្ទៃដីសរុប ៧ ៩៩០ម៉ែត្រការ៉េ ស្ថិតនៅក្នុងភូមិស្វាយ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង៕




*អគារសាខាគយខេត្តស្វាយរៀង*

# កិច្ចប្រជុំក្រុមប្រឹក្សាភិបាលស្តីពីទឹក នៃសភាអាស៊ីលើកទី ៥
# គ្រោងរៀបចំប្រជុំនៅឆ្នាំ២០២៣ នៅកម្ពុជា

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ វង្គសភា*



លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី ទទួលជួបពិភាក្សាជាមួយប្រតិភូក្រុមប្រឹក្សាទឹកនៃសភាអាស៊ី ដឹកនាំដោយលោកសាស្ត្រាចារ្យបណ្ឌិត Yong Deok Cho

ការគ្រប់គ្រងនិងត្រួតពិនិត្យលើបរិមាណ និងគុណភាពទឹក ទាមទារនៅការយល់ដឹងអំពីវិទ្យាសាស្ត្រ បរិស្ថាន សង្គមនិងតម្រូវការរបស់មនុស្ស ជាពិសេស ការវិនិយោគ លើការកសាងធនធានមនុស្ស បច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធទឹក។ ការអភិវឌ្ឍទឹកតម្រូវឱ្យរៀបចំផែនការមេ ដែលមានលក្ខណៈស៊ីសង្វាក់ជាប្រព័ន្ធស្រប និងលក្ខណៈទីតាំងភូមិសាស្ត្ររបស់ប្រទេសនីមួយៗ ។

មានប្រសាសន៍ លើកឡើងខាងលើ បែបនេះរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** អនុប្រធានទី ២ រដ្ឋសភា កាលពីថ្ងៃទី ៥ខែកញ្ញា ឆ្នាំ២០២២នៅវិមានរដ្ឋសភា ក្នុងឱកាស លោកជំទាវអនុប្រធានទី២ ទទួលជួបប្រតិភូក្រុមប្រឹក្សាទឹកនៃសភាអាស៊ី ដឹកនាំដោយលោកសាស្ត្រាចារ្យបណ្ឌិត Yong deok Cho អគ្គលេខាធិការក្រុមប្រឹក្សាទឹក អាស៊ី (Asian Water Council -AWC) ចូលរួមជួបសំដែងការគួរសមនិងពិភាក្សាលើការងារ មួយចំនួនពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា



-ភិបាលអំពីទឹកនៃសភាអាស៊ីលើកទី៥ ដែលគ្រោងរៀបចំនៅខែមីនា ឆ្នាំ២០២៣ នៅព្រះរាជាណាចក្រកម្ពុជា ។

លោកជំទាវកិត្តិសង្គហបបណ្ឌិត បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ប្រតិភូក្រុមប្រឹក្សាទឹកអាស៊ីនៃរដ្ឋសភាសាធារណរដ្ឋកូរ៉េ ដើម្បីពង្រឹងនិងអនុវត្តកិច្ចសហប្រតិបត្តិការការទូត សភាសម្រាប់ប្រទេសទាំងពីរក៏ដូចជាសមាជិកនៃក្រុមប្រឹក្សាទឹកអាស៊ីផងដែរ ដែលមានសមាជិកសរុប ១១ ប្រទេស។ លោកជំទាវ



សមាសភាពប្រតិភូក្រុមប្រឹក្សាទឹកនៃសភាអាស៊ី

បានលើកឡើងអំពីសារៈសំខាន់នៃការគ្រប់គ្រងធនធានទឹករួមទាំងទឹកសម្រាប់បរិភោគ ទឹកប្រើប្រាស់ ទឹកស្រោចស្រពក្នុងវិស័យកសិកម្ម និងឧស្សាហកម្មដែលមានភាពចាំបាច់សម្រាប់មនុស្សជាតិ ។ នៅក្នុងដំណាក់កាលនៃបម្រែបម្រួលអាកាសធាតុ និងការប្រែប្រួលសណ្តាប់ធ្នាប់ពិភពលោក សន្តិសុខស្បៀង គឺមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានាបាននូវការបម្រើជូនប្រជាជនក្នុងពេលដែលមានវិបត្តិសង្គ្រាមកើតឡើង ។ ហេតុដូចនេះ សន្តិសុខទឹកពិតជាមានភាពពាក់ព័ន្ធទៅនឹងវិស័យជាច្រើនដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព ។ ការគ្រប់គ្រង និងត្រួតពិនិត្យលើបរិមាណនិងគុណភាពទឹកទាមទារនៅការយល់ដឹងអំពីវិទ្យាសាស្ត្រ បរិស្ថាន សង្គម និងតម្រូវការរបស់មនុស្ស ជាពិសេស ការវិនិយោគលើការកសាងធនធានមនុស្សបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធទឹក ។ ការអភិវឌ្ឍទឹកតម្រូវឱ្យមាន ការរៀបចំផែនការមេដែលមានលក្ខណៈស៊ីសង្វាក់ជាប្រព័ន្ធស្រប និងលក្ខណៈទីតាំងភូមិសាស្ត្ររបស់ប្រទេសនីមួយៗ ។

សូមបញ្ជាក់ថា ក្រុមប្រឹក្សាទឹកនៃសភាអាស៊ី ( ASIA



ពិធីផ្លាស់ប្តូរវត្ថុអនុស្សាវរីយ៍



សមាសភាពថ្នាក់ដឹកនាំរដ្ឋសភា

NATIONAL ASSEMBLY WATER CONSULTATIVE BOARD ) ដែលហៅកាត់ថា " AAWC " ត្រូវ បង្កើតឡើងក្នុងគោលបំណងជួយពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមសភានៃបណ្តាប្រទេសក្នុងទ្វីបអាស៊ី ដែលកំពុងមានការលំបាកក្នុងការរៀបចំគោលនយោបាយទឹក និងដោះស្រាយបញ្ហាទឹក ដែលទាមទារឱ្យមានការចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងចែករំលែកអំពីការកសាងច្បាប់ គោលនយោបាយទឹក និង ដាក់ចេញគោលនយោបាយទឹកសម្រាប់សកម្មភាព អង្គការនីតិបញ្ញត្តិ និងមានភាពទាក់ទង គ្នាជាមួយនិងអង្គការនីតិប្រតិបត្តិ ។

ក្រុមប្រឹក្សាទឹកនៃសភាអាស៊ីមានអង្គប្រតិបត្តិមួយសំខាន់ គឺក្រុមប្រឹក្សាទឹកអាស៊ី (Asia Water Council –AWC ) ដែលត្រូវបង្កើតឡើងក្នុងឆ្នាំ ២០១៦ ដើម្បីសម្រេចបាននូវការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកក្នុងតំបន់អាស៊ីឱ្យមានចីរភាពស្រប ទៅនិងការប្រែប្រួលអាកាសធាតុ ។ ការយល់ដឹងអំពីវិធី សាស្ត្រប្រើប្រាស់គ្រប់គ្រងទឹក និងវិនិយោគលើធនធានទឹក អាចផ្តល់ឱ្យយើងនៅបច្ច័យល្អសម្រាប់ការរស់របស់សង្គម ក៏ដូចជាការកសាងទីក្រុងឆ្លាតវៃស្របតាមបច្ចេកវិទ្យាថ្មីៗ ។

ក្រោយជំនួបសម្តែងការគួរសមជាមួយលោកជំទាវអនុប្រធានទី២រួចមក ប្រតិភូក្រុមប្រឹក្សាទឹកនៃសភាអាស៊ីក៏បន្តប្រជុំការងារ ដើម្បីពិភាក្សាអំពីការគ្រោង រៀបចំក្រុមប្រឹក្សាភិបាលនៅកម្ពុជាជាមួយឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥នៃរដ្ឋសភានិងរៀបចំផែនការសកម្មភាពដើម្បីសហប្រតិបត្តិការក្នុងកម្រិតពហុភាគី តំបន់ និងទ្វេភាគី ។ សម្រាប់គម្រោងនាពេលអនាគត AAWC និង AWC និងពិនិត្យលទ្ធភាពដាក់លេខាធិការដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីបន្តអនុវត្តគោលនយោបាយ និងផែនការសកម្មភាពសំខាន់ៗសម្រាប់



ពិធីផ្លាស់ប្តូរវត្ថុអនុស្សាវរីយ៍

ការទូតសភា អំពីការអនុវត្តនៅទស្សនទាន ភាពប្រទាក់ក្រឡាគ្នារវាងថាមពល ទឹក និងការរៀបចំធានានៅសន្តិសុខស្បៀង ។ ភាគីទាំងពីរ នឹងបន្តសហការគ្នាដើម្បីភាពជោគជ័យ នៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលទឹកនៃសភាអាស៊ីនាឆ្នាំក្រោយ ។

ក្នុងជំនួបលោក Yongdeok Cho បានថ្លែងអំណរគុណជូនចំពោះ លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ដែលបានចំណាយពេលវេលាដ៏មមាញឹកជួបប្រតិភូក្រុមប្រឹក្សាទឹកអាស៊ីនាពេលនេះ ។ លោកបានរំលឹកអំពីដំណើរទស្សនកិច្ចរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភាទៅកាន់សាធារណរដ្ឋកូរ៉េ កាលពីខែមេសា ឆ្នាំ២០២២ កន្លងមក ដោយទទួលបានលទ្ធផលដ៏ត្រចះត្រចង់ ។ នាដំណើរទស្សនកិច្ចនាពេលនោះ លោក Byun Jaeill ប្រធានក្រុមមិត្តភាពកូរ៉េ-កម្ពុជា និងជាប្រធានក្រុមប្រឹក្សាភិបាលទឹកនៃសភាអាស៊ី (AAWC) បានថ្លែងអំណរគុណចំពោះសភាកម្ពុជា ដែលបានចាត់តាំងឯកឧត្តម សួស យ៉ារ៉ា ប្រធានគណៈកម្មការទី ៥នៃរដ្ឋសភាកម្ពុជាចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាទឹក នៃសភាអាស៊ីលើកទី៤ នៅប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី ១៥ -១៦ ខែមីនា ឆ្នាំ ២០២២ និងបានសំដែងនូវការរីករាយ ដែលកម្ពុជាឯកភាពរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាទឹកនៃសភាអាស៊ីលើកទី ៥ នាឆ្នាំ ២០២៣ ខាងមុខ ។

គួររំលឹកផងដែរថា កិច្ចប្រជុំលើកទី៤ របស់ AAWC ក៏បានអនុម័តលើគម្រោងមួយ ក្រោមកម្មវិធីសុខុមាលភាពទឹកស្អាត AAWC នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ គម្រោងនេះ មានថវិកាចំនួន ៩៩៨ លានវ៉ុនកូរ៉េ ( ប្រហែល ៧៤៨,៩៤៥ ដុល្លារអាមេរិក ) ក្នុង គោលបំណងបង្កើតផែនការមេសម្រាប់សន្តិសុខទឹកក្នុងស្រុកគងពិសី ដោយមានក្រសួងធនធានទឹក និងឧតុនិយមជាភ្នាក់ងារអនុវត្តគម្រោង ៕



រូបថតអនុស្សាវរីយ៍

# គុយបា កោតសរសើរកម្ពុជា អំពីភាពជោគជ័យ ក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩

*អត្ថបទ ៖ រិទ្ធ , រូបថត ៖ ខឹម សុវណ្ណារ៉ា*



ប្រតិភូសាធារណរដ្ឋគុយបា ចូលជួបសម្ដែងការគួរសមជាមួយឯកឧត្តម ខៀវ កាញារីទ្ធ



ប្រតិភូភាគី គុយបា



ថ្នាក់ដឹកនាំនៃក្រសួងព័ត៌មានចូលរួមក្នុងជំនួប

ឯកឧត្តម Gerardo Peñalver Portal អនុរដ្ឋមន្ត្រីការបរទេសទី១ នៃសាធារណរដ្ឋគុយបា បានថ្លែងកោតសរសើរអំពីភាពជោគជ័យរបស់កម្ពុជាក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ ហើយក៏បានធ្វើការជំរុញសេដ្ឋកិច្ចប្រទេសជាតិមានការវិវឌ្ឍងើបឡើងវិញ។

ការលើកឡើងរបស់ឯកឧត្តម Gerardo បែបនេះ ក្នុងឱកាសដែលឯកឧត្តមចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន



ឯកឧត្តម ខៀវ កាញារីទ្ធ ជួបពិភាក្សាជាមួយភាគីគុយបា

កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២ ខណៈដែលឯកឧត្តមមកទស្សនកិច្ចការងារនៅកម្ពុជារយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២២ ។

ឯកឧត្តម Gerardo Peñalver Portal បានសម្តែងការភ្ញាក់ផ្អើលដោយលើកឡើងថា នេះជាលើកទីមួយដែលបានមកដល់តំបន់នេះ ហើយក៏មិននឹកស្មានថា រាជធានីភ្នំពេញ មានការរីកចម្រើនដ៏ធំ និងទំនើប ដែលបង្ហាញពីការដឹកនាំដ៏ល្អរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី។ ឯកឧត្តម Gerardo Peñalver Potal មានប្រសាសន៍ថាប្រទេសគុយបាមកដល់ពេលនេះ នៅមានការរងសម្ពាធនិងការបែងចែកការរើសអើងពីប្រទេសមួយចំនួន ហើយពិសេសការជំរុញដំណឹងក្លែងក្លាយបានធ្វើឱ្យយើងមានការលំបាក ។

ឯកឧត្តមសង្ឃឹមថា នឹងមានកិច្ចសហការល្អៗជាមួយនឹងក្រសួងព័ត៌មានកម្ពុជាដើម្បីជំរុញឱ្យប្រជាជននៃប្រទេសទាំងពីរ គុយបា-កម្ពុជា អាចយល់ពីគ្នាយ៉ាងច្រើនជាងនេះ ។

ឯកឧត្តម **ខៀវ កាញារីទ្ធ** បានជម្រាបជូនថា ប្រជាជនកម្ពុជាមិនភ្លេចនោះទេ ពីព្រោះនៅក្រោយឆ្នាំ១៩៧៩ ប្រទេសគុយបា គឺជាប្រទេសស្ថិតក្នុងប្រទេសដំបូងៗគេ ដែលបានបញ្ជូនគ្រូពេទ្យ វេជ្ជបណ្ឌិតគុយបាមកដល់ប្រទេសកម្ពុជាដើម្បីព្យាបាលអ្នកជំងឺ ហើយនេះជាកាយវិកាមួយដែលកម្ពុជាមិនអាចបំភ្លេចបាន។ ឯកឧត្តម រដ្ឋមន្ត្រី បានជម្រាបជូនដែរថា សម្រាប់ប្រទេសកម្ពុជាយើងក៏ធ្លាប់ស្គាល់ និងធ្លាប់ភ្លក់រសជាតិនៃការដែលគេហ៊ុមព័ទ្ធសេដ្ឋកិច្ចជាការលំបាក។ ដូចនេះហើយ សម្តេចតេជោ **ហ៊ុន សែន** តែងតែធ្វើការប្រឆាំងល្បែងដាក់ទណ្ឌកម្មសេដ្ឋកិច្ចនេះ ព្រោះមិនដែលមានការចំណេញអ្វីនោះទេ គឺធ្វើឱ្យមានការវេទនាដល់ប្រជាជនភាគច្រើន។ ទន្ទឹមនេះដែរ ឯកឧត្តម **ខៀវ កាញារីទ្ធ** សង្ឃឹមថា នៅក្នុងឱកាសដំណើរទស្សនកិច្ចផ្លូវការរបស់នាយករដ្ឋមន្ត្រីគុយបាមកកម្ពុជា ដែលជាឱកាសឱ្យក្រសួងព័ត៌មានជួបជាមួយទីភ្នាក់ងារសារព័ត៌មានអាមេរិកឡាទីន Prensa Latina គុយបា ដែលយើងមានកិច្ចសហប្រតិបត្តិការគ្នាតាំងពីឆ្នាំ១៩៨០ ដើម្បីធ្វើយ៉ាងណាជំរុញការផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមកឱ្យកាន់តែប្រសើរឡើង ដើម្បីផលប្រយោជន៍សម្រាប់ប្រជាជននៃប្រទេសទាំងពីរ កម្ពុជា-គុយបា ៕



ឯកឧត្តម ខៀវ កាញារីទ្ធ ជូនវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវ



ឯកឧត្តម Gerardo ជូនវត្ថុអនុស្សាវរីយ៍
ដល់ឯកឧត្តម ខៀវ កាញារីទ្ធ

# រដ្ឋមន្ត្រីក្រសួងការងារ៖ របបសន្តិសុខសង្គមផ្នែកប្រាក់សោធន ជារបបសន្តិសុខសង្គមថ្មីដ៏ល្អប្រសើរមួយ ដើម្បីរក្សាផលប្រយោជន៍ជូនកម្មករ-និយោជិត

*អត្ថបទ៖ សាត សុផល , រូបថត៖ ឯកសារ*



មន្ត្រី ប.ស.ស. ចុះផ្សព្វផ្សាយអំពីអត្ថប្រយោជន៍សោធននិវត្តន៍សម្រាប់និយោជិតកម្មករ

ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានក្រុមប្រឹក្សាភិបាល ប.ស.ស បានឱ្យដឹងថា របបសន្តិសុខសង្គមផ្នែកប្រាក់សោធន ជារបបសន្តិសុខសង្គមថ្មីដ៏ល្អប្រសើរមួយ សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយចាប់ផ្តើមបង់វិភាគទានចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ តទៅ ដែល ៥ឆ្នាំដំបូង នៃភាគទានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះ មានការចូលរួមពីភាគីនិយោជក ២ភាគរយ និងភាគីនិយោជិត ២ភាគរយ។ ប៉ុន្តែ ៥ឆ្នាំបន្ទាប់ នឹងមានការប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចក្នុងប្រទេស។

ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** ថ្លែងបែបនេះនៅក្នុងកិច្ចប្រជុំលើក ទី ៤ នៃ យុទ្ធនាការ ៩០ថ្ងៃ នៃពិធីផ្សព្វផ្សាយ




លោក ម៉ុង ហួត មន្ត្រី ប.ស.ស.
ធ្វើបទបង្ហាញអំពីអត្ថប្រយោជន៍សោធននិវត្តន៍



ភាគីនិយោជក និងភាគីនិយោជិតខ្លួនឯងផ្ទាល់។ ឯកឧត្តមបញ្ជាក់ថា បើប្រៀបធៀបជាមួយបណ្ដាប្រទេសផ្សេងៗ អត្រានៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននៅកម្ពុជា គឺស្ថិតនៅអត្រាទាបឆ្ងាយជាងប្រទេសជិតខាងនៅឡើយ។ ដូច្នេះសូមឱ្យនិយោជកទាំងអស់ត្រូវត្រៀមខ្លួនបង់ភាគទានចំនួន ២ភាគរយ សម្រាប់ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ព្រោះវា គឺជាកាតព្វកិច្ច។

ឯកឧត្តមរដ្ឋមន្ត្រី បានណែនាំដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករ-និយោជិត ត្រូវចូលរួមសហការដើម្បីធ្វើការផ្សព្វផ្សាយអំពីកាតព្វកិច្ច និងអត្ថប្រយោជន៍ នៃរបបសន្តិសុខ



កម្មករ និយោជិត តាមរោងចក្រសហគ្រាស ស្ដាប់បទបង្ហាញអំពីអត្ថប្រយោជន៍សោធននិវត្តន៍

ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារកាលពីពេលថ្មីៗនេះ ។ ឯកឧត្តមរដ្ឋមន្ត្រី បានលើកឡើងថា ការចូលរួមបង់ភាគទានរបស់ភាគីនិយោជកក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ គឺបង្ហាញពីការរួមចំណែក ក្នុងការ អភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើន ក៏ដូចជាលើកទឹកចិត្តកម្មករ និយោជិតឱ្យខិតខំធ្វើការងារ និងមានសង្ឃឹមខ្ពស់នៅពេលដែលពួកគាត់ចាស់ទៅធ្វើការលែងកើត និងសុខភាពចុះខ្សោយ នៅពេលនោះគាត់នឹងទទួលបានអត្ថប្រយោជន៍ និងការការពារពី ប.ស.ស. ផ្នែកប្រាក់សោធន និងផ្នែកថែទាំសុខភាព ដែលនេះបានមកពីការចូលរួមរបស់

សង្គម ផ្នែក ប្រាក់សោធន នេះ ឱ្យបានតែទូលំទូលាយ និងយល់ដឹង កាន់តែច្បាស់ ដើម្បីចូលរួម អនុវត្តន៍កាតព្វកិច្ច និងទទួលបានអត្ថប្រយោជន៍នៅពេលដែលគាត់ដល់អាយុចូលនិវត្តន៍ ស្របតាមច្បាប់ស្ដីពីរបបសន្តិសុខសង្គមពេញលេញប្រកបដោយភាពពេញចិត្ត និងរីករាយសាទរ។ ឯកឧត្តមរដ្ឋមន្ត្រី បានសំណូមពរឱ្យនិយោជក និងតំណាងនិយោជកទាំងអស់ធ្វើការបញ្ជូនឈ្មោះកម្មករ-និយោជិត ទៅក្នុងបញ្ជី ប.ស.ស. ឱ្យបានគ្រប់គ្នាដើម្បីរក្សាផលប្រយោជន៍ជូនកម្មករ-និយោជិត។

ក្រសួងការងារបានទុករយៈពេល ៣ខែ ចាប់ពីខែកក្កដា ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ ដើម្បីផ្សព្វផ្សាយរបបផ្នែកសោធននេះដល់កម្មករ-និយោជិត នៅតាមបណ្ដាតំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម រោងចក្រ សហគ្រាស គ្រឹះស្ថាន







កម្មករ និយោជិត តាមរោងចក្រសហគ្រាស ស្តាប់បទបង្ហាញអំពីអត្ថប្រយោជន៍សោធននិវត្តន៍

ទូទាំងរាជធានី-ខេត្ត ក្រុង ស្រុក-ខណ្ឌ ឱ្យបានយល់ដឹងកាន់តែច្បាស់លាស់ដើម្បីឱ្យដំណើរការអនុវត្តរបបនេះដោយរលូន។ យោងតាមរបាយការណ៍ស្តីពីយុទ្ធនាការ ៩០ថ្ងៃ នៃការចុះផ្សព្វផ្សាយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនបានឱ្យដឹងថា គិតត្រឹមថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ នេះ មានបងប្អូនកម្មករនិយោជិតសរុបប្រមាណជាង ៩៧ម៉ឺននាក់ ស្មើនឹង ២ ៣០៣ លើក បានចូលរួមឈ្វេងយល់ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន តាមរយៈយុទ្ធនាការចុះផ្សព្វផ្សាយរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។ ប.ស.ស. បាននិងកំពុងបន្តបង្កើនការផ្សព្វផ្សាយ ឱ្យកាន់តែទូលំទូលាយបន្ថែមទៀតទៅកាន់









កម្មករ និយោជិត តាមរោងចក្រសហគ្រាស ស្តាប់បទបង្ហាញអំពីអត្ថប្រយោជន៍សោធននិវត្តន៍

បងប្អូនប្រជាពលរដ្ឋនៅទូទាំងប្រទេស ពិសេសបងប្អូនកម្មករនិយោជិតធ្វើយ៉ាងណាឱ្យពួកគាត់ទាំងអស់បានយល់ដឹងកាន់តែច្បាស់អំពីការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីមួយនេះ។ ក្រុមការងារ ប.ស.ស.បានចាប់ផ្តើមបើកយុទ្ធនាការផ្សព្វផ្សាយរបបផ្នែកប្រាក់សោធនដល់កម្មករនិយោជិត នៅក្នុងសប្តាហ៍ទី៣ នៃខែកក្កដា ឆ្នាំ២០២២ បន្ទាប់ពីបានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធរួមមានសហជីពមន្ត្រីក្រសួងនិងនិយោជកចំនួន ៥លើករួចមក។





កម្មករ និយោជិត តាមរោងចក្រសហគ្រាស ស្តាប់បទបង្ហាញអំពីអត្ថប្រយោជន៍សោធននិវត្តន៍

ឯកឧត្តម **អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស បានមានឱ្យដឹងថា ប.ស.ស បានបែងចែកក្រុមការងារផ្សព្វផ្សាយនេះជា ៨ក្រុម ដោយក្នុងមួយក្រុមមាន ១០នាក់ រួមមានអ្នកផ្សព្វផ្សាយ និងអ្នកទំនាក់ទំនងតាមរោងចក្រ សហគ្រាសក្នុងនោះមាន ៤ ក្រុមចុះផ្សព្វផ្សាយនៅរាជធានីភ្នំពេញ និង៤ក្រុមទៀតចុះនៅតាមបណ្តាខេត្ត។ ការផ្សព្វផ្សាយនេះ គឺផ្តោតទៅលើរោងចក្រសហគ្រាសនៅតាមតំបន់សួនឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេសពិសេស តំបន់ដែលរោងចក្រសហគ្រាសច្រើនដោយធ្វើយ៉ាងណាបញ្ជ្រាបរបបសន្តិសុខសង្គមផ្នែកសោធននេះដល់កម្មករឱ្យបាន ៨០ភាគរយនៃកម្មករសរុបរបស់ ប.ស.ស. ប្រមាណ ១លាន ៤សែននាក់ នៅក្នុងរយៈពេល ៩០ថ្ងៃចាប់ពីខែកក្កដា រហូតដល់ដំណាច់ខែកញ្ញា មុននឹងអនុវត្តន៍របបនេះជាផ្លូវការនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ហើយកម្មករនិយោជិត និងនិយោជក នឹងចាប់ផ្តើមបង់វិភាគទានចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២២ តទៅ។

គួរបញ្ជាក់ថា របបសន្តិសុខសង្គមផ្នែកសោធននេះតម្រូវឱ្យកម្មករនិយោជិតត្រូវបង់វិភាគទាន២ភាគរយនិងនិយោជកបង់២ភាគរយ។ ប៉ុន្តែកម្មករនឹងទទួលបានប្រាក់១០០ភាគរយពេលដល់ពួកគាត់មានអាយុ៦០ឆ្នាំ ដែលត្រូវចូលនិវត្តន៍។

របបសន្តិសុខសង្គមផ្នែកសោធននេះ គោលនយោបាយដ៏





កម្មករ និយោជិត តាមរោងចក្រសហគ្រាស ស្តាប់បទបង្ហាញអំពីអត្ថប្រយោជន៍សោធននិវត្តន៍

ល្អបំផុត ដែលប្រមុខរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តន៍សម្រាប់វិស័យឯកជននេះ គឺជាជំហានថ្មីមួយទៀតដែលជាជំហានឆ្ពោះទៅកាន់ការអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមពេញលេញនៅកម្ពុជា និងជាចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមមួយដ៏រឹងមាំ ប្រកបដោយចីរភាព និងបរិយាបន្ន ដើម្បីជាប្រយោជន៍សម្រាប់ប្រជាជនគ្រប់ក្រុមគោលដៅ និងជាពិសេសការបង្ការហានិភ័យខ្ពស់នៃការធ្លាក់ចុះភ្លាមចូលក្នុងភាពក្រីក្រ នៅពេលចូលដល់វ័យចាស់ជរា ដែលនេះជាការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះបងប្អូនប្រជាពលរដ្ឋ ជាពិសេសគឺពលរដ្ឋមានវ័យចំណាស់។





# ឯកឧត្តម ហងូ សាមឿន អញ្ជើញចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០២២ នៅប្រទេសអូស្ត្រាលី

អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ NCDM



ទិដ្ឋភាពក្នុងសាលប្រជុំសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីការបន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០២២





សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ី-ប៉ាស៊ីហ្វិក ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០២២ សហការរៀបចំឡើងដោយរដ្ឋាភិបាលអូស្ត្រាលី និងអង្គការសហប្រជាជាតិទទួលបន្ទុកការងារកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (UNDRR) ក្រោមមូលបទ " ពីវិបត្តិទៅកាន់ភាពធន់ៈការផ្លាស់ប្តូរអនាគតនៃតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ " កំពុងប្រព្រឹត្តទៅនៅទីក្រុងប្រ៊ីសបែន ប្រទេសអូស្ត្រាលី ចាប់ពីថ្ងៃទី ១៩-២២ ខែកញ្ញា ឆ្នាំ ២០២២ ដែលមានប្រតិភូអញ្ជើញចូលរួមក្នុងអង្គសន្និសីទមានប្រមាណជាង ៣ ០០០នាក់ មកពី ៣៩ប្រទេស ក្នុងនោះមានប្រតិភូថ្នាក់រដ្ឋ

មន្ត្រីមានចំនួន ៣១រូប និងតំណាងអាស៊ាន,កិច្ចសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង,ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី,កោះតំបន់អាស៊ីប៉ាស៊ីហ្វិក,វិស័យឯកជន,យុវជន និងរដ្ឋបាលមូលដ្ឋាន ។

ដោយឡែកគណៈប្រតិភូកម្ពុជាដឹកនាំដោយ ឯកឧត្តម **ហង្ស សាមឿន** អនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ទីប្រឹក្សាសម្តេចតេជោនាយករដ្ឋមន្ត្រី តំណាងឯកឧត្តមទេសរដ្ឋមន្ត្រី **គន់ គីម** អនុប្រធានទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក៏បានអញ្ជើញចូលរួមក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ីប៉ាស៊ីហ្វិក ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ ២០២២ នោះផងដែរ ។ រដ្ឋមន្ត្រីប្រធានប្រតិភូនិងតំណាងអាស៊ាន,កិច្ចសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង,ធនាគារពិភពលោក,ធនាគារអភិវឌ្ឍន៍អាស៊ី ,កោះតំបន់អាស៊ីប៉ាស៊ីហ្វិក,វិស័យឯកជន,យុវជននិងរដ្ឋបាលមូលដ្ឋានត្រូវបានអញ្ជើញឱ្យចូលរួមថ្លែងបទអន្តរាគមន៍នៅឯវេទិកាថ្នាក់រដ្ឋមន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយដោយផ្តោតលើ



ឯកឧត្តម ហង្ស សាមឿន អញ្ជើញចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ី-ប៉ាស៊ីហ្វិក តំណាងឱ្យព្រះរាជាណាចក្រកម្ពុជា




ថ្នាក់ដឹកនាំអង្គសន្និសីទ




ថ្នាក់ដឹកនាំអង្គសន្និសីទ




ឯកឧត្តម ហង្ស សាមឿន អញ្ជើញចូលថ្លែងបទអន្តរាគមន៍តំណាងកម្ពុជា



ទិដ្ឋភាព និងសកម្មភាពរបស់អង្គសន្និសីទ




រូបថតអនុស្សាវរីយ៍

ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នៅតាមប្រទេសនីមួយៗក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកជាពិសេស÷ការធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពនិងការប្រឈមក្នុងការអនុវត្តក្របខ័ណ្ឌការងារសេនដាយរបស់សាមីប្រទេស។ ការចែករំលែកមេរៀនបទពិសោធន៍អំពីដំណោះស្រាយប្រកបដោយនវានុវត្តន៍និងភាពជាក់ស្តែង ដើម្បីកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅទូទាំងតំបន់។ ការពិនិត្យឡើងវិញនូវកិច្ចខិតខំប្រឹងប្រែងដើម្បីការពារនិងកាត់បន្ថយហានិភ័យដែលមានស្រាប់និងថ្មីនៅតាមរបស់ប្រទេសនិងអង្គការនីមួយៗ។ ការប្តេជ្ញាចិត្តក្នុងការអនុវត្តសកម្មភាពក្របខ័ណ្ឌការងារសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ ២០១៥-២០៣០៕






រូបថតអនុស្សាវរីយ៍

# សម្តេចតេជោ **ហ៊ុន សែន** រីករាយជាមួយពលរដ្ឋក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ស្របពេលដែលកម្ពុជាទទួលបានភ្ញៀវទេសចរសរុបជាង១លាន២សែននាក់ នាពិធីភ្ជុំបិណ្ឌ

*អត្ថបទ៖ កែ ផុស , រូបថត៖ AKP*



ភ្ញៀវទេសចរជាតិ-អន្តរជាតិ ទស្សនាប្រាសាទអង្គរវត្តក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ

ក្នុងសារជាសំឡេងផ្ញើជូនជនរួមជាតិ កាលពីព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងថា សម្តេចមានការរីករាយ ដោយសារនៅក្នុងប្រទេស បងប្អូនជនរួមជាតិ បានប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌប្រកបដោយជោគជ័យ ជាមួយនិងការរក្សាបាននូវសុវត្ថិភាពគ្រប់ផ្នែក ជាពិសេសគឺការពារបានដ៏ល្អប្រសើរ មិនឱ្យមានការរីករាលដាលនៃជំងឺកូវីដ-១៩។

សម្តេចតេជោ **ហ៊ុន សែន** បានបន្តថា ក្នុងរយៈពេលចុងក្រោយមកដល់ថ្ងៃនេះ សម្តេចបានទទួលព័ត៌មាន ពីថ្នាក់ដឹកនាំក្រសួងសុខាភិបាលជាបន្តបន្ទាប់ សម្រាប់ព័ត៌មានទាក់ទងនឹងការឆ្លងជំងឺកូវីដ-១៩ប្រចាំថ្ងៃ គឺនៅក្នុងកម្រិតក្រោម ១០ករណី ឬលើសបន្តិចបន្តួច និងបានទទួលព័ត៌មានពីអត្រាចាក់វ៉ាក់សាំងជាប្រចាំផងដែរ។ ជាងនេះទៀតសម្តេចតេជោ ក៏នៅបន្តតាមដានកិច្ចការ ដែលរាយការណ៍ដោយសម្តេចក្រឡាហោម **ស ខេង** ជាបន្តបន្ទាប់។

សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា ទោះបីជាសម្តេចមិនបានចូលរួមក្នុងពិធីបុណ្យភ្ជុំបិណ្ឌនៅឆ្នាំនេះក៏ដោយ ក៏សម្តេចសប្បាយរីករាយជាមួយបងប្អូនប្រជាពលរដ្ឋ ដែលបានធ្វើបុណ្យយ៉ាងសប្បាយរីករាយនៅក្នុងឆ្នាំនេះ ដែលខុសប្លែកពីឆ្នាំទៅ ដែលយើងស្ថិតក្នុងស្ថានភាពដ៏អាក្រក់នៃការឆ្លងកូវីដ-១៩ ។ នាឱកាសបុណ្យភ្ជុំបិណ្ឌ៣ថ្ងៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តម **ថោង ខុន** បានឱ្យដឹងថា កម្ពុជាទទួលបានភ្ញៀវទេសចរសរុបជាង១លាន២សែននាក់ នាពិធីបុណ្យភ្ជុំបិណ្ឌ និងការដើរកម្សាន្តរយៈពេល៣ថ្ងៃ ចាប់ពី



ភ្ញៀវទេសចរកម្សាន្តតំបន់ទេសចរណ៍នានាក្នុងស្រុក

ថ្ងៃទី២៤-២៦ ខែកញ្ញា ឆ្នាំ២០២២ ក្នុងនោះខេត្តបាត់ដំបង សៀមរាប ប៉ៃលិន ទទួលបានភ្ញៀវច្រើនជាងគេដាច់។ នេះបើតាម បានបញ្ជាក់កាលពីព្រឹកថ្ងៃទី២៧ខែកញ្ញានេះ។ឯកឧត្តម **ថោង ខុន** បានមានប្រសាសន៍ឱ្យដឹងថា៖«នាឱកាសពិធីបុណ្យភ្ជុំបិណ្ឌរយៈពេល៣ថ្ងៃ ពីថ្ងៃទី២៤-២៦ខែកញ្ញា ឆ្នាំ២០២២កម្ពុជាយើងទទួលបានភ្ញៀវទេសចរសរុបទូទាំងប្រទេស ១,២៥៩,១២១ នាក់ ក្នុងនោះភ្ញៀវជាតិមានចំនួន១,២៤៤,៦៤២នាក់ និងភ្ញៀវបរទេសផ្ទៃក្នុងមានចំនួន១៤,៤៧៩នាក់»។ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានលើកឡើងពីស្ថិតិប្រចាំថ្ងៃថា៖

* ថ្ងៃទី១ (២៤ កញ្ញា) ទទួលបាន៣៣៩,៤៥៩នាក់។

* ថ្ងៃទី២ (២៥ កញ្ញា) ទទួលបាន៥១២,១២៦នាក់។

* ថ្ងៃទី ៣ (២៦ កញ្ញា) ទទួលបាន៤០៧,៥៣៦នាក់។

ឯកឧត្តម ថោង ខុន បានបន្តឱ្យដឹងអំពីខេត្តដែលទទួលបានភ្ញៀវទេសចរច្រើនជាងគេទាំង១០ (Top 10) សម្រាប់រយៈពេល ៣ថ្ងៃនេះ រួមមាន៖

*ខេត្តបាត់ដំបងមានភ្ញៀវទេសចរ ចំនួន ២១០,១២២នាក់ ក្នុងនោះចំនួនភ្ញៀវទេសចរជាតិមានចំនួន ២០៩,៧៦៤នាក់ ចំនួនភ្ញៀវទេសចរអន្តរជាតិ(ទេសចរផ្ទៃក្នុង)មានចំនួន ៣៥៨នាក់។

*ខេត្តសៀមរាប មានភ្ញៀវទេសចរចំនួន ១៤៣,៤៧០នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិ និងបងប្អូនប្រជាពលរដ្ឋក្នុងខេត្ត មានចំនួនប្រមាណ ១៤០,០០០ នាក់។

*ខេត្តកែប ទទួលភ្ញៀវទេសចរ ចំនួន ១១៦,៧៧៦នាក់ ក្នុងនោះភ្ញៀវជាតិមានចំនួន ១១៥,៧១៤នាក់ និងអ្នកទេសចរបរទេសផ្ទៃក្នុង មានចំនួន ១,០៦២ នាក់។







* ខេត្តពោធិ៍សាត់ ទទួលបានភ្ញៀវទេសចរណ៍ សរុបចំនួន ៩៦,៤៥២នាក់ ស្រី៥៤នាក់ ក្នុងនោះមានភ្ញៀវទេសចរជាតិ ៩៦,៤៤៤នាក់ ស្រី៥៤,០០៧នាក់ និងភ្ញៀវទេសចរអន្តរជាតិ ៨នាក់ ស្រី៣នាក់។
* ខេត្តព្រះសីហនុ ទទួលភ្ញៀវទេសចរសរុប ៨៤.៥៥៧នាក់ ។ក្នុងនោះ ភ្ញៀវជាតិ ៨២.០០១នាក់ និងភ្ញៀវបរទេសសរុប ២.៥៥៦ នាក់។
* ខេត្តកំពង់ចាម មានភ្ញៀវទេសចរសរុបចំនួន ៧៩.៥៧៤ នាក់ ក្នុងនោះមានភ្ញៀវបរទេសចំនួន ២៤៦ នាក់
* ខេត្តកំពត ៧៧,៥៤៨នាក់មានចំនួនសរុប ៧៧៥៤៨នាក់ ក្នុងនោះភ្ញៀវទេសចរណ៍ជាតិមានចំនួន ៧៦ ២៩៦នាក់ និង ភ្ញៀវ អន្តរជាតិផ្ទៃក្នុងមានចំនួន ១២៥២នាក់ ។
* ខេត្តកណ្តាល ៥៤,៥៤៦នាក់
* ខេត្តកំពង់ឆ្នាំង ៥៤,០២៦នាក់សរុបមានចំនួន ៥៤៧០១ នាក់ ក្នុងនោះ ភ្ញៀវបរទេសមានចំនួន ៣៧នាក់ ។
* ខេត្តប៉ៃលិន ៤៩,៧៤៨នាក់។

ឯកឧត្តម **ថោង ខុន** បានបញ្ជាក់ថា តួលេខនេះមានកំណើន៨៩.៤៣% ធៀបនឹងរយៈពេល៣ថ្ងៃនៃពិធីភ្ជុំបិណ្ឌកាលពីឆ្នាំ២០២១ ដោយចរន្តភ្ញៀវនាឱកាសពិធីបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ មានសភាពផុសផុលខ្លាំងធៀបនឹងឆ្នាំ២០២១កន្លងមក ដោយសាររាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការកម្សាន្តនៅគ្រប់រមណីយដ្ឋានទេសចរណ៍ទាំងអស់ ហើយប្រជាពលរដ្ឋអាចទៅធ្វើបុណ្យទាននៅតាមទីវត្តអារាមនានាដោយពុំមានការរឹតត្បិត ខុសពីឆ្នាំ២០២១កន្លងមកដែលប្រជាពលរដ្ឋបានត្រឹមយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅត្រឹមមុខខ្លោងទ្វារចូលវត្តដោយសារវិបត្តិជំងឺកូវីដ-១៩។

លោក **ថោង ខុន** បានបន្តថា ប្រជាពលរដ្ឋបានសម្រុកចូលរាជធានីភ្នំពេញវិញនាល្ងាចថ្ងៃចន្ទ ដែលធ្វើឱ្យចរាចរណ៍នៅតាមដងផ្លូវជាតិនានាមានការមមាញឹកខ្លាំង ខណៈប្រជាពលរដ្ឋខ្លះទៀតនឹងបន្តចូលរាជធានីភ្នំពេញនាថ្ងៃនេះទៀត ពិសេសកម្មករ/កម្មការីដែលទទួលបានច្បាប់ឈប់សម្រាកពី៤-៥ថ្ងៃ។

ចំពោះបញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាពចរាចរណ៍វិញ លោករដ្ឋមន្ត្រី **ថោង ខុន** សង្កេតឃើញថា គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី/ខេត្ត និងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់បានសម្រួលចរាចរណ៍ និងថែរក្សាសន្តិសុខសណ្តាប់ធ្នាប់នៅតាមដងផ្លូវជាតិ និងទីតាំងសំខាន់ៗ។

ដោយឡែក មន្ទីរទេសចរណ៍គ្រប់រាជធានី/ខេត្តក៏បានចុះផ្ទាល់ដល់មូលដ្ឋានអាជីវកម្ម និងគោលដៅទេសចរណ៍សំខាន់ៗ ដើម្បីផ្តល់សេវាកម្មប្រកបដោយគុណភាព តម្លៃសមរម្យ និងបន្តពង្រឹងការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ក្នុងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ពិសេសបញ្ចៀសការកកកុញខ្លាំងដូចដែលធ្លាប់កើតមាននាឆ្នាំកន្លងមក។

លោករដ្ឋមន្ត្រីក្រសួងទេសចរណ៍សន្និដ្ឋានថា សម្រាប់រយៈពេល៣ថ្ងៃនេះ សភាពការណ៍ទេសចរណ៍ជារួម រាប់តាំងពីសន្តិសុខសណ្តាប់ធ្នាប់ និងការដើរកម្សាន្តរបស់ភ្ញៀវទេសចរមានភាពល្អប្រសើរធម្មតា និងមិនមានបញ្ហាធំដុំណាមួយកើតឡើងទេ បើទោះបីបណ្តារាជធានី/ខេត្តភាគច្រើនមានភ្លៀងធ្លាក់ខ្លាំង និងបណ្តាលឱ្យមានជំនន់ទឹកភ្លៀង និងការកកស្ទះនៅតាមតំបន់ និងផ្លូវជាតិសំខាន់ៗមួយចំនួន៕

# ស្ថាបនិកក្រុមហ៊ុន ខ្មែរ យ៉ូរីយូ ជាជនជាតិជប៉ុន ជួយប្រជាកសិករខ្មែរ នៅខេត្តបាត់ដំបងឱ្យមានមុខរបរ និងប្រាក់ចំណូល

*អត្ថបទ៖ កែ ផុស , រូបថត៖ ក្រុមហ៊ុនសុរាខ្មែរ*






ផលិតផលស្រាខ្មែរផលិតពីផ្លែស្វាយ

លោក តាកាយ៉ាម៉ា រីយ៉ូឃិ ជួបសម្តែងការគួរសមជាមួយ ឯកឧត្តម ខៀវ កាញារីទ្ធនិងបង្ហាញផលិតផលស្រាខ្មែរ

ស្ថាបនិកក្រុមហ៊ុន **ខ្មែរ យ៉ូរីយូ** ជាជនជាតិជប៉ុនឈ្មោះ **តាកាយ៉ាម៉ា រីយ៉ូឃិ** ដែលបានជួយដល់ប្រជាកសិករខ្មែរនៅខេត្តបាត់ដំបង ឱ្យមានមុខរបរ និងប្រាក់ចំណូលពីការធ្វើស្រែ និងផលដំណាំ ដែលបានដាំដុះ ដូចជាស្វាយ ខ្នុរ ចេក ជាដើម ដែលពីមុនជាដីចម្ការមីន ។

លោក **តាកាយ៉ាម៉ា រីយ៉ូឃិ** បានឱ្យដឹងពីប្រវត្តិការងាររបស់លោក កាលមកប្រទេសកម្ពុជាលើកដំបូង បានជួយលើកិច្ចការងារដោះមីន ដើម្បីឱ្យប្រជាកសិករ មានដីស្រែធ្វើដាំដុះដំណាំផ្សេងៗ លើផ្ទៃដីដែលបោសសម្អាតគ្រប់មីនរួចរាល់ ។ នៅពេលប្រជាកសិករ ដាំដុះ បានផលដំណាំតែពិបាករកទីផ្សារលក់ដូរ ពេលខ្លះគេបិទច្រកព្រំដែន សម្រាប់នាំចេញ ពេលខ្លះតម្លៃនៃការលក់ធ្លាក់ថ្លៃថោក ធ្វើឱ្យកសិផលរបស់ពួកគាត់ត្រូវ



ផលិតផលដំឡូងមីដែលអាចធ្វើស្រាបាន

រលួយខូចខាត បាត់ទាំងថ្លៃដើមថែមទៀត។

ដោយមើលឃើញពីការលំបាកនេះ លោក **រីយ៉ូឃិ** បានបង្កើតជាសហគមន៍មួយឡើង កាលពីឆ្នាំ២០០៨ ដោយមានការគាំទ្រ និងជួយឧបត្ថម្ភ ពីអ្នកជំនាញ និងមន្ត្រីបច្ចេកទេសពីប្រទេសជប៉ុន ដើម្បីប្រមូលយក កសិផលរបស់ប្រជាកសិករ ដូចជា ចេក ស្វាយ មកចូលរោងចក្រធ្វើការសម្ងួត វេចខ្ចប់ និងផលិតជាស្រា សម្រាប់លក់ ។ បន្ទាប់មក ដោយការងារនេះបានដំណើរការទៅដោយរលូន ទើបលោកបានបង្កើតជាក្រុមហ៊ុន **ខ្មែរ យ៉ូរីយូ** ដែលមានការគ្រប់គ្រងដោយ លោក **ហុខ សុខមាន** ជាជនជាតិខ្មែរ មកដល់បច្ចុប្បន្ននេះ។

ក្នុងការងារដែលបានចូលរួមចំណែកដល់ប្រជាជនកម្ពុជារបស់ជនជាតិជប៉ុនរូបនេះ បានធ្វើឱ្យឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ លោក **តាកាយ៉ាម៉ា រីយ៉ូឃិ** ស្ថាបនិក ក្រុមហ៊ុន **ខ្មែរ យ៉ូរីយូ** ដែលបានខិតខំប្រឹងប្រែងក្នុងការជួយដល់ប្រជាកសិករខ្មែរមួយចំនួន នៅខេត្តបាត់ដំបង ឱ្យមានមុខរបរស្ថិតស្ថេរ និងមានប្រាក់ចំណូលពីការលក់ផលដំណាំ ដែលបានដាំដុះ ដូចជា ស្វាយ ខ្នុរ ចេកជាដើម ។

ការកោតសរសើរ របស់ឯកឧត្តមរដ្ឋមន្ត្រី ក្នុងឱកាសទទួលជួប និងទទួលអំណោយជាផលិតផលរបស់កសិករខ្មែររួមមាន ដំណាប់ចេក ស្វាយសម្ងួត ហើយនិងស្រាខ្នុរ ស្រាចេក ពីលោក **តាកាយ៉ាម៉ា** ប្រធានអង្គការបោសសម្អាតមីន និងអភិវឌ្ឍន៍សហគមន៍អន្តរជាតិ និងជាស្ថាបនិកក្រុមហ៊ុន **ខ្មែរ យ៉ូរីយូ** ដែលមានស្នាក់ការនៅខេត្តបាត់ដំបង នាព្រឹកថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២២ នៅទីស្តីការក្រសួងព័ត៌មានកាលពីពេលកន្លងទៅនេះ។

លោក **តាកាយ៉ាម៉ា រីយ៉ូឃិ** បានឱ្យដឹងថា ការព្យាយាមជំរុញផ្នែកឧស្សាហកម្មថ្នាក់តំបន់ឱ្យប្រសើរឡើងសម្រាប់អភិវឌ្ឍន៍ និងនិរន្តរភាពជីវភាពសហគមន៍ទៅថ្ងៃអនាគត ក្រុមហ៊ុនលោក បានផលិតស្រាស្វាយ និងស្រាខ្នុរ ដ៏ល្អ និងមានរសជាតិយ៉ាងពិសេសប្លែកពីគេ។ ដូច្នេះ អ្វីដែលក្រុមហ៊ុន បន្តប្រឹងប្រែងជួយដល់ប្រជាកសិករខ្មែរ ឱ្យកាន់តែមានជីវភាពល្អប្រសើរបន្ថែមទៀតនោះ គឺការពង្រឹងគុណភាពនូវរាល់ផលិតផលទាំងអស់ រួមទាំងការវេចខ្ចប់ ពិសេសផ្សព្វផ្សាយ ម៉ាកស្រាដែលមានគុណភាពល្អនេះ ដើម្បីលក់ទៅកាន់ទីផ្សារអន្តរជាតិ ។

លោក **ហុខ សុខមាន** បានបន្ថែមថា បច្ចុប្បន្ននេះ ក្រុមហ៊ុន **ខ្មែរ យ៉ូរីយូ** បានផលិតស្រាសដែលមានគុណភាពល្អ



ហាងលក់ស្រាខ្មែរដែលផលិតពីផ្លែឈើ និងដំឡូងមី



ឯកឧត្តម ខៀវ កាញារីទ្ធ ទទួលជួបពិភាក្សាជាមួយលោក តាកាយ៉ាម៉ា រីយ៉ូយិ

ឈ្មោះថា«សុរាខ្មែរ» ដោយក្នុងចំណោមស្រាទាំងនោះ មានស្រាខ្មុរ ស្រាស្វាយ ដែលបាននាំយកទៅលក់នៅប្រទេសប៉ុន ដែលស្រាទាំងនេះត្រូវបានផលិតឡើងនៅលើទឹកដី សន្តិភាព ដែលពីមុនជាចម្ការមីន ។

ឯកឧត្តម **ខៀវ កាញារីទ្ធ** ក៏បានទទួលស្គាល់នូវការផលិតស្រាស ដែលថ្លាល្អ ហើយមានគុណភាពផលិតដោយលោក **រីយ៉ូយិ** កាលពីជាង ១០ឆ្នាំមុន ហើយឥឡូវ ក៏បានផលិតជាស្រា ខ្មុរ និង ស្រាចេក ដែលកាន់តែមានរសជាតិ និងគុណភាពខ្ពស់ ។ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងថា នឹងជួយធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ អំពីផលិតផលរបស់ក្រុមហ៊ុន ខ្មែរ យ៉ូរីយូ ដែលបានផលិតឡើង ប្រកបដោយគុណភាព និងស្តង់ដារខ្ពស់ ។

ឯកឧត្តមរដ្ឋមន្ត្រីក៏បានលើកឡើងដែរថា នឹងគោរពស្នើសុំទៅប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់ជូននូវមេដាយកិត្តិយសជូនដល់លោក **តាកាយ៉ាម៉ា រីយ៉ូយិ** ដែលបានជួយដល់ប្រជាកសិករខ្មែរមួយចំនួនក្នុងខេត្តបាត់ដំបង ឱ្យមានការងារធ្វើ និងប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃកាន់តែប្រសើរឡើង។

សូមបញ្ជាក់ថាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាជ្ញាធរមីន បានសម្រេចបង្កើត "គម្រោងសម្តេចតេជោសម្រាប់សកម្មភាពមីន -- Samdech Techo Project for Mine Action_STP - MA" ក្រោមមូលបទ "ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម -- Providing Safe Ground, Creating Smiles" ក្រោមការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលដោយអាជ្ញាធរមីន ដែលមានសម្តេចតេជោ ជាប្រធាន ដែលគម្រោងនេះ បានកើតចេញពីការអំពាវនាវរបស់សម្តេចតេជោ **ហ៊ុន សែន** កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ ក្នុងទិវាមច្ឆជាតិ នៅតំបន់អាងទឹកត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ និងជាថ្ងៃដ៏អស្ចារ្យមួយសម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលការបោសសម្អាតមីន មានការចូលរួមគាំទ្រយ៉ាងផុសផុលពីកាកបាទក្រហមកម្ពុជា វិស័យឯកជន និងសប្បុរសជន ក្រោមការដឹកនាំប្រកបដោយកិត្តិបណ្ឌិតរបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី។



លោក ហុង សុខមាន បង្ហាញផលិតផលស្រាខ្មែរ



# ពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ឆ្នាំ២០២២ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោកជំទាវ ទទួលកាន់វេនបិណ្ឌចំនួន ៣វត្ត ក្នុងរាជធានីភ្នំពេញ

អត្ថបទនិងរូបថត៖ ស្រី សាម៉ាន



ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងលោកជំទាវទទួលកាន់វេនបិណ្ឌចំនួន០៣វត្ត ក្នុងរាជធានីភ្នំពេញ នៃពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនាឆ្នាំ២០២២ រួមជាមួយ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ មន្ត្រីជការ នៅក្នុងក្រសួងព័ត៌មាន តែងតែអញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌគឺ បិណ្ឌវេនទី១នៅវត្តពិភទ្ធរង្សី(ហៅ ចិនដំដែកខាងជើង) ក្នុងសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ វេនបិណ្ឌទី៧ នៅវត្តលង្កាព្រះកុសុមារាម ស្ថិតនៅក្នុងសង្កាត់បឹងកេងកង១





ឯកឧត្តម ខៀវ កាញារីទ្ធ និងលោកជំទាវ អញ្ជើញចូលរួមសូត្រមន្តសមាទានសីល នៃពីធីកាន់វេនបិណ្ឌ





ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងវេនបិណ្ឌទី១១ នៅវត្តមង្គលវ៉ន ( ហៅវត្តស្វាយដង្គុំ )រាជធានីភ្នំពេញ។

បុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យដ៏ធំមួយក្នុងចំណោមបុណ្យផ្សេងៗទៀតតាមបវេណីព្រះពុទ្ធសាសនា ពិសេសចំពោះអ្នកកាន់សាសនាព្រះពុទ្ធ។ ដោយឡែកសម្រាប់ឆ្នាំ២០២២នេះពិធីកាន់បិណ្ឌនិងពិធីបុណ្យភ្ជុំបិណ្ឌបានចាប់ផ្ដើមពីថ្ងៃ១រោច ខែភទ្របទ ដល់ ថ្ងៃ១៤រោច ខែភទ្របទ ត្រូវនឹងថ្ងៃអាទិត្យទី១១ ខែកញ្ញា ដល់ ថ្ងៃសៅរ៍ ទី២៤ ខែកញ្ញា ឆ្នាំ២០២២ ជាថ្ងៃកាន់បិណ្ឌ លុះដល់ថ្ងៃ១៥ រោច ត្រូវនឹងថ្ងៃអាទិត្យទី២៥ខែកញ្ញា ឆ្នាំ២០២២ ជាថ្ងៃភ្ជុំបិណ្ឌធំ។ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌឆ្នាំ២០២២នេះដែររាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យមន្ត្រីរាជការ កម្មករ និយោជិត បានឈប់សម្រាកចាប់ពីថ្ងៃទី២៤ ដល់ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២២ ដើម្បីចូលរួមប្រារព្ធពិធីបុណ្យសាសនាដ៏ធំមួយនេះនិងជួបជុំក្រុមគ្រួសារនៅឯស្រុកកំណើត។

ដោយអនុវត្តតាមប្រសាសន៍សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ដើម្បីជួយសម្រួលបន្ទុកចំណាយរបស់បងប្អូនប្រជាពលរដ្ឋជាមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករ កម្មការិនី សិស្ស និស្សិត ដែលធ្វើដំណើរទៅលេងស្រុកកំណើតជួបជុំបងប្អូនក្រុមគ្រួសារប្រកបដោយសេចក្ដីសប្បាយរីករាយក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌនេះ រដ្ឋបាលរាជធានីភ្នំពេញបានរៀបចំរថយន្តក្រុងចំនួន១៧៥គ្រឿង សម្រាប់បម្រើសេវាដឹកជញ្ជូនសាធារណៈរយៈពេល៥ថ្ងៃក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ចាប់ពីថ្ងៃទី២៣ ខែកញ្ញា ដល់ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ដោយពុំបង់ប្រាក់ឡើយ។

លោកជំទាវ **ខៀវទេព រង្សីកាញារីទ្ធ** មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ និងជាប្រធានកិត្តិយសសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងព័ត៌មាន តំណាងឯកឧត្តម **ខៀវ កាញារីទ្ធ** រួមជាមួយ ឯកឧត្តម លោកជំទាវ រដ្ឋលេខា-



ថ្នាក់ដឹកនាំមន្ត្រីរាជការ អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ

ធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ថ្នាក់ដឹកនាំមន្ត្រីរាជការ ទីប្រឹក្សា បានប្រារព្ធពិធីសូត្រមន្តសមាទានសីល និមន្តព្រះសង្ឃចម្រើនព្រះបរិត្ត និងសម្តែងធម្មទេសនាទាក់ទងទៅនឹងពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ ដែលជាពិធីបុណ្យមួយត្រូវបានពុទ្ធបរិស័ទខ្មែរទូទាំងប្រទេសប្រារព្ធធ្វើជារៀងរាល់ឆ្នាំក្នុងជំនឿយ៉ាងមុតមាំលើទស្សនៈកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ បន្ទាប់មកបានប្រគេនយាគូនិងភត្តាហារ ព្រមទាំងនិមន្តព្រះសង្ឃជាបង្សុកូលឆ្លង ដើម្បីជាកិច្ចឧទ្ទិសកុសលជូនដល់ញាតិការទាំង៧សន្តានដែលបានចែកឋានទៅកាន់លោកខាងមុខសូមបានសុខក្នុងគតិភពជារៀងរហូត។ សម្រាប់វេនកាន់បិណ្ឌទី១ នេះដែរឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងព័ត៌មាន បានប្រមូលបច្ច័យសម្រាប់កសាងក្នុងវត្តពិភទ្ធរង្សី (ហៅចិនដំដែកខាងជើង) សម្រាប់កសាងវត្តមានចំនួន២លានរៀល ប្រគេនចៅអធិការវត្តចំនួន២០០ដុល្លារ និង១៥ម៉ឺនរៀល ប្រគេនព្រះគ្រូសូត្រឆ្វេងស្តាំ ក្នុងមួយអង្គ១០០ដុល្លារ ព្រះសង្ឃស្វាធ្យាយចំនួន៩អង្គ ក្នុងមួយអង្គ៩ម៉ឺនរៀល ប្រគេនព្រះសង្ឃគង់នៅក្នុង



លោកជំទាវ ខៀវទេព រង្សីកាញារីទ្ធ អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ



*លោកជំទាវ ខៀវទេព រស្មីភាញារិទ្ធ អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ*







វត្តចំនួន ២៧អង្គ មួយអង្គ២ម៉ឺនរៀល បច្ច័យធ្វើចង្ហាន់ព្រះសង្ឃពីរពេលចំនួន ៣លានរៀល ប្រគេនសាដកព្រះសង្ឃ ៣៩អង្គ ប្រគេនទឹកសុទ្ធចំនួន ២០យួរ,មីជាតិ ១០កេស, បច្ច័យជូនអាចារ្យធំ ១៨ម៉ឺនរៀល ជូនគណៈកម្មការវត្ត១២នាក់ ក្នុង១នាក់ទទួលបានថវិកា២ម៉ឺនរៀល ជូនយាយជី៥នាក់ក្នុងម្នាក់ៗ២ម៉ឺនរៀល ឧបត្ថម្ភសិស្ស និស្សិតស្នាក់នៅរៀនសូត្រចំនួន៤៥នាក់ ក្នុងម្នាក់ៗ១ម៉ឺនរៀល។

សម្រាប់វេនបិណ្ឌទី៧ ឯកឧត្តម **ខៀវ ភាញារិទ្ធ** និង លោកជំទាវ **ខៀវទេព រស្មីភាញារិទ្ធ** ព្រមទាំងក្រុមគ្រួសារ រួមជាមួយឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ មន្ត្រីរាជការ ក្រសួងព័ត៌មាន ពុទ្ធបរិស័ទចំណុះជើងវត្តជិតឆ្ងាយបានអញ្ជើញចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី៧នៅវត្តលង្ការព្រះកុសុមារាម នៅថ្ងៃ៦រោច ខែភទ្របទ ឆ្នាំខាលចត្វាស័ក.ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២២ មានធ្វើពិធីសូត្រមន្តសមាទានសិលនិមន្តព្រះសង្ឃចម្រើនព្រះបរិត្តនិងសម្ដែងធម្មទេសនាទាក់ទងទៅនឹងពិធីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ ដែលពិធីនេះត្រូវបានពុទ្ធបរិស័ទខ្មែរ នៅទូទាំងប្រទេសធ្វើជារៀងរាល់ឆ្នាំ។ លុះព្រឹកថ្ងៃ៧ រោចត្រូវនឹងថ្ងៃសៅរ៍ទី១៧ ខែកញ្ញា ឆ្នាំ២០២២ ដដែល ឯកឧត្តម **ខៀវ ភាញារិទ្ធ** និង លោកជំទាវ **ខៀវទេព រស្មីភាញារិទ្ធ** ព្រមទាំងក្រុមគ្រួសារឯកឧត្តម លោកជំទាវ រដ្ឋលេខាធិកា អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃក្រសួងព័ត៌មានបានអញ្ជើញបូជាទៀនធូប ផ្កាភ្ញី ថ្វាយព្រះរតនត្រ័យនិងនាំយកនូវគ្រឿងឧបភោគ



ថ្នាក់ដឹកនាំមន្ត្រីរាជការ អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ





បរិភោគ ចង្ហាន់ បិណ្ឌបាត និងបច្ច័យប្រគេនយាគូព្រះសង្ឃ និងវេរភត្តាហារដល់ព្រះសង្ឃ ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធជីដូន ជីតា បុព្វការីជន ញាតិការទាំង ៧សន្តាន ព្រមទាំងឯកឧត្តម **ម៉ៅ អាយុទ្ធ** រដ្ឋលេខាធិការក្រសួងព័ត៌មាន ដែលបានចែកឋានទៅកាន់បរលោក។

នាឱកាសបុណ្យកាន់បិណ្ឌវេនទី៧នេះដែរ ឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** និងលោកជំទាវ ព្រមទាំងគ្រួសារ ជាកូនជាចៅ របស់មហាឧបាសក **ខៀវ ថន** ឧបាសិកា **ឡោ លាងហ៊ីន** លោកយាយកុសលចិត្តាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ **ពេន យុត** រួមជាមួយឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំមន្ត្រីរាជការក្រសួងព័ត៌មានបានប្រមូលបច្ច័យចូលរួមកសាងសមិទ្ធផល ក្នុងវត្តលង្កាព្រះកុសុមារាម សរុបបច្ច័យចំនួន៦លាន១សែន៨ម៉ឺនរៀល និង១ ០៦០ដុល្លារ។ ឯកឧត្តម **ខៀវ កាញារីទ្ធ** និងលោកជំទាវបានប្រគេនបច្ច័យដល់ព្រះចៅអធិការវត្តចំនួន ៣០០ដុល្លារ លោកគ្រូសូត្រឆ្វេងស្តាំក្នុងមួយអង្គ១០០ដុល្លារ,បច្ច័យប្រគេនព្រះសង្ឃស្វាធ្យាយ ៧២ម៉ឺនរៀល,បូជាព្រះធម៌ទេសនាពេលល្ងាច៥០ម៉ឺនរៀល, ប្រគេនបច្ច័យបួន ដល់ព្រះសង្ឃចំនួន៣លាន ៣សែន ៨ម៉ឺនរៀល,បច្ច័យសម្រាប់ចង្ហាន់លោកពីពេលចំនួន ៤លានរៀល ប្រគេនអង្ករចំនួន ១ពាន់គីឡូក្រាម, ទឹកសុទ្ធ ២០កេស, មីជាតិ ២០កេស, ជូនថវិកាដល់តាជី យាយជី ៤០នាក់ម្នាក់ៗ ១ម៉ឺនរៀល, ភ្លេងបុរាណ ១សែនរៀល,និស្សិត សិស្សស្នាក់នៅរៀនសូត្រក្នុងទីអារាមវត្តលង្កាព្រះកុសុមារាម៥០នាក់ ក្នុងម្នាក់ៗ១ម៉ឺនរៀល, ចំណាយលើបាយបត្តបូរ ២លាន ៤សែនរៀល ផងដែរ។

សម្រាប់វេនកាន់បិណ្ឌទី១១ នៅវត្តមង្គលវ៉ន(ហៅវត្តស្វាយដង្គុំ) លោកជំទាវ **ខៀវទេព រង្សីកាញារីទ្ធ** ត្រូវជាកូនបង្កើតលោកយាយកុសលចិន្តាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ **ពេន យុត** ប្រធានសីលវត្តីវត្តមង្គលវ៉ន ហៅវត្តស្វាយដង្គុំ ព្រមទាំងក្រុមគ្រួសារថ្នាក់ដឹកនាំមន្ត្រីរាជការ នៃក្រសួងព័ត៌មាន បាននាំយកបច្ច័យនិងទេយ្យទានដូចជា សាដក១០, អង្ករ ៥០០ គីឡូក្រាមស្មើនឹង១០បាវ, ទឹកសុទ្ធ ២៨យួរ, មីជាតិ ១០កេស, ប្រគេនបច្ច័យសម្តេចចៅអធិការវត្ត ៣០០ដុល្លារ, ព្រះគ្រូវិន័យធម៌



ឯកឧត្តម ខៀវ កាញារីទ្ធ និងលោកជំទាវ ថតរូបអនុស្សាវរីយ៍ក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ

ចំនួន ១០០ដុល្លារ, ព្រះគ្រូសូត្រឆ្វេងស្តាំក្នុង១អង្គ ១០០ដុល្លារ, ព្រះសង្ឃស្វាធ្យាយ ៩អង្គ ចំនួន ៤៥ម៉ឺនរៀល, បូជាព្រះធម៌ ៥០ម៉ឺនរៀល, ប្រគេនបច្ច័យ៤ដល់ព្រះសង្ឃ ៣២អង្គ ចំនួន ៦៤ម៉ឺនរៀល,បច្ច័យសម្រាប់ធ្វើចង្ហាន់និងបាយបត្តបូរចំនួន ៣លានរៀល, បច្ច័យកសាងចំនួន២លានរៀល,ជូនតាអាចារ្យធំ ៥ម៉ឺនរៀល, ជូនតាជី យាយជី ៤០នាក់ ចំនួន ៤០ម៉ឺនរៀល, ចុងភៅ ១០នាក់ ១០ ម៉ឺនរៀល ។ សរុបបច្ច័យ និងទេយ្យទានក្នុងវេនកាន់បិណ្ឌទី១១ មានបច្ច័យសរុបជាប្រាក់ដុល្លារ ១ ០៩០ដុល្លារ និងប្រាក់រៀល ចំនួន ១៦លាន ២១ម៉ឺនរៀល។



ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងព័ត៌មានថតរូបអនុស្សាវរីយ៍ក្នុងពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

**<u>បញ្ជីរាយនាម</u>**

**ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងព័ត៌មាន ដែលបានចាប់មគ្គផល**

**ក្នុងពិធីវេនកាន់បិណ្ឌទី១ នៅវត្តពិភពទួលខ្សឺ (វត្តចិនដំដែកខាងជើង)**

ថ្ងៃអាទិត្យ ១រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២

| ល.រ | នាម និងគោត្តនាម | អង្គភាព/តួនាទី | ប្រាក់រៀល | ប្រាក់ដុល្លារ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ឯកឧត្តម **ខៀវ កាញារីទ្ធ និងលោកជំទាវ** | រដ្ឋមន្ត្រី | 4,000,000៛ | 400$ | |
| ២ | ឯកឧត្តម **ថាច់ ផែន** | រដ្ឋលេខាធិការ | 100,000៛ | | |
| ៣ | ឯ.ឧ **ឡុង សេង** និងលោកជំទាវ **លី ប៊ុនសៃ** | អនុរដ្ឋលេខាធិការ | 200,000៛ | | |
| ៤ | ឯកឧត្តម លី វ៉ាន់ហុង | ប្រតិភូរាជរដ្ឋាភិបាល-អគ្គនាយក | | 100$ | |
| ៥ | ឯកឧត្តម ស៊ូនី វង្សវិសិដ្ឋ | រដ្ឋលេខាធិការ | 1,000,000៛ | | |
| ៦ | អគ្គនាយិកាវិទ្យុជាតិកម្ពុជា | | 2,000,000៛ | | |
| ៧ | លោកជំទាវ សន ម៉ារ៉ាដា | រដ្ឋលេខាធិការ | | 200$ | |
| ៨ | ឯកឧត្តម អ៊ុក សំរេច និងលោកជំទាវ | រដ្ឋលេខាធិការ | | 100$ | |
| ៩ | ឯកឧត្តម តូច សារ៉េត | រដ្ឋលេខាធិការ | 250,000៛ | | |
| ១០ | ឯកឧត្តម ហ៊ុយ សារ៉ាវុធ និងលោកជំទាវ | រដ្ឋលេខាធិការ | 100,000៛ | | |
| ១១ | ឯកឧត្តម តន់ យ៉ាន និងលោកជំទាវ | រដ្ឋលេខាធិការ | 200,000៛ | | |
| ១២ | ឯកឧត្តម ហោ សុភាព | រដ្ឋលេខាធិការ | 100,000៛ | | |
| ១៣ | ឯ.ឧ គឹម គុណវឌ្ឍន៍ និងលោកជំទាវ | រដ្ឋលេខាធិការ | | 40$ | |
| ១៤ | ឯកឧត្តម ងឿន ច័ន្ទលីនប៉ូឡែន | អនុរដ្ឋលេខាធិការ | | 100$ | |
| ១៥ | លោកជំទាវ ជា ស៊ុនដាណែត | អនុរដ្ឋលេខាធិការ | 200,000៛ | | |
| ១៦ | លោកជំទាវ ឡុងឌី សាន់ណារ៉ា | អនុរដ្ឋលេខាធិការ | 200,000៛ | | |
| ១៧ | លោកជំទាវ សរ គឹមលី | អនុរដ្ឋលេខាធិការ | 200,000៛ | | |
| ១៨ | ឯកឧត្តម ហាស់ សំអាត និងលោកជំទាវ | អនុរដ្ឋលេខាធិការ | 150,000៛ | | |
| ១៩ | ឯកឧត្តម ឃួន វិចិត្រ | អនុរដ្ឋលេខាធិការ | 100,000៛ | | |
| ២០ | ឯកឧត្តម សំបូរ វណ្ណារិទ្ធ និងលោកជំទាវ | អនុរដ្ឋលេខាធិការ | 150,000៛ | | |
| ២១ | ឯកឧត្តម ឆាយ សុផល និងលោកជំទាវ | អនុរដ្ឋលេខាធិការ | 200,000៛ | | |

| | | | | | |
|---|---|---|---|---|---|
| ២២ | ឯកឧត្តម អ៊ុក គីមសេង និងលោកជំទាវ | អនុរដ្ឋលេខាធិការ | 100,000៛ | | |
| ២៣ | ឯកឧត្តម រស់ ថាន់សន និងលោកជំទាវ | អនុរដ្ឋលេខាធិការ | 100,000៛ | | |
| ២៤ | ឯ.ឧ ផុស សុវណ្ណ និងលោកជំទាវ អ៊ុក មករា | ប្រតិភូរាជរដ្ឋាភិបាល-អគ្គនាយក | 100,000៛ | | |
| ២៥ | ឯកឧត្តម ចាន់ សុភាព | អនុរដ្ឋលេខាធិការ | | 50$ | |
| ២៦ | ឯកឧត្តម ខឹម បូរ៉ាណា និងលោកជំទាវ | ទីប្រឹក្សា-អគ្គនាយករង | 100,000៛ | | |
| ២៧ | លោក ខឹម សុវណ្ណារ៉ា និងលោកស្រី | អនុប្រធាននាយកដ្ឋាន | 50,000៛ | | |
| ២៨ | លោក នូ ចាន់រី និងលោកស្រី | អនុប្រធាននាយកដ្ឋាន | 50,000៛ | | |
| ២៩ | លោក ឌី ណារិន និងលោកស្រី | អនុប្រធាននាយកដ្ឋាន | 50,000៛ | | |
| ៣០ | លោកជំទាវ ឆន ណារី | ទីប្រឹក្សា-អគ្គនាយករង | 100,000៛ | | |
| ៣១ | លោកស្រី សុខ សីហា និងស្វាមី | អនុប្រធាននាយកដ្ឋាន | 40,000៛ | | |
| ៣២ | លោក ពៅ រតនៈ | ទីប្រឹក្សា | 50,000៛ | | |
| ៣៣ | ឯកឧត្តម ឆ្លម សេងហួរ និងលោកជំទាវ | ទីប្រឹក្សា | 100,000៛ | | |
| ៣៤ | ឯកឧត្តម ណុប ម៉ូយ និងលោកជំទាវ | ទីប្រឹក្សា-ប្រធានអង្គភាពលទ្ធកម្ម | 100,000៛ | | |
| ៣៥ | ឯកឧត្តម អ៊ុំ ឫទ្ធី និងលោកជំទាវ | ទីប្រឹក្សា-អគ្គនាយករង | 500,000៛ | | |
| ៣៦ | ឯកឧត្តម សាត សុផល និងលោកជំទាវ | ទីប្រឹក្សា-អគ្គនាយករង | | 20$ | |
| ៣៧ | នាយកដ្ឋានរដ្ឋបាលទូទៅ | | 500,000៛ | | |
| ៣៨ | នាយកដ្ឋានគ្រប់គ្រងសម្ភារៈនិងទ្រព្យរដ្ឋ | | 400,000៛ | | |
| ៣៩ | អគ្គនាយកដ្ឋានAKP | | 200,000៛ | | |
| ៤០ | លោក សរ ពិសិដ្ឋ | ទីប្រឹក្សា | 50,000៛ | | |
| ៤១ | ឯកឧត្តម ស៊ន់ គីមឈន់ | ទីប្រឹក្សា | 50,000៛ | | |
| ៤២ | ឯកឧត្តម ម៉េង សុខអាន និងលោកជំទាវ | ទីប្រឹក្សា | 100,000៛ | | |
| ៤៣ | ឯកឧត្តម ប៊ូ វណ្ណារិទ្ធ និងលោកជំទាវ | ទីប្រឹក្សា | | 20$ | |
| ៤៤ | លោក ខាត់ សុគន្ធឌីណា និងភរិយា | ប្រធានមន្ទីរសម្របសម្រួល រាជធានី-ខេត្ត | 100,000៛ | | |
| ៤៥ | អធិការដ្ឋាន | | 400,000៛ | | |
| ៤៦ | ឯកឧត្តម លន់ ហួរ និងលោកជំទាវ | ទីប្រឹក្សា-ប្រធាននាយកដ្ឋាន | 200,000៛ | | |
| ៤៧ | ឯកឧត្តម ខឹម បូរិន និងលោកជំទាវ | ទីប្រឹក្សា | | 20$ | |
| ៤៨ | ឯកឧត្តម សន រដ្ឋា | ទីប្រឹក្សា | 100,000៛ | | |
| ៤៩ | ឯកឧត្តម តូច សុភាព | ទីប្រឹក្សា | | 20$ | |
| ៥០ | លោក ព្រហ្ម សំអឿន | ទីប្រឹក្សា | 50,000៛ | | |

| | | | | | |
|---|---|---|---|---|---|
| ៥១ | ឯកឧត្តម ពៅ ពិសិទ្ធ | ទីប្រឹក្សា | 200,000៛ | | |
| ៥២ | លោក ប្រុក សារ៉ាវុធ | ទីប្រឹក្សា | | 20$ | |
| ៥៣ | នាយកដ្ឋានសនវកម្មផ្ទៃក្នុង | | 200,000៛ | | |
| ៥៤ | លោក ឡេា ចាន់នី និងភរិយា | នាយកមណ្ឌលបណ្ដុះបណ្ដាល | 100,000៛ | | |
| ៥៥ | លោក គឹង ពុធតារា | អនុប្រធាននាយកដ្ឋាន | 100,000៛ | | |
| ៥៦ | ឯកឧត្តម នៅ សុភ័ក្ស និងលោកជំទាវ | ទីប្រឹក្សា | 100,000៛ | | |
| ៥៧ | នាយកដ្ឋានបុគ្គលិក | | 400,000៛ | | |
| ៥៨ | ឯកឧត្តម តូច ណារ័ត្ន និងលោកជំទាវ | ទីប្រឹក្សា-អគ្គនាយករង | | 50$ | |
| ៥៩ | លោក ប៉ិច សុទ្ធាវិទ្ធ | មន្ត្រីវិទ្យុជាតិFM96 | 40,000៛ | | |
| ៦០ | កញ្ញា លី ឈុនមុី | មន្ត្រីវិទ្យុជាតិFM96 | 40,000៛ | | |
| ៦១ | លោក ស៊ុំ វឌ្ឍនៈ | មន្ត្រីវិទ្យុជាតិFM96 | 80,000៛ | | |
| ៦២ | លោក ពាន់ សុភត្រា | មន្ត្រីវិទ្យុជាតិFM96 | 40,000៛ | | |
| ៦៣ | លោកស្រី សយ លក្ខិណា | មន្ត្រីវិទ្យុជាតិFM96 | 50,000៛ | | |
| ៦៤ | លោក ម៉ែន សុភី | មន្ត្រីវិទ្យុជាតិFM96 | 50,000៛ | | |
| ៦៥ | លោក ប៉ូ សុវណ្ណមុនីរិទ្ធី | មន្ត្រីវិទ្យុជាតិFM96 | 40,000៛ | | |
| ៦៦ | កញ្ញា ប៊ុន គីមអ៊ី | មន្ត្រីវិទ្យុជាតិFM96 | 50,000៛ | | |
| ៦៧ | លោក រិន ឆេងលី | មន្ត្រីវិទ្យុជាតិFM96 | 40,000៛ | | |
| ៦៨ | ឯកឧត្តម ទេព វណ្ណៈ | ទីប្រឹក្សា | | 20$ | |
| ៦៩ | ឯកឧត្តម មាស រដ្ឋាវុឌ្ឍ | ទីប្រឹក្សា | 100,000៛ | | |
| ៧០ | លោកជំទាវ ខៀវ គឹមហ៊ាន | ទីប្រឹក្សា | 100,000៛ | | |
| ៧១ | លោកស្រី ដួង សារី | មន្ត្រី | 20,000៛ | | |
| ៧២ | លោក សៀង មុន្នី | អនុប្រធាននាយកដ្ឋាន | 20,000៛ | | |
| ៧៣ | លោក នួន ឬទ្ធីយ៉ា | អនុប្រធាននាយកដ្ឋាន | 20,000៛ | | |
| ៧៤ | លោក គុយ ស៊ីធឿន | អនុប្រ.ការិយាល័យ | 20,000៛ | | |
| ៧៥ | លោក ចាន់ ប៊ុនថន | ប្រធានការិយាល័យ | 20,000៛ | | |
| ៧៦ | លោក កេង លាង | អនុប្រធាននាយកដ្ឋាន | 20,000៛ | | |
| ៧៧ | លោក ផន រតនា | អនុប្រធាននាយកដ្ឋាន | 20,000៛ | | |
| ៧៨ | ឯកឧត្តម ឃុត សំខាន់ | ទីប្រឹក្សា-ប្រធានមន្ទីរព័ត៌មាន | 200,000៛ | | |
| ៧៩ | លោក ញ៉ែម សៅគ្រី | ប្រធានមន្ទីរព័ត៌មាន | 200,000៛ | | |
| ៨០ | លោក ង៉ាន់ស៊ីណា | ទីប្រឹក្សា | 50,000៛ | | |

| | | | | | |
|---|---|---|---|---|---|
| ៨១ | លោកជំទាវ អ៊ឹម សុភាព ម៉ៅ វិបុល | ទីប្រឹក្សា | 800,000៛ | | |
| ៨២ | លោកជំទាវ នីន សុខា | ទីប្រឹក្សា | 160,000៛ | | |
| ៨៣ | លោកជំទាវ ប្រាក់ អេលីរតនា | ទីប្រឹក្សា | 100,000៛ | | |
| ៨៤ | លោកជំទាវ យួន កូវីសុខា | ទីប្រឹក្សា | | 20$ | |
| ៨៥ | ឯកឧត្តម ប៉ាង ណាត និងលោកជំទាវ | ទីប្រឹក្សា | 100,000៛ | | |
| ៨៦ | លោកជំទាវ រស់ សុជាត ព្រមទាំងបុត្រ | ទីប្រឹក្សា | 100,000៛ | | |
| ៨៧ | លោកជំទាវ វ៉ាយ សុភាព | ទីប្រឹក្សា | 50,000៛ | | |
| ៨៨ | លោកស្រី ឥន្ទ តាវ៉ានី | ទីប្រឹក្សា | 50,000៛ | | |
| ៨៩ | លោកស្រី ស៊ុម សុធារិទ្ធ | សមាគមនារី | 50,000៛ | | |
| ៩០ | លោកស្រី ធឿន ដាលីន | ពុទ្ធបរិស័ទ | 20,000៛ | | |
| ៩១ | លោកស្រី ចេង ប៉ោឡាំង | ពុទ្ធបរិស័ទ | 20,000៛ | | |
| ៩២ | លោកស្រី ណុប យសធីតា | ពុទ្ធបរិស័ទ | 10,000៛ | | |
| ៩៣ | លោកយាយ សាយ សៀត | ពុទ្ធបរិស័ទ | 10,000៛ | | |
| ៩៤ | លោកស្រី កែវ ចន្ទី | ពុទ្ធបរិស័ទ | 20,000៛ | | |
| ៩៥ | លោកស្រី ហ៊ាង | ពុទ្ធបរិស័ទ | 20,000៛ | | |
| ៩៦ | លោកយាយ យូ គាង | ពុទ្ធបរិស័ទ | 5,000៛ | | |
| ៩៧ | លោកស្រី អុល សុផល | ពុទ្ធបរិស័ទ | 5,000៛ | | |
| ៩៨ | លោកស្រី រ័ត្ន វ៉ាន់ថា ព្រមទាំងបុត្រ | ពុទ្ធបរិស័ទ | 10,000៛ | | |
| ៩៩ | លោកស្រី សូ វ៉ុន | ពុទ្ធបរិស័ទ | 5,000៛ | | |
| ១០០ | លោកស្រី សេង ស្រីនុច | ពុទ្ធបរិស័ទ | 5,000៛ | | |
| ១០១ | លោកយាយ កែម រ៉ា | ពុទ្ធបរិស័ទ | 10,000៛ | | |
| **សរុបបច្ច័យ** | | | **16,610,000៛** | **1,180$** | |

ថ្ងៃអាទិត្យ ១រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០២២
**អ្នកទទួលបច្ច័យ**

**ខឹម ប៉ូណា**

ថ្ងៃអាទិត្យ ១រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២២
**អនុរដ្ឋលេខាធិការ**

**ប្រធានគណៈកម្មការកាន់ទេនបិណ្ឌទី១**

**ឡុង សេង**

# បញ្ជីរាយនាមសប្បុរសជន ចូលរួមបច្ច័យកាន់បិណ្ឌទី ៧
# ពិធីបុណ្យភ្ជុំបិណ្ឌ នៅវត្តលង្ការព្រះកុសុមារាម
# ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០២២

| ល.រ | នាម និងគោត្តនាម | | ថវិកា | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | រៀល | ដុល្លារ | |
| ១ | ឯកឧត្តម | ខៀវ កាញារីទ្ធ និង លោកជំទាវ ទេព រង្សី | 17,820,000៛ | $ 710 | |
| ២ | | ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងព័ត៌មាន | 2,000,000៛ | | |
| ៣ | លោកជំទាវ | Mey ( Son ) | | $ 450 | |
| ៤ | លោកជំទាវ | ម៉ែន សៀង សុខ ចំរើន | | $ 250 | |
| ៥ | | សាច់ញាតិឯកឧត្តមរដ្ឋមន្ត្រី | 4,000,000៛ | | |
| ៦ | ឯកឧត្តម | លី វ៉ាន់ហុង | 500,000៛ | | |
| ៧ | លោកជំទាវ | អ៊ឹម សុភាព ម៉ៅ វិបុល | | $ 100 | |
| ៨ | ឯកឧត្តម | ឱន់ សារ៉ាត និងលោកជំទាវ | | $ 100 | |
| ៩ | លោកជំទាវ | ឈឹមពៅ សុភាន់ឌី | | $ 100 | |
| ១០ | លោកជំទាវ | ទី ម៉ារ៉ា | | $ 50 | |
| ១១ | លោកជំទាវ | សរ គឹមលី | 200,000៛ | | |
| ១២ | ឯកឧត្តម | សុខ ចាន់តក្កី | 200,000៛ | | |
| ១៣ | លោកជំទាវ | ឡុងឌី សាន់ណារ៉ា | 200,000៛ | | |
| ១៤ | លោកជំទាវ | លឹម មុំ | 200,000៛ | | |
| ១៥ | លោកជំទាវ | ឈឹម គារ៉ែនណា | 200,000៛ | | |
| ១៦ | លោកជំទាវ | សេង មួយគាង | | $ 40 | |
| ១៧ | ឯកឧត្តម | ហេង សទ្ធា | 150,000៛ | | |
| ១៨ | លោកជំទាវ | នង ឆ្នូក | 150,000៛ | | |
| ១៩ | លោកជំទាវ | នីន សុខា | 120,000៛ | | |
| ២០ | លោកជំទាវ | ជា ស៊ុនដាណែត | 120,000៛ | | |
| ២១ | លោកជំទាវ | ស្រ៊ី ចាន់អេង | 100,000៛ | | |
| ២២ | ឯកឧត្តម | ហ៊ុយ សារ៉ាវុធ | 100,000៛ | | |
| ២៣ | ឯកឧត្តម | រស់ ចាន់សន និង លោកជំទាវ | 100,000៛ | | |
| ២៤ | | ស៊ុំ សារិទ្ធិ ( ក្មួយសុភក្រ្តឡា ) | 100,000៛ | | |
| ២៥ | ឯកឧត្តម | ណុប ម៉ូយ | 100,000៛ | | |
| ២៦ | លោកជំទាវ | ហ៊ីង រ៉េត | 100,000៛ | | |

| | | | | |
|---|---|---|---|---|
| ២៧ | លោកជំទាវ **ម៉ី ស៊ីធឿន** | 100,000៛ | | |
| ២៨ | ឯកឧត្តម **ប៉ោ ពុទ្ធារិទ្ធ និងលោកជំទាវ** | 100,000៛ | | |
| ២៩ | លោកស្រី **កៅ ចន្ធី និងស្វាមី** | 100,000៛ | | |
| ៣០ | លោក **សៀក ម៉េង និងភរិយា** | 100,000៛ | | |
| ៣១ | លោកជំទាវ **ប្រាក់ អេលីរតនា** | 50,000៛ | | |
| ៣២ | លោក **កង សេដ្ឋ** | 50,000៛ | | |
| ៣៣ | ឯកឧត្តម **ខឹម ម៉ូរ៉ាណា** | 50,000៛ | | |
| ៣៤ | លោក **ឆន់ សារឹម** | 40,000៛ | | |
| **សរុប** | | **27,050,000៛** | **$ 1,800** | |

# ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ប្រកាសជួយសាងសង់ទីលានបាល់ទាត់ជូនវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង



*អត្ថបទនិងរូបថត៖ សៅ សុវណ្ណ*

លោក **អន គៀង** នាយកវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង បានឱ្យដឹងថា ទីលានបាល់ទាត់មួយនេះនឹងត្រូវចំណាយថវិកាក្នុងការស្ថាបនាអស់ប្រមាណ ១ម៉ឺន ៦ពាន់ ៥០០ ដុល្លារអាមេរិក ។ លោកថា ទីលានបាល់ទាត់នេះក្រោយការស្ថាបនារួចរាល់វាមានតួនាទីសំខាន់ណាស់សម្រាប់ការហ្វឹកហាត់ និងការប្រកួតរបស់សិស្ស ដែលវានឹងរួមចំណែកយ៉ាង



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ទទួលស្វាគមន៍ពីបងប្អូនប្រជាពលរដ្ឋ និងអតីត លោកគ្រូ អ្នកគ្រូ វិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង

ឆ្លើយតបទៅនឹងសំណូមពររបស់លោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្ស ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ទីប្រឹក្សារាជរដ្ឋាភិបាល បានប្រកាសជួយសាងសង់ទីលានបាល់ទាត់ជូនវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន ពារាំង ដែលស្ថិតក្នុងឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង នាឱកាសដែលឯកឧត្តមអញ្ជើញជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ នៃវិទ្យាល័យមួយនេះរួមទាំងមាតា បិតា អាណាព្យាបាលសិស្សផងដែរ កាលពីរសៀលថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ។



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា និងថ្នាក់ដឹកនាំខេត្តព្រៃវែង



លោក អន កៀង នាយកវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង



ឯកឧត្តម ហ៊ី ធួក អភិបាលរងខេត្តព្រៃវែង



ភាពជិតស្និទរវាងឯកឧត្តមបណ្ឌិត ញឹម វណ្ណដា និងបងប្អូនប្រជាពលរដ្ឋ

សំខាន់ក្នុងការអភិវឌ្ឍវិស័យកីឡានៅក្នុងវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង ជាពិសេសផ្នែកកីឡាបាល់ទាត់ ។

ឆ្លៀតក្នុងឱកាសនេះ ជួសមុខឱ្យមាតា បិតា អាណាព្យាបាលសិស្ស លោកគ្រូ អ្នកគ្រូ និង អាជ្ញាធរដែនដី លោក **អន កៀង** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ដែលកន្លងមកបានចំណាយធនធានផ្ទាល់ខ្លួនសន្ធឹកសន្ធាប់ក្នុងការស្ថាបនាវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង នេះឡើង ដែលពីមុនមានឈ្មោះថាវិទ្យាល័យ ញឹម វណ្ណដា ពារាំង មុនពេលប្តូរមកដាក់ឈ្មោះថាវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន ពារាំង វិញនោះ ។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** បានគូសបញ្ជាក់ថាវិស័យអប់រំ គឺជាវិស័យអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ព្រោះថា ការអប់រំគឺជាការកសាងឡើងនូវធនធានមនុស្ស ដែលធនធានមនុស្សនេះនឹងត្រូវយកមក ប្រើប្រាស់សម្រាប់ការ



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា មានប្រសាសន៍សំណេះសំណាល



ប្រជាពលរដ្ឋអញ្ជើញចូលរួម



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ជូនអំណោយដល់ លោកគ្រូ អ្នកគ្រូ






អគារសិក្សាអតីតវិទ្យាល័យ ញ៉ឹម វណ្ណដា ពារាំង ជាអំណោយសប្បុរសជននៃសាធារណរដ្ឋកូរ៉េ

កសាង និងអភិវឌ្ឍប្រទេសជាតិ បើប្រទេសជាតិមួយគ្មានធនធានមនុស្ស ពោលគឺ គ្មានអ្នកចេះដឹងគ្រប់គ្រាន់ទេ ប្រទេសជាតិមួយនោះមិនអាចរីកចំរើនបានទេ អញ្ចឹងហើយបានជាប្រមុខរាជរដ្ឋាភិបាលសម្រេចកសាងសាលារៀនឱ្យបាននៅទូទាំងប្រទេស ដើម្បីផ្តល់ជាកន្លែងសម្រាប់ការសិក្សារៀនសូត្ររបស់កូនចៅប្រជាពលរដ្ឋយើង តាំងពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ឧត្តមសិក្សា ។



ឯកឧត្តមបណ្ឌិត ញ៉ឹម វណ្ណដា ផ្តល់អំណោយជូនបងប្អូនប្រជាពលរដ្ឋក្នុងពិធីសំណេះសំណាល

ឯកឧត្តមបណ្ឌិត **ញ៉ឹម វណ្ណដា** មានប្រសាសន៍បន្តថា សម័យសព្វថ្ងៃនេះ សាលារៀនបានពង្រាយនៅទូទាំងប្រទេស ។ ការកសាងសាលារៀនដ៏ច្រើនបែបនេះ ក្នុងគោលបំណងតែមួយគត់ គឺបង្ខិតឱ្យនៅជិតបំផុតនឹងកូនចៅរបស់បងប្អូនប្រជាជនយើង មានន័យថាសាលារៀននៅជិតបង្កើយ ដែលឪពុក ម្តាយ ឬអាណាព្យាបាលគ្រូតែឱ្យកូនចៅខ្លួនចូលរៀនបានគ្រប់ៗគ្នា ។ ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត ក៏បានលើកឡើងអំពីសារសំខាន់នៃការអភិវឌ្ឍវិស័យកីឡា ជាពិសេសការផ្តោតទៅលើយុវវ័យដែលជាសិស្ស និស្សិតកំពុងសិក្សា ព្រោះយុវវ័យមានចំនួនច្រើននៅក្មេង និងមានកម្លាំងកំហែងគ្រប់គ្រាន់ក្នុងការហ្វឹកហាត់និងលេងកីឡា ខណៈដែលប្រទេសកម្ពុជាយើងបានទទួលធ្វើជាម្ចាស់ផ្ទះក្នុងការប្រកួតកីឡាស៊ីហ្គេម នៅឆ្នាំ២០២៣ ខាងមុខផងនោះ ការអភិវឌ្ឍកីឡាមានការឈានឡើង គឺកាន់រឹតតែសំខាន់ទៅទៀត ដែលកិច្ចការមួយនេះយើងមិនអាចស្ទាក់ស្ទើរក្នុងការយកចិត្តទុកដាក់បានឡើយ ៕



ពិធីពិសារអាហារសាមគ្គី

# ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា សន្យាជួយជួសជុលផ្លូវលំមួយខ្សែក្នុងឃុំពពេល និងជំរុញឱ្យមានការគោរពសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ

*អត្ថបទនិងរូបថត៖ សៅ សុវណ្ណ*



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា អញ្ជើញជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋក្នុងឃុំពពេល





ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ទីប្រឹក្សារាជរដ្ឋាភិបាល បានសន្យាជួយជួសជុលកែលម្អផ្លូវលំមួយខ្សែមានប្រវែងជាង ៤គីឡូម៉ែត្រ ឆ្លងកាត់ចំនួន៣ភូមិ គឺភូមិត្រាវឯម ភូមិក្មោកពង និងភូមិព្រៃនាងស្ថិតនៅក្នុងឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីសម្រួលការធ្វើចរាចរណ៍របស់បងប្អូនប្រជាពលរដ្ឋនៅក្នុងរដូវវស្សា ជាពិសេសបងប្អូនកម្មករ កម្មការិនី ក្នុងការធ្វើដំណើរបំពេញការងារនៅរោងចក្រតំបន់នេះ ។ ការថ្លែងលើកឡើងបែបនេះក្នុងឱកាស ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** អញ្ជើញចុះជួបសំណេះ សំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ មន្ត្រីភូមិ និងបងប្អូនប្រជាពលរដ្ឋក្នុងឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២ ។

ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** បានមានប្រសាសន៍ក្នុងឱកាសនោះថា ពេលនេះជារដូវវស្សាមានភ្លៀងធ្លាក់សឹងតែរាល់ថ្ងៃ ធ្វើឱ្យផ្លូវលំដែលជាផ្លូវដីនៅទីនេះមានការខូចខាតនៅត្រង់កន្លែងខ្លះដោយអន្លើៗ អញ្ចឹងហើយ ទើបនៅពេលនេះ ឯកឧត្តម និងក្រុមការងារចុះជួយឃុំពពេល រួមជាមួយអាជ្ញាធរដែនដីភូមិ ឃុំ និងបងប្អូន ប្រជាពលរដ្ឋបានសម្រេចរួមគ្នាថាត្រូវធ្វើការជួសជុលកែលម្អឡើងវិញដើម្បីសម្រួលដល់ការធ្វើ



ទិដ្ឋភាពផ្លូវដែលត្រូវជួសជុលកែលម្អ

ចរាចរណ៍ របស់បងប្អូនប្រជាពលរដ្ឋនៅក្នុងរដូវវស្សា ជាពិសេស បងប្អូនកម្មករ កម្មការិនី ក្នុងការធ្វើដំណើរទៅបំពេញការងារនៅរោងចក្រ ។ ឯកឧត្តមបានគូសបញ្ជាក់ថា ផ្លូវមួយខ្សែនេះ បើសិនពន្យាការជួសជុលថែទាំវានឹងមានការខូចខាតខ្លាំង ព្រោះពេល



ឯកឧត្តមបណ្ឌិត ញ៉ឹម វណ្ណដា សំណេះសំណាលជាមួយ សមាជិកក្រុមប្រឹក្សាឃុំ និងមន្ត្រីភូមិ



ឯកឧត្តមបណ្ឌិត ញ៉ឹម វណ្ណដា ផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន

នេះជារដូវវស្សា ហើយនៅពេលដែលផ្លូវនេះខូចខាតខ្លាំងនោះ នឹងបណ្តាលឱ្យមានការលំបាកដល់ការធ្វើដំណើររបស់បងប្អូនប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋទាំង៣ភូមិនៅតាមដងផ្លូវមួយខ្សែនេះរួមមាន ភូមិត្រាវឯម ភូមិក្រោកពង និងភូមិព្រៃនាង ។

ឆ្លៀតឱកាសនេះដែរ ឯកឧត្តមបណ្ឌិត **ញ៉ឹម វណ្ណដា** បានជំរុញឱ្យបងប្អូនប្រជាពលរដ្ឋ ដែលជាអ្នកប្រើប្រាស់ផ្លូវនេះ ជាពិសេសអ្នកដែលមានលំនៅឋាននៅតាមបណ្តោយផ្លូវនេះចូលរួមគ្នាក្នុងការថែរក្សា ការពារជួសជុលវាដូចជា ត្រូវកាប់ដីមកចាក់បំពេញនៅតាមជង្ហុកផ្លូវជាដើម ដោយមិនត្រូវបណ្តែតបណ្តោយឱ្យវាខូចខាតដោយយើងមិនបានថែទាំនោះទេ ហើយបន្ថែមពីលើនេះឯកឧត្តមក៏បានដាស់តឿនឱ្យបងប្អូនប្រជាកសិករសកម្មក្នុងការបង្កបង្កើនផលស្រូវរដូវវស្សា រួមទាំងការដាំដុះនូវដំណាំរួមផ្សំផ្សេងៗទៀត ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការ និងអាចលក់ដូរបានដើម្បីបង្កើននូវចំណូលបន្ថែមសម្រាប់ក្រុមគ្រួសារនីមួយៗរបស់បងប្អូន ។

ឆ្លើយតបទៅនឹងការប្រកាសក្នុងការជួសជុលកែលម្អផ្លូវលំមួយខ្សែខាងលើ បងប្អូននៅភូមិតាឯម ភូមិក្រោកពង និងភូមិព្រៃនាង ស្ថិតនៅក្នុងឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមបណ្ឌិត **ញ៉ឹម វណ្ណដា** ទីប្រឹក្សារាជរដ្ឋាភិបាល ដែលបានបំផុសឱ្យមានការជួសជុលផ្លូវមួយខ្សែនេះឡើងវិញ ហើយបន្ថែមពីលើនេះ ឯកឧត្តមក៏បានប្រកាសអំពីការផ្តល់រថយន្ត សង្គ្រោះបន្ទាន់មួយគ្រឿងជូនដល់មណ្ឌលសុខភាពឃុំពពេលផងដែរ ។

ដោយឡែកនៅរសៀលថ្ងៃដដែលនោះដែរ ឯកឧត្តមបណ្ឌិត **ញ៉ឹម វណ្ណដា** បានបន្តដំណើរ និងបានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាល ចែកឯកសណ្ឋានជូនបងប្អូនប្រជាការពារនៅឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ប្រមាណជាង ៨០នាក់ ជួយកសាងឃ្លាំងទុកសម្ភារៈជូនដល់បញ្ជាការវរៈសេនាតូច៣១៣ ស្រុកត្រាំកក់ ជួយកសាងទីលានទីស្នាក់ការប៉ុស្តិ៍នគរបាលត្រពាំងក្រញូង ព្រមទាំងបានជំរុញឱ្យប្រជាការពារយកចិត្តទុកដាក់ខ្ពស់ ក្នុងការការពារសន្តិសុខសណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានជាពិសេសការទប់ស្កាត់នូវសកម្មភាពចោរកម្ម ក្មេងទំនើង ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនជាដើម ។

ឯកឧត្តមបណ្ឌិត **ញ៉ឹម វណ្ណដា** មានប្រសាសន៍ថា កម្លាំងប្រជាការពារមានតួនាទីសំខាន់ ក្នុងការចូលរួមចំណែកដើម្បីបំពេញការងារខាងលើជាមួយកម្លាំងនគរបាលប៉ុស្តិ៍នៅក្នុងមូលដ្ឋានផងដែរ គឺក្នុងន័យរក្សាសុខសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋយើង ។ ឯកឧត្តមបន្តថា ដើម្បីឆ្លើយតបទៅនឹងកិច្ចខិតខំ ប្រឹងប្រែងបំពេញការងាររបស់បងប្អូនប្រជាការពារនៅ



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា អញ្ជើញជាអធិបតីក្នុងពិធី
ជួបសំណេះសំណាលជាមួយប្រជាការពារនៅឃុំត្រពាំងក្រញូង



ក្នុងឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ជាពិសេសការចូលរួមការពារសណ្តាប់ធ្នាប់នៅក្នុងបរិវេណនៃពុទ្ធគិរីកម្ពុជា ដែលជាទីកន្លែងមានបងប្អូនប្រជាពលរដ្ឋ ធ្វើដំណើរមកគោរពបូជាចំពោះព្រះពុទ្ធរូបផង និងមកកំសាន្តផងជាហូរហែនោះ ថ្ងៃនេះ ឯកឧត្តម និងក្រុមការងារ បានសម្រេចនាំយកឯកសណ្ឋានប្រជាការពារមកចែកជូនដោយផ្ទាល់ដៃដល់បងប្អូនប្រជាការពារនៅតាមភូមិនានា ក្នុងឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ប្រមាណជាង ៨០នាក់ ក្នុងម្នាក់ៗ ទទួលបានឯកសណ្ឋាន ១កំប្លេ និង ថវិកា ២ ម៉ឺន រៀល ព្រមទាំង ការទទួលទានអាហាររួមគ្នានៅពុទ្ធគិរីកម្ពុជាមួយពេលផងដែរ ។

ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** បានគូសបញ្ជាក់ថា ការរក្សាឱ្យបាននូវសន្តិសុខសណ្តាប់ធ្នាប់សង្គមគឺជាកិច្ចការសំខាន់ និងចាំបាច់ខ្លាំងណាស់ ក្នុងនោះក៏មានការរក្សាសណ្តាប់ធ្នាប់នៅតាមភូមិឃុំផងដែរ ដោយត្រូវធ្វើយ៉ាងណាកាត់បន្ថយឱ្យបានជាអតិបរមាឬលុបបំបាត់ទាំងស្រុងនូវសកម្មភាពចោរកម្ម ក្មេងទំនើង ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀនជាដើម ដើម្បីឆ្លើយតបទៅនឹងគោលការណ៍ភូមិ ឃុំ មានសុវត្ថិភាពរបស់ក្រសួងមហាផ្ទៃ ៕



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា ប្រគេនទេយ្យវត្ថុចំពោះព្រះសង្ឃ



ឯកឧត្តមបណ្ឌិត ញឹម វណ្ណដា សំណេះសំណាលសួរសុខទុក្ខ
និងចែកអំណោយជូនដល់ប្រជាការពារ





សប្បុរសជនចូលរួមចែកអំណោយជូនដល់ប្រជាការពារ

# ឯកឧត្តម អ៊ុំ សារឹទ្ធ អញ្ជើញចូលរួមមហាសន្និបាតនៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង នៅទីក្រុងរ៉ាបាត ប្រទេសម៉ារ៉ុក

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ព្រឹទ្ធសភា*



សមាជិក សមាជិកា មហាសន្និបាតប្រារព្ធពិធីស្ងឹងស្មាធន៍គោរពវិញ្ញាណក្ខន្ធលោកជំទាវ Marie Josephine Diallo ប្រធានសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំងដែលបានទទួលមរណភាព កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២




ទិដ្ឋភាពនៃការបើកកិច្ចប្រជុំមហាសន្និបាតនៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង(ASGPF)

ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ីម កា** ប្រធានស្តីទីព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងជាអនុប្រធាននៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង បានដឹកនាំប្រតិភូអញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងមហាសន្និបាតនៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង (ASGPF) ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២ នៅរដ្ឋសភាម៉ារ៉ុក ទីក្រុងរ៉ាបាត (RABAT) ប្រទេសម៉ារ៉ុក ក្រោមអធិបតីភាពឯកឧត្តម Najib El Khadi អគ្គលេខាធិការរដ្ឋសភាម៉ារ៉ុកនិងជាប្រធានស្តីទី ASGPF ដោយមានសមាសភាពអញ្ជើញចូលរួមចំនួន ៥៤ រូប ដែលអញ្ជើញមកពីបណ្តាប្រទេសប្រើភាសាបារាំង និងជាសមាជិកនៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង ។

កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ បានពិនិត្យ និងអនុ



ទិដ្ឋភាពនិងសកម្មភាពក្នុងកិច្ចប្រជុំមហាសន្និបាត

ម៉ត់របៀបវារៈ ដើម្បីយកទៅឆ្លងក្នុងមហាសន្និបាតក្នុងនោះរួមមាន៖ កំណត់ហេតុនៃកិច្ចប្រជុំ ASGPF ឯកិច្ចប្រជុំកាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២ នៅទីក្រុងដាកា ប្រទេសសេណេហ្កាល់។ កំណត់ហេតុមហាសន្និបាត ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ នៅទីក្រុងព្រុចសែល ប្រទេសប៊ែលហ្សិក។ ស្ថានភាពហិរញ្ញវត្ថុរបស់សមាគម។ ការលើកសំណើនៃលក្ខន្តិកៈច្បាប់ឆ្នាំ១៩៩១ សម្រាប់ ASGPF ដោយសារមានការវិវត្តវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងវិស័យធនាគារ។ អាហារូបករណ៍របស់ប្រធាន (វិធីសាស្ត្រផ្តល់ជូន)។ ទំនាក់ទំនងរវាងសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង ជាមួយសមាគមសភាប្រើភាសាបារាំង (APF) អំពីកិច្ចសហប្រតិបត្តិការរួមគ្នា។ ការបោះឆ្នោតសារជាថ្មីរបស់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងការសើរើមាត្រា៤នៃលក្ខន្តិកៈ ASGPF។ ការត្រៀមរៀបចំកិច្ចប្រជុំសម្រាប់លើកក្រោយ នៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងមហាសន្និបាត (កំណត់ទីកន្លែងកាលបរិច្ឆេទនិងប្រធានបទនានា) និង បញ្ហាផ្សេងៗ។

ដោយឡែក ប្រធានបទដែលបានលើកយកមកពិភាក្សានៅក្នុងអង្គមហាសន្និបាតមានជាអាទិ៍៖ ១-របបទីសភានិយមទំនាក់ទំនងរវាងសភាទាំងពីរ (រដ្ឋសភានិងព្រឹទ្ធសភា) ២-ក្រមសីលធម៌ និងក្រមប្រតិបត្តិសម្រាប់សមាជិកសភានិងមន្ត្រីអគ្គលេខាធិការដ្ឋានសភា ៣-មជ្ឈមណ្ឌលស្រាវជ្រាវសភា៖ វិធីសាស្ត្រប្រៀបធៀប។

ក្នុងសុន្ទរកថាបើករបស់ឯកឧត្តម Najib El Khadi ប្រធានស្ដីទី បានគូសបញ្ជាក់អំពីចំណុចសំខាន់ៗ រួមមាន៖ សេចក្តីត្រូវការភាសាបារាំងនៅតែរក្សាដដែល ទោះបីយើងកំពុងស្ថិតក្នុងបរិបទកូវីដ-១៩ក៏ដោយ ក៏មហាសន្និបាតបានប្រព្រឹត្តទៅដោយប្រក្រតីផងដែរ។ ការបន្តនិរន្តរភាពនៃកិច្ចពិភាក្សា និងការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកលើការអនុវត្តជាក់ស្តែងនៅក្នុងការងារអគ្គលេខាធិការដ្ឋានសភាប្រើភាសាបារាំង ចាំបាច់ធ្វើឡើងដោយការជួបមុខគ្នាផ្ទាល់។ កិច្ចសហប្រតិបត្តិការរវាងសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំងជាមួយនិងសមាគមសភាប្រើភាសាបារាំង លើវិស័យបណ្តុះបណ្តាល



ឯកឧត្តម អ៊ុំ សារឹទ្ធ និងលោក គីមឃាត ដារ៉ារិទ្ធ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសភាអាស៊ីធ្វើបទបង្ហាញ ស្តីពីបទការអនុវត្តន៍ជាក់ស្តែងរបស់សភាកម្ពុជាជូនដល់កិច្ចប្រជុំ

កិច្ចការសភា សំដៅពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានសភានៅក្នុងសភាប្រើភាសាបារាំង ជាពិសេសតាមរយៈការបណ្តុះបណ្តាលវគ្គ Geoffrey-Dieudonee ។

មហាសន្និបាតនេះ បានពិនិត្យ និងអនុម័តរបៀបវីរៈសំខាន់ៗដូចតទៅ៖ កំណត់ហេតុនៃកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២។ កំណត់ហេតុនៃមហាសន្និបាតដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី០៩ខែកញ្ញា ឆ្នាំ២០១៩ នៅទីក្រុងព្រុចស៊ែល ប្រទេសប៊ែលហ្សិក។ របាយការណ៍សកម្មភាពប្រចាំឆ្នាំ២០២០-២០២២។ ការកែប្រែមាត្រា៤នៃលក្ខន្តិកៈនៃសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង។ ស្ថានភាពហិរញ្ញវត្ថុរបស់សមាគមអគ្គលេខាធិការសភាប្រើភាសាបារាំង។ ទំនាក់ទំនងរវាងសមាគមអគ្គលេខាធិការសភាប្រើភាសាបារាំងជាមួយនិងសមាគមសភាប្រើភាសាបារាំង។ គម្រោងវគ្គបណ្តុះបណ្តាលពីចម្ងាយផ្តល់ជូនមន្ត្រីអគ្គលេខាធិការដ្ឋានសភា រៀបចំដោយវិទ្យាល័យ Senghor។ អាហាររូបករណ៍ផ្តល់ជូនមន្ត្រីអគ្គលេខាធិការដ្ឋានសភា។ កំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំលើកក្រោយ និងបញ្ហាផ្សេងៗ។ ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ASGPF ។

ក្រៅពីនោះ មហាសន្និបាតបានស្តាប់ការធ្វើបទបង្ហាញអំពីរបបទីសភា និងទំនាក់ទំនងរវាងសភាទាំងពីរនិងក្រមសីលធម៌សម្រាប់សមាជិកសភានិងបុគ្គលិកសភានិងដែនកំណត់ព្រមទាំងមជ្ឈមណ្ឌលស្រាវជ្រាវសភា ៖ វិធីសាស្ត្រប្រៀបធៀបក្នុងអំឡុងពេលដំណើរការមហាសន្និបាត ។

ក្នុងកិច្ចប្រជុំមហាសន្និបាត ក៏មានបទបង្ហាញរបស់សភាកម្ពុជា ស្តីពីមជ្ឈមណ្ឌលស្រាវជ្រាវ ដែលទទួលបានការចាប់អារម្មណ៍ពីមជ្ឈដ្ឋាននានា ជាពិសេសសម្រាប់មិត្តភក្តិក្នុងទ្វីប



ឯកឧត្តម អ៊ុំ សារឹទ្ធ ជួបសន្ទនាជាមួយដៃគូការងារ

អាហ្វ្រិក។ នេះជាមោទនភាពរបស់កម្ពុជាដែលមានសមត្ថភាពចែករំលែកបទពិសោធន៍សភាដល់សមាគមអគ្គលេខាធិការសភាប្រើភាសាបារាំងទាំងមូល ។

អន្តរកម្មរបស់កម្ពុជា ជាមួយអង្គការសភាកម្រិតសកលនេះបានរួមចំណែកលើកកម្ពស់កិត្យានុភាពរបស់ជាតិយើងនិងសភាយើង ហើយអនុញ្ញាតឱ្យយើងដើរទាន់គេឯងក្នុងតំបន់និងពិភពលោក ហើយមានចំណុចខ្លះ កម្ពុជាយើងបានអនុវត្តល្អច្រើនជាងសភាដទៃទៀតផង។

នៅក្នុងមហាសន្និបាត ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានជួបសន្ទនាការងារជាមួយដៃគូការងារ មានដូចជា៖ អគ្គលេខាធិការព្រឹទ្ធសភាបារាំង រដ្ឋសភាបារាំង អគ្គលេខាធិការសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល អគ្គលេខាធិការរដ្ឋសភាកាណាដា អគ្គលេខាធិការរដ្ឋសភាគេប៊ិច អគ្គលេខាធិការរដ្ឋសភាប៉ូលេនេស៊ីបារាំង អគ្គលេខាធិការរដ្ឋសភាកុងហ្គោនិងអគ្គលេខាធិការសភាម៉ារ៉ុកជាដើម ដើម្បីរកការគាំទ្រសម្រាប់សហប្រតិបត្តិការក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការផ្លាស់ប្តូរបទពិសោធន៍សភាទៅវិញទៅមក៕

# លោកជំទាវ ខៀវទេព រង្សីកាញ្ញារិទ្ធ និងប្រតិភូអញ្ជើញកាន់បិណ្ឌវេនទី៥ នៅវត្តដំណាក់ព្រីង និងវត្តមហាលាភ ក្នុងឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម

*អត្ថបទ និងរូបថត ៖ វ៉ាន់ ច័ន្ទកិរុណា*



លោកជំទាវ ខៀវទេព រង្សីកាញ្ញារិទ្ធ ប្រធានកិត្តិយស សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សាខាក្រសួងព័ត៌មាន រួមជាមួយឯកឧត្តមលោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាក្រសួង នាំយកនូវបច្ច័យ ទេយ្យទាន ប្រគេនដល់ព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តមហាលាភ





ក្នុងឱកាសនៃពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌចូលមកដល់ លោកជំទាវ **ខៀវទេព រង្សីកាញ្ញារិទ្ធ** ប្រធានកិត្តិយស សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ សាខាក្រសួង ព័ត៌មាន តំណាងឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** អមដំណើរ ដោយលោកជំទាវ **សុខមុំ និមល** អគ្គនាយិកា នៃអគ្គនាយកដ្ឋានទីភ្នាក់ងារព័ត៌មានកម្ពុជា AKP រួមជាមួយ ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ក្រសួងព័ត៌មាន បាននាំយកនូវបច្ច័យ ទេយ្យទានទៅប្រគេន



លោកជំទាវ ខៀវទេព រង្សីកាញ្ញារីទ្ធ ប្រធានកិត្តិយស សមាគមនារីកម្ពុជា ដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សាខាក្រសួងព័ត៌មាន រួមជាមួយឯកឧត្តមលោកជំទាវ ជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាក្រសួង នាំយកនូវបច្ច័យ ទេយ្យទាន ប្រគេនដល់ព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តដំណាក់ព្រីង





ដល់ព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តដំណាក់ព្រីង និងវត្តមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម និងបានជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលមានអាយុ ៧០ឆ្នាំឡើង កាលពីព្រឹកថ្ងៃទី១៥ខែកញ្ញា ឆ្នាំ២០២២។

លោកជំទាវ **ខៀវទេព រង្សីកាញ្ញារីទ្ធ** ប្រធានកត្តិយស សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍សាខាក្រសួងព័ត៌មាន បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា តែងតែយកចិត្តទុកដាក់យ៉ាងសំខាន់ចំពោះសុខភាព សុខុមាលភាពប្រជាពលរដ្ឋ ដោយមិនប្រកាន់នូវនិន្នាការនយោបាយ និន្នាការគណបក្ស ពូជសាសន៍ ពណ៌សម្បុរ អ្វីឡើយ ឱ្យតែប្រជាពលរដ្ឋកម្ពុជាមានទុក្ខលំបាកនៅទីកន្លែងណារមែងតែងមានវត្តមាននៃមន្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជាចុះជួយ និងនៅក្បែរប្រជាពលរដ្ឋជានិច្ច ជាពិសេសក្នុងរដូវបុណ្យទាននានា។

លោកជំទាវ បានបន្តថា ពិធីបុណ្យភ្ជុំបិណ្ឌជាពិធីបុណ្យដ៏




រូបថតអនុស្សាវរីយ៍



ជំមួយក្នុងវិស័យពុទ្ធសាសនា និងជំនឿដ៏ល្អផូរផង់របស់ប្រជាពលរដ្ឋខ្មែរតាំងពីបុរាណកាលរៀងមក ហើយពិធីបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ ក៏បានឆ្លុះបញ្ចាំងអំពីបុណ្យបាប កម្មផល អកុសលកម្មនានា ដែលមនុស្សបានសាងឡើងតាំងពីអតីតជាតិ បច្ចុប្បន្ន និងទៅអនាគត។

ឆ្លៀតក្នុងឱកាសនោះផងដែរ លោកជំទាវ **ខៀវទេព រង្សីកាញ្ញារីទ្ធ** រួមជាមួយលោកជំទាវថ្នាក់ដឹកនាំនៃសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ សាខាក្រសួងព័ត៌មាន បាន



លោកជំទាវ ខៀវទេព រង្សីកាញ្ញារីទ្ធ រួមជាមួយលោកជំទាវគណៈប្រតិភូ
អញ្ជើញចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋដែលមានវ័យអាយុ ៧០ឡើង





លោកជំទាវ ខៀវទេព រង្សីកាញ្ញារិទ្ធ ឡើងមានមតិសំណេះសំណាល

ប្រគេនទេយ្យទាន និងបច្ច័យដល់វត្តដំណាក់ព្រីង និងវត្តមហាលាភ ដែលក្នុងមួយវត្តៗ ទទួលបានអង្ករ ១០០គីឡូក្រាម បច្ច័យព្រះចៅអធិការវត្តក្នុងមួយវត្ត ២០ម៉ឺនរៀល បច្ច័យព្រះសង្ឃគង់ក្នុងវត្តដំណាក់ព្រីង ១២អង្គ ក្នុងមួយអង្គៗ បច្ច័យ ២ម៉ឺនរៀល វត្តមហាលាភ ព្រះសង្ឃ ១៥អង្គ មួយអង្គៗ បច្ច័យ ២ម៉ឺនរៀល សាដកមួយវត្ត ២ប្រអប់ ត្រីងៀត ២គីឡូក្រាម ទឹកសុទ្ធ ២កេស ទឹកសណ្ដែក ២កេស មីជាតិ ២កេសតូច ស្ករស ២គីឡូក្រាម



លោក រស់ ឃីម ឡើងរាយការណ៍









បច្ច័យគណៈកម្មាការអាចារ្យវត្ត ១០ម៉ឺនរៀល បច្ច័យកសាងវត្តក្នុងមួយវត្តៗ ១លាន ៨៧ម៉ឺនរៀល សរុបបច្ច័យកសាងវត្ត ៣លាន ៧០ម៉ឺនរៀល។ ដោយឡែក លោកជំទាវ **សុខមុំ និមល** អគ្គនាយិកានៃអគ្គនាយកដ្ឋានទីភ្នាក់សារព័ត៌មានកម្ពុជា (AKP) បានបន្ថែមក្នុងមួយវត្តទទួលបានឆៃប៉ូវ ២គីឡូក្រាម សៀងផ្អែម ៤យួរ និងប្រេងឆា ២លីត្រផងដែរ។

ជាកិច្ចបន្ត លោកជំទាវ **ខៀវទេព រង្សីភាញារិទ្ធ** រួមជាមួយលោកជំទាវគណៈប្រតិភូ បានអញ្ជើញចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋដែលមានវ័យអាយុ ៧០ឆ្នាំឡើង នៅក្នុងឃុំមហាលាភ ដោយបាននាំយកនូវប្រសាសន៍ផ្តាំផ្ញើសាកសួរសុខទុក្ខរបស់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ជូនចំពោះ លោកយាយ លោកតា អ៊ំ ពូ មីងទាំងអស់ ដែលបានចូលរួម សូមថែទាំសុខភាពរស់នៅស្អាត ហូបស្អាត និងរួមគ្នាអនុវត្តន៍វិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ និងចេះរស់នៅតាមបែបគន្លងថ្មីក្នុងបរិបទជំងឺកូវីដ-១៩។ មុននឹងបញ្ចប់ លោកជំទាវ **ខៀវទេព រង្សីភាញារិទ្ធ** បានផ្តល់ជូនថវិកាដល់លោកតា លោកយាយ ដែលមានអាយុចាប់ពី ៧០ឆ្នាំឡើងទៅ ប្រមាណ ៥៦៩នាក់ ក្នុងម្នាក់ៗទទួលបានថវិកា ២ម៉ឺនរៀលផងដែរ៕



# កំណើននៃប្រភេទផ្លែឈើស្រស់កម្ពុជានាំចេញទៅចិន រំលេចចេញពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន

*អត្ថបទ៖ សៅ សុវណ្ណ , រូបថត៖ ក្រសួងកសិកម្ម*




ឯកឧត្តម វេង សាខុន អញ្ជើញចូលរួមពិធីសម្ពោធការនាំចេញផ្លែស្វាយស្រស់ពីកម្ពុជាទៅចិន



វិស័យកសិកម្មជាសសរស្តម្ភមួយ សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិកម្ពុជាលើការនាំចេញកសិផល ជាពិសេសប្រភេទផ្លែឈើស្រស់ បានក្លាយជាគោលនយោបាយសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការលើកកម្ពស់កម្រិតជីវភាព របស់ប្រជាកសិករ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

កាលពីឆ្នាំ២០២១ កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម រវាងកម្ពុជានិងចិន មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយក្នុងនោះប្រទេសទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ អំពីប្រទេសចិនបញ្ជាទិញអង្ករកម្ពុជាចំនួន ៤០ម៉ឺនតោន ក្នុងរយៈពេល ១៧ខែ គិតចាប់ពីខែធ្នូ ឆ្នាំ២០២១ តទៅ និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី « **ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យ និងសុវត្ថិភាពចំណីអាហារ** » រវាងចិននិងកម្ពុជាជាដើម ។

ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ បានឱ្យដឹងថា ការនាំចេញផលិតផលកសិកម្មកម្ពុជាទៅកាន់ទីផ្សារប្រទេសចិន ក្នុងរយៈពេល៣ឆ្នាំ៦ខែ គិតចាប់ពីឆ្នាំ ២០១៩ រហូតដល់៦ខែ ដើមឆ្នាំ២០២២ នេះ សម្រេចបានទំហំជាង២,៤លានតោន ដែលក្នុងនោះមានផ្លែចេកស្រស់ អង្ករ ចំណិតដំឡូងមីក្រៀម ម្សៅដំឡូងមី ដំណាប់ស្វាយជ័រកៅស៊ូ កាកសំណល់ដំឡូងមី ផ្លែស្វាយស្រស់ គ្រាប់ស្វាយចន្ទីកែច្នៃ ម្សៅកាការ និងផលិតផលកសិកម្មចំនួន ២៤មុខផ្សេងទៀត

ដែលមានតម្លៃសរុប ១ ៩៤២លានដុល្លារអាមេរិក ។

គួរបញ្ជាក់ដែរថា នៅមុនពេលកើតមានវិបត្តិកូវីដ-១៩ ការនាំចេញកសិផលរបស់កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ មានកំណើនពីមួយឆ្នាំទៅមួយឆ្នាំពិសេសគឺការរកបានទីផ្សារចិនដែលជាទីផ្សារដ៏ធំប្រកបដោយសក្តានុពល សម្រាប់ការនាំចេញកសិផលខ្មែរ ដោយ ក្នុងនោះប្រភេទផលិតផលកសិកម្មខ្មែរកាន់តែច្រើនឡើងៗ បានបង្ហាញវត្តមានក្នុងទីផ្សារប្រទេសចិន ។



ពិធីចុះហត្ថលេខាស្តីពីលក្ខខណ្ឌការត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យនៃការនាំចេញផ្លែស្វាយទៅទីផ្សារនៅចិន

ជាមួយគ្នានោះដែរ បើទោះបីជាស្ថិតក្នុងបរិបទកូវីដ-១៩ក្តី ក៏ផ្លែឈើស្រស់របស់កម្ពុជាទទួលបាន ការអនុញ្ញាតឱ្យនាំចេញផ្ទាល់ទៅកាន់ ប្រទេសចិនជាបន្តបន្ទាប់ ជាក់ស្តែងដូចជា



ឯកឧត្តម វេង សាខុន ពិនិត្យមើលផ្លែស្វាយក្នុងរោងចក្រ សម្រាប់ការនាំចេញ

កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ អគ្គនាយកដ្ឋានគយចិន បានអនុម័តទទួលស្គាល់ជាផ្លូវការ នូវបញ្ជីឈ្មោះចម្ការស្វាយចំនួន៣៧ និងរោងចក្រវេចខ្ចប់ចំនួន៥ របស់កម្ពុជា ដែលបានចុះបញ្ជីសម្រាប់នាំចេញផ្លែស្វាយស្រស់កម្ពុជា ទៅកាន់ប្រទេសចិន ដែលជាសមិទ្ធផលថ្មីនៃកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរលើវិស័យកសិកម្មរវាងកម្ពុជានិងចិន បន្ទាប់ពីការនាំចេញផ្លែចេកស្រស់របស់កម្ពុជាទៅចិន ។

ដោយឡែកការនាំចេញផលិតផលកសិកម្មរបស់កម្ពុជាក្នុងបរិបទកូវីដ-១៩ក៏ជួបបញ្ហាមួយចំនួនផងដែរ តាមការឱ្យដឹងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទថា នៅ៥ខែដើមឆ្នាំ២០២២នេះការនាំចេញកសិផលស្រស់មួយចំនួនរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ពិសេសទីផ្សារប្រទេសចិនដែលជាទីផ្សារធំរបស់កម្ពុជា បានធ្លាក់ចុះគួរឱ្យកត់សម្គាល់បណ្តាលមកពីកត្តាមួយចំនួនដូចជាការរឹតបន្តឹង ការត្រួតពិនិត្យទំនិញដើម្បីទប់ស្កាត់ការរាលដាលឆ្លងជំងឺកូវីដ-១៩ ជាដើម ។

យ៉ាងណាមិញ ជាសមិទ្ធផលថ្មីក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិនថ្មីៗ កន្លងទៅនេះ ការវាយតម្លៃលក្ខខណ្ឌតម្រូវភូតគាមអនាម័យ សម្រាប់ការនាំចេញផ្លែមៀនស្រស់ពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិនបានឈានដល់ដំណាក់កាលចុងក្រោយហើយ ដោយទទួលបានផលវិជ្ជមានដែលអាចនឹងនាំចេញក្នុងរដូវប្រមូលផលខាងមុខនេះ ពោលគឺក្នុងអំឡុងខែសីហាឬខែកញ្ញា នេះបើតាមការឱ្យដឹងពីឯកឧត្តម



ការត្រួតពិនិត្យពីមន្ត្រីជំនាញការវេចខ្ចប់ផ្លែស្វាយស្រស់





ឯកឧត្តម វេង សាខុន អញ្ជើញពិនិត្យមើលការវេចខ្ចប់ផ្លែស្វាយសម្រាប់ការនាំចេញពីរោងចក្រកម្ពុជាទៅចិន

**ខិន ឆាយ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្មកម្ពុជា ។

ក្រៅពីនេះ កសិផលខ្មែរមួយចំនួនទៀត ក៏កំពុងស្ថិតក្នុងការចរចាដើម្បីនាំចេញផ្ទាល់ ទៅកាន់ទីផ្សាររបស់ប្រទេសចិនផងដែរ ជឿជាក់ថានឹងទទួលបានការអនុម័ត និងទទួលស្គាល់ពីរដ្ឋាភិបាលចិនជាបន្តបន្ទាប់ ដែលនឹងធ្វើឱ្យប្រជាជនចិនកាន់តែច្រើនឡើងៗ បានស្គាល់និងភ្លក្សរសជាតិកសិផលស្រស់របស់កម្ពុជា ។

ក្រោមកិច្ចខិតខំប្រឹងប្រែងរួមរបស់ប្រទេសទាំងពីរចិននិងកម្ពុជា ទីបំផុតពិតជានឹងអាចជម្នះឧបសគ្គនានា ដែលបង្កផលប៉ះពាល់ដល់ការនាំចេញនាំចូលអន្តរជាតិ ដូចជាវិបត្តិជំងឺកូវីដ-១៩ ជាដើម ដល់ពេលនោះ ក្នុងទីផ្សារដ៏ធំនិងប្រកបដោយសក្ដានុពលរបស់ប្រទេសចិន មុខជានឹងបន្ថែមវត្តមានរបស់ផលិតផលខ្មែរ ជាពិសេសគឺផលិតផលកសិកម្មកាន់តែច្រើនឡើងៗជាមិនខាន ៕



ចេកអំបូងលឿង



ដំឡូងមី



ផ្លែមៀន



ម្រេច



ស្វាយចន្ទី

# រយៈពេល៥ឆ្នាំ ក្រសួងព័ត៌មានរកឃើញព័ត៌មានក្លែងក្លាយ
## ជាង៤ពាន់មាតិកា តែមិនបញ្ជូនសំណុំរឿងទៅតុលាការនោះទេ

*អត្ថបទ ៖ ប៊ុនរិទ្ធ (AKP) , រូបថត ៖ វ៉ាន់ ច័ន្ទភិរុណ*



សន្និសីទសារព័ត៌មាន ស្តីពីសមិទ្ធផលសម្រេចបានរយៈពេល ៥ឆ្នាំរបស់ក្រសួងព័ត៌មាន

ថ្លែងក្នុងសន្និសីទសារព័ត៌មាន ស្តីពី "សមិទ្ធផលសម្រេចបានរយៈពេល៥ឆ្នាំ កន្លងមករបស់ក្រសួងព័ត៌មាន" ដែលរៀបចំឡើងដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ព្រឹកថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ នៅទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **មាស សុភ័ណ្ឌ** អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងព័ត៌មាន បានលើកឡើងថា រយៈពេល៥ឆ្នាំ កន្លងមកនេះក្រសួងព័ត៌មាន បានរកឃើញការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយចំនួន ៤ ៦៥៧ មាតិកាដែលជាប្រភេទព័ត៌មានប្រឌិត មានន័យថារឿងដែលផ្សាយនោះគ្មាននោះទេ ប៉ុន្តែបង្កើតឡើងធ្វើឱ្យមានជាព័ត៌មានដែលជាប្រភេទជេរប្រមាថ ដូចជាការជេរប្រមាថព្រះមហាក្សត្រជាដើម។



ឯកឧត្តម មាស សុភ័ណ្ឌ

ឯកឧត្តម បានថ្លែងថា នៅពេលពិនិត្យរួចហើយ ក្រសួងព័ត៌មាន មិនបានលើកយកសំណុំរឿងទាំងនោះបញ្ជូនទៅតុលាការទេ តែយើងមានកិច្ចសហប្រតិបត្តិការ ជាមួយក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ផងដែរ។






ឯកឧត្តមអនុរដ្ឋលេខាធិការ បានថ្លែងបញ្ជាក់ថា ក្នុងករណីការផ្សព្វផ្សាយមិនពិតមានករណីធ្ងន់ធ្ងរក្រសួងបានបញ្ជូនសំណុំរឿងទៅក្រសួងពាក់ព័ន្ធចាត់វិធានការបន្តចំនួន១៧០មាតិកា។

ឯកឧត្តម បន្តថា ចំពោះព័ត៌មានក្លែងក្លាយ ក្រសួងបានអនុវត្តន៍តាមអនុក្រឹត្យមួយដែលបានចាប់ផ្ដើមតាំងពីឆ្នាំ២០២០មក ហើយការរកព័ត៌មានក្លែងក្លាយនេះមានការសហការគ្នារវាងក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍។

ឯកឧត្តម ក៏បានអះអាងដែរថា ក្រសួងទាំងបីនេះនឹងធ្វើការទប់ស្កាត់ចំពោះព័ត៌មានក្លែងក្លាយដើម្បីកុំឱ្យមានការជះឥទ្ធិពលដល់ប្រជាពលរដ្ឋ និងសេចក្ដីថ្លៃថ្នូររបស់ប្រទេសទាំងមូលផងដែរ។ «ព័ត៌មានក្លែងក្លាយបានជះឥទ្ធិពលខ្លាំងណាស់ដល់ប្រទេសជាតិ ជាក់ស្ដែងការឃោសនាពីគ្រោះធម្មជាតិជាដើម។ ការផ្សាយព័ត៌មានក្លែងក្លាយនេះ មិនមែនមានតែពេលបច្ចុប្បន្ននេះទេ គឺមានយូរហើយ ប៉ុន្តែពេលបច្ចុប្បន្ននេះ គឺមានការផ្សព្វផ្សាយលឿនដែលយើងពិបាកគ្រប់គ្រង»។

ជាមួយគ្នានោះដែរ ឯកឧត្តមអ្នកនាំពាក្យបានបន្ថែមថា ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះក្រសួងព័ត៌មានបានចុះបញ្ជីអង្គភាព ស្ថាប័នសារព័ត៌មាន បានចំនួន២១៥៤ អង្គភាព/ស្ថាប័ន ក្នុងនោះសារព័ត៌មានអនឡាញមានការកើនឡើងច្រើន។ ទន្ទឹមនេះ ការចុះបញ្ជីនេះទៀតសោត បើប្រៀបធៀបនឹងឆ្នាំ២០១៨ គឺកើន៥៨៨អង្គភាព។

បើតាមឯកឧត្តម **មាស សុភ័ណ្ឌ** សម្រាប់ការចុះបញ្ជីស្ថាប័នសារព័ត៌មាននេះធ្វើឡើងជារៀងរាល់ឆ្នាំ ហើយការចុះនេះគឺមានការទទួលស្គាល់ និងបង្ហាញឱ្យឃើញថាលំហព័ត៌មាននៅកម្ពុជាមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ដឹកនាំក្រសួងព័ត៌មាន៕

# ក្រសួងធនធានទឹក និងឧតុនិយមបង្ហាញសមិទ្ធផលរយៈពេល ៥ឆ្នាំ ដែលសម្រេចបាន

*អត្ថបទ ៖ សៅ សុវណ្ណ , រូបថត ៖ វ៉ាន់ ច័ន្ទភិរុណ*



ឯកឧត្តម ប៊ុន ហ៊ាន មានប្រសាសន៍ក្នុងសន្និសីទសារព័ត៌មាន
បង្ហាញពីលទ្ធផលដែលក្រសួងធនធានទឹក និងឧតុនិយម សម្រេចបានរយៈពេល ៥ឆ្នាំ

ឯកឧត្តម **ប៊ុន ហ៊ាន** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម បានមានប្រសាសន៍បង្ហាញពីទស្សនទាននៃការគ្រប់គ្រងទឹក និងសមិទ្ធផលដែលក្រសួងសម្រេចបានក្នុងរយៈពេល ៥ឆ្នាំកន្លងមករួមមានទី ១-ការគ្រប់គ្រងទឹកឱ្យបានល្អប្រសើរ និងទី ២-ការប្រើប្រាស់ទឹក ឬការធ្វើអាជីវកម្មលើធនធានទឹក ប្រកបដោយប្រសិទ្ធភាពខ្ពស់និងនិរន្តរភាព ។





ការថ្លែងបែបនេះរបស់ ឯកឧត្តម **ប៊ុន ហ៊ាន** បានធ្វើឡើងក្នុងឱកាស ឯកឧត្តមបានអញ្ជើញធ្វើសន្និសីទសារព័ត៌មានស្ដីពីសមិទ្ធផលសម្រេចបានរយៈពេល ៥ឆ្នាំ របស់ក្រសួងធនធានទឹក ដែលរៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី



នៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០២២ ព្រមទាំងមានការអញ្ជើញចូលរួមថ្នាក់ដឹកនាំក្រសួង និងមន្ទីរធនធានទឹកនិងឧតុនិយម ខេត្តបាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ ខេត្តកំពង់ស្ពឺ ជាវាគ្មិនក្នុងសន្និសីទសារព័ត៌មាននោះផងដែរ ។

សូមបញ្ជាក់ថា សមិទ្ធផល ដែលក្រសួងធនធានទឹកនិងឧតុនិយម សម្រេចបានរយៈពេល ៥ ឆ្នាំមកនេះរួមមាន៖ អភិវឌ្ឍន៍អាងស្តុកទឹក និងសំណង់ស្ពាក់ទឹកធំៗចំនួន ៣កន្លែង ដែលអាចស្តុកទឹកបាន ៤៥៥ លានម៉ែត្រគ្រីគុណ ។ ការស្តារសាងសង់ និងអនុត្តរភាពប្រព័ន្ធសាស្ត្រ បានចំនួន ១២៣ ០១៥ ហិកតា ក្នុងនោះស្រូវវស្សាចំនួន ៨១ ៨៦៣ហិកតា និងស្រូវប្រាំង ៤១ ១៥២ហិកតា ព្រមទាំងដំណាំរួមផ្សំ ៤.៣៩៩ហិកតា ។ ការជួសជុល ថែទាំ ប្រព័ន្ធធារាសាស្ត្រ បានចំនួន ៦៩១ ២២១ ហិកតាក្នុងនោះស្រូវវស្សា ៥៧៥ ៧៦៥ហិកតា និងស្រូវប្រាំង ១១៥ ៤៥៦ហិកតា ព្រមទាំងដំណាំរួមផ្សំ ៣ ៦៤៦ហិកតា ។ រៀបចំប្រព័ន្ធដោះទឹកជំនន់ និងប្រព័ន្ធស្រោចស្រព ស្ទឹងព្រែកត្នោត ដែលមានលទ្ធភាពដោះទឹកបាន១ ៣៥០ម៉ែត្រគ្រីគុណ ក្នុងមួយវិនាទី នៅផ្នែកខាងក្រោម ស្ទឹងព្រែកត្នោត សម្រេចបាន





ប្រព័ន្ធធារាសាស្ត្រ ស្ទឹងស្រែង ឃុំជើងទៀន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និងឃុំស្លែងស្ពាន ស្រុកស្រីស្នំ ខេត្តសៀមរាប








ប្រព័ន្ធធារាសាស្ត្រ ស្ទឹងជីនិត ស្ថិតក្នុងខេត្តកំពង់ធំ

ប្រមាណ ៦៤ភាគរយ ។ ការងារការពារច្រាំងទន្លេមេគង្គ និងទន្លេបាសាក់ ក្នុងខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ បានប្រវែង ៣០ ៦៥៨ម៉ែត្រ ។ ទំនប់ការពារទឹកជំនន់ លើផ្ទៃដីសរុបចំនួន៦ ០២៤ហិកតា ក្នុងនោះការពារលំនៅដ្ឋានបាន១០ ៤៨៩ខ្នង។ ទំនប់ការពារទឹកប្រៃ លើផ្ទៃដីសរុប ១៨ ១៣៨ហិកតា ។សាងសង់ស្ថានីយឧតុនិយម ចំនួន ៥១កន្លែង និងប៉ុស្តិ៍ តម្រងទឹកភ្លៀង ចំនួន ៩១កន្លែង និងស្ថានីយជលសាស្ត្រ ២៨កន្លែង ។ការងារព្យាករអាកាសធាតុ ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំរដូវ និងការព្យាករណ៍ទឹកជំនន់ នៅតាមទន្លេស្ទឹងសំខាន់ៗមួយចំនួន ។ ការកំណត់ព្រំអាងទឹក និងបឹងធម្មជាតិ បានចំនួន ១៣៤ កន្លែង ។

ជារួម គិតមកដល់បច្ចុប្បន្ននេះ លទ្ធភាពស្រោចស្រពនៃប្រព័ន្ធធារាសាស្ត្រ ក្រសួងធនធានទឹកនិងឧតុនិយម សម្រេចបាន ១ ៨៨៩ ១១២ហិកតា លើផ្ទៃដីដាំដុះសរុប ៣ ០៧៨ ២២០ ហិកតា ដែលស្មើរនឹង ៦១,៣៧ភាគរយ ។៚



ប្រព័ន្ធធារាសាស្ត្រ អាចាង ស្ថិតក្នុងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង

# កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ចូលរួមឧបត្ថម្ភនិង ដំឡើងបង្គោលនិងអំពូលសូឡាតាម បណ្តោយផ្លូវស្របដងទន្លេមេគង្គ នៅតំបន់រមណីយដ្ឋានព្រែកកាំពី អន្លង់ផ្សោតកាំពី និងតំបន់ជុំវិញ

អត្ថបទ និងរូបថត ៖ ប៉ែន សុខុម



កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ នៃសាលាភូមិន្ទរដ្ឋបាលប្រគល់អំពូលសូឡា ជូនសាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាព ឯកឧត្តម យក់ ប៊ុនណា រដ្ឋលេខាធិការប្រចាំការ ក្រសួងមុខងារសាធារណៈ និងជានាយកសាលាភូមិន្ទរដ្ឋបាល

សាលាភូមិន្ទរដ្ឋបាល បានរៀបចំដំឡើងបង្គោលនិងអំពូលសូឡា ដាក់តាមតំបន់រមណីយដ្ឋានព្រែកកាំពី អន្លង់ផ្សោតកាំពី ដើម្បីបំភ្លឺដងផ្លូវជួយសម្រួលការធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងតំបន់ និងភ្ញៀវទេសចរឆ្លងកាត់នៅពេលរាត្រី។

កម្មវិធីនេះ ធ្វើឡើងកាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ ក្រោមវត្តមានឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកចិត្របុរី និងសហការី ព្រមទាំងគណៈគ្រប់គ្រង និងមន្ត្រីរាជការនៃសាលាភូមិន្ទរដ្ឋបាល អមដោយអាជ្ញាធរឃុំសំបុក និងអាជ្ញាធរស្រុកចិត្របុរី ដោយបានដំឡើងបង្គោលនិងអំពូលសូឡាចំនួន ៤០ឈុត នៅអមតាមសងខាងផ្លូវចាប់ពីរមណីយដ្ឋាន**ព្រែកកាំពី** រហូតដល់អន្លង់





សកម្មភាពកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បានចុះទៅដំឡើងបង្គោល និងអំពូលសូឡា









សកម្មភាពលោកគ្រូទទួលបន្ទុកថ្នាក់ ដឹកនាំ កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បានចុះទៅដំឡើងបង្គោល និងអំពូលសូឡា នៅក្នុងតំបន់រមណីយដ្ឋានព្រែកកាំពី











ផ្សោតកាំពី ក្នុងឃុំសំបុក ស្រុកចិត្របុរី ខេត្តក្រចេះ។

កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បានចុះទៅដំឡើងបង្គោល និងអំពូលសូឡា នៅក្នុងតំបន់រមណីយដ្ឋានព្រែកកាំពី អន្លង់ផ្សោតកាំពី បំភ្លឺតាម ដងផ្លូវ និងកាយកាត់បន្ថយការចំណាយលើការប្រើប្រាស់អគ្គិសនី ជូនប្រជាពលរដ្ឋក្នុងតំបន់ ។

នេះជាការដំឡើងលើកទី១ ដែលកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ បានចូលរួមដំឡើងបង្គោល និងអំពូលសូឡា ចំនួន ៤០ឈុត ដែលជាការអនុវត្តការងារសង្គម ក្នុងកម្មវិធីអំពូលសូឡាបំភ្លឺសហគមន៍របស់សាលាភូមិន្ទរដ្ឋបាល។ សាលាបានគ្រោងរៀបចំដាក់អំពូលសូឡាបំភ្លឺនៅតាមបណ្ដោយផ្លូវស្របដងទន្លេមេគង្គ ក្នុងឃុំសំបុក និងឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ក្នុងគោលបំណងលើកកម្ពស់សុវត្ថិភាពក្នុងការធ្វើដំណើរពេលរាត្រី បង្កើនសោភ័ណភាព និងជំរុញទេសចរណ៍នៅតំបន់រមណីយដ្ឋានព្រែកកាំពី អន្លង់ផ្សោតកាំពី និងតំបន់ជុំវិញ។





កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បានដំឡើងបង្គោល និងអំពូលសូឡារួចរាល់និងថតរូបអនុស្សាវរីយ៍





កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បានចូលរួមឧបត្ថម្ភនូវបង្គោល និងអំពូលសូឡាចំនួន ៣១ឈុត និងកម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់នគរភ្នំ បានចូលរួមឧបត្ថម្ភនូវបង្គោល និងអំពូលសូឡាចំនួន ២២ឈុត សរុបទាំងពីរថ្នាក់មានចំនួន ៥៣ឈុត (ក្នុងការដំឡើងលើកទី១នេះមានចំនួន ៤០ឈុត)។ ទន្ទឹមនឹងនេះ កម្មសិក្សាការីទាំងពីរថ្នាក់ ក៏បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពដំឡើងបង្គោលនិងអំពូលសូឡា ទាំង ៤០ឈុត លើកនេះផងដែរ។

ក្នុងថ្ងៃដដែលនោះ កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បានធ្វើទស្សនកិច្ចសិក្សានៅវត្តសសរ ១០០ និងបាននាំយកទេយ្យទាននិងបច្ច័យទៅប្រគេនព្រះសង្ឃគង់នៅវត្តសសរ១០០ និងបានដាំកូនឈើនៅទីនោះផងដែរ។







កម្មសិក្សាការីវគ្គវិក្រឹតការមន្ត្រីជាន់ខ្ពស់ ឆ្នាំ២០២២ ថ្នាក់ចេនឡា បាននាំយកទេយ្យទាននិងបច្ច័យ រួមទាំងដាំកូនឈើ នៅបរិវេណវត្តសរសរ១០០





# GBV Safe App

## ជាកម្មវិធីលើទូរស័ព្ទវៃឆ្លាត នឹងផ្តល់ភាពងាយស្រួលក្នុងការផ្តល់ព័ត៌មាន អំពីករណីរំលោភបំពានសិទ្ធិស្ត្រី និងកុមារីដែលងាយរងគ្រោះ

*អត្ថបទ ៖ វ៉ាន់ ច័ន្ទភិរុណា , រូបថត ៖ អ៊ឹម ភិរក្សនារីរតនៈ*



តំណាងក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ
អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នៅទីស្តីការក្រសួងកិច្ចការនារី




លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី

លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី បានមានប្រសាសន៍ថា កម្មវិធីលើទូរស័ព្ទវៃឆ្លាត GBV Safe App នឹងផ្តល់ភាពងាយស្រួល ក្នុងការផ្តល់ព័ត៌មានអំពីករណីរំលោភបំពានសិទ្ធិស្ត្រី ដែលអាចនឹងកើតឡើង រួមទាំងការបៀតបៀនផ្លូវភេទ នៅក្នុងចំណោមស្ត្រី និងកុមារីដែលងាយរងគ្រោះ ជាពិសេសកម្មកររោងចក្រ ថ្លែងក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នាព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ នៅទីស្តីការក្រសួងកិច្ចការនារី ។

លោកជំទាវ រដ្ឋលេខាធិការ បានបញ្ជាក់ថា ការធ្វើបរិវត្តកម្មឌីជីថល ដើម្បីទប់ស្កាត់និងឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី និងគោរពតាមគោលការណ៍សិទ្ធិនិងតម្រូវការរបស់ជនរងគ្រោះ គឺជានវានុវត្តមួយដែលក្រសួងកិច្ចការនារី និងអង្គការដៃគូ បាន និងកំពុងអនុវត្ត ជាពិសេសក្នុងបរិបទការរីករាលដាលនៃជំងឺកូវីដ-១៩ ។

លោកជំទាវ បានបញ្ជាក់បន្តទៀតថា ក្រសួងកិច្ចការនារី ក្រោមជំនួយបច្ចេកទេសរបស់អង្គការ UNFPA ក៏កំពុងសិក្សាការអភិវឌ្ឍកម្មវិធីលើទូរស័ព្ទវៃឆ្លាតដែលមាន ឈ្មោះថា GBV

Safe App ដែលកម្មវិធីនេះ នឹងកាន់តែផ្ដល់ភាពងាយស្រួលជាងមុនក្នុងការផ្ដល់ព័ត៌មានអំពីសេវាដល់ជនរងគ្រោះដោយអំពើហិង្សាងាយស្រួលក្នុងការរាយការណ៍និងបញ្ជូនករណីមានអំពើហិង្សានិងផ្ដល់កិច្ចអន្តរាគមន៍បានទាន់ពេលវេលា និងផ្ដល់ប្រឹក្សាតាមប្រព័ន្ធអនឡាញ ធានាបាននូវឯកជនភាព និងការរក្សាការសម្ងាត់របស់ជនរងគ្រោះ ។ « កម្មវិធី Mobile Application GBV Safe App មានគោលដៅចូលរួម ដើម្បីទប់ស្កាត់ GBV ដែលអាចនឹងកើតឡើង រួមទាំងការ បៀតបៀនផ្លូវភេទនៅក្នុងចំណោមស្ត្រី និងកុមារីដែលងាយរងគ្រោះ ជាពិសេសកម្មកររោងចក្រ តាមរយៈយន្តការសម្របសម្រួល និងគាំទ្រដល់ជនរងគ្រោះ និងការ សាកល្បងបឋមជាមួយនិស្សិត និងអ្នកផ្ដល់សេវានានា »។





សូមបញ្ជាក់ផងដែរថា គម្រោង GBV Safe App នេះមានរយៈ ពេល៣ឆ្នាំ គឺចាប់ពីឆ្នាំ ២០២២-២០២៤។ គម្រោងនេះបានរំពឹងទុកដែលនឹងផ្ដល់នូវព័ត៌មានសំខាន់ៗក្នុងការលើកកម្ពស់ការយល់ដឹងពីអំពើហិង្សា និងការបៀតបៀនផ្លូវភេទដែលកើតមានឡើងនៅក្នុងក្រុមគោលដៅ និងបណ្ដាញសុវត្ថិភាព Hotline/Helpline។ បន្ថែមពីនោះទៀត ការតភ្ជាប់បណ្ដាញទំនាក់ទំនងសម្រាប់ការបញ្ជូនជនរងគ្រោះទៅកាន់សេវាផ្សេងៗដែលសមស្រប និងកំពុងដំណើរការនាពេលបច្ចុប្បន្ន។ នៅក្នុងគម្រោងនេះ ក៏នឹងបង្កើតមុខងារថ្មីមួយដែលហៅថា GBV Chatbot ដែលតភ្ជាប់ទៅនឹងទម្រង់ផ្សេងៗ នៃបណ្ដាញទំនាក់ទំនងរវាងអ្នកទទួលសេវាតាមរយៈប្រព័ន្ធអនឡាញជាមួយអ្នកផ្ដល់សេវារួមមានដូចជា GBV Safe App និងប្រអប់សារនៅក្នុង Facebook page របស់ MOWA ជាដើម៕



តំណាងក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធ
អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ នៅទីស្ដីការក្រសួងកិច្ចការនារី

# យុទ្ធនាការអន្ទាក់សូន្យដើម្បីអភិរក្សសត្វព្រៃឱ្យនៅគង់វង្ស ក្នុងព្រៃធម្មជាតិកម្ពុជា

*អត្ថបទ ៖ អ៊ុន រិទ្ធី , រូបថត ៖ គង់ សិរីរ័ត្ន*

រួមគ្នាបញ្ចប់វិបត្តិអន្ទាក់ និងការជួញដូរសត្វព្រៃគ្រប់ប្រភេទក្នុងព្រៃធម្មជាតិនៃប្រទេសកម្ពុជា គឺជាកម្មវត្ថុដែលក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តរតនគិរី រដ្ឋបាលខេត្តរតនគិរី អង្គការជីវិតធម្មជាតិនៅកម្ពុជា (BirdLife in Cambodia),អង្គការអភិរក្សអន្តរជាតិ (CI), អង្គការ FFI,អង្គការ WWF,អង្គការ WEA,អង្គការ ACCB និងអង្គការសន្សំម្លប់ព្រៃបានរៀបចំយុទ្ធនាការអន្ទាក់សូន្យនៅខេត្តរតនគិរី កាលពីថ្ងៃទី០៤ ខែកញ្ញា២០២២ ដើម្បីបញ្ឈប់វិបត្តិអន្ទាក់ និងការបរបាញ់សត្វព្រៃគ្រប់ប្រភេទ ក្នុងព្រៃធម្មជាតិកម្ពុជាសំដៅអភិរក្សសត្វព្រៃកម្ពុជាឱ្យនៅគង់វង្ស និងមានចំនួនសម្បូរឡើងវិញ ។



ឯកឧត្តម នេត្រ ភក្ត្រា

ខេត្តរតនគិរី ជាខេត្តទី៦ ចុងក្រោយគេ បានរៀបចំយុទ្ធនាការអន្ទាក់សូន្យនេះ មុននឹងឈានបិទបញ្ចប់យុទ្ធនាការនៅរាជធានីភ្នំពេញក្នុងខែតុលា ឆ្នាំ២០២២ ។ ស្ថិតនៅភូមិភាគឦសាន្ត ខេត្តរតនគិរីមានសម្បត្តិធនធានធម្មជាតិ និងសត្វព្រៃដ៏សម្បូរបែប ក៏ប៉ុន្តែនាទសវត្សរ៍ចុងក្រោយនេះការបរបាញ់ ការដាក់អន្ទាក់ និងការបំពុលសត្វព្រៃ បង្កើតជាកត្តាប្រឈមដ៏សំខាន់ធ្វើឱ្យចំនួនសត្វព្រៃមានការថយចុះជាលំដាប់ អាចប្រឈមនឹងការបាត់ពូជសត្វព្រៃមួយចំនួន។ ការបរិភោគសាច់សត្វព្រៃជាកត្តាជំរុញ




រួមគ្នាបញ្ចប់វិបត្តអន្ទាក់ និងការជួញដូរសត្វព្រៃនៅកម្ពុជា



ឯកឧត្តម ញ៉ែម សំអឿន



លោក ប៊ូ វរសក្ស




សិស្សានុសិស្សនៃខេត្តរតនគិរីចូលរួមយុទ្ធនាការអន្ទាក់សូន្យ

ធ្វើឱ្យមានការដាក់អន្ទាក់ និងការជួញដូរសត្វព្រៃ។ យុទ្ធនាការអន្ទាក់សូន្យនាថ្ងៃនេះ ប្រារព្ធធ្វើនៅចំថ្ងៃដែលពិភពលោករៀបចំទិវា «យល់ដឹងពីសត្វត្មាតអន្តរជាតិ»។ តាមរយៈលទ្ធផលជំរឿនសត្វត្មាតចុងក្រោយនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ របស់ក្រុមការងារអភិរក្សសត្វត្មាតកម្ពុជាបានកត់ត្រាសត្វត្មាតជិតផុតពូជចំនួន ១៣៤ក្បាល ក្នុងនោះមានវត្តមានសត្វត្មាតភ្លើងចំនួន១៩ក្បាល ត្មាតត្នោតចំនួន៤៤ក្បាល និងត្មាតផេះមានចំនួន ៧១ក្បាល។ ខេត្តរតនគិរី ជាខេត្តសំខាន់មួយដែលមានទីជម្រកធម្មជាតិ ជួយគាំទ្រដល់ការរស់នៅរបស់សត្វត្មាតជិតផុតពូជរបស់កម្ពុជាយើង ប៉ុន្តែក្រុមការងារអភិរក្សសត្វត្មាតមានការព្រួយបារម្ភលើសម្ពាធនៃការបរបាញ់ ការដាក់អន្ទាក់និងការបំពុលដែលបន្តកើតឡើង កត្តានេះនឹងធ្វើឱ្យចំនួនសត្វត្មាតដែលមានវត្តមាននៅក្នុងខេត្តរតនគិរី នឹងបន្តធ្លាក់ចុះរហូតដល់អាចគ្មានវត្តមានរបស់ពួកវានៅពេលអនាគត ។

ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានដឹកនាំយុទ្ធនាការអន្ទាក់សូន្យបានមានប្រសាសន៍ថា៖ «យុទ្ធនាការអន្ទាក់សូន្យ គឺជាកិច្ចខិតខំប្រឹងប្រែងរួមរវាងក្រសួងបរិស្ថាន អាជ្ញាធរពាក់ព័ន្ធ អង្គការដៃគូក្នុងការងារអភិរក្ស និងដៃគូអភិវឌ្ឍន៍ដើម្បីលុបបំបាត់អន្ទាក់គ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិផ្តល់ជម្រកប្រកបដោយសុខ សុវត្ថិភាពសម្រាប់សត្វព្រៃនិងជីវៈចម្រុះ អនុញ្ញាតឱ្យជីវៈចម្រុះអាចរីកលូតលាស់តាមធម្មជាតិដោយគ្មានការគំរាមកំហែងនិងធ្វើឱ្យប្រព័ន្ធអេកូឡូស៊ី



មន្ត្រីនៃក្រសួងបរិស្ថានចូលរួមក្នុងយុទ្ធនាការអន្ទាក់សូន្យនៅកម្ពុជា

កាន់តែមាននិរន្តរភាព។សត្វព្រៃបានដើរតួនាទីសំខាន់ក្នុងការធានានិរន្តរភាពប្រព័ន្ធអេកូឡូស៊ីហើយការបាត់បង់សត្វព្រៃនិងជីវៈចម្រុះនឹងធ្វើឱ្យប៉ះពាល់ដល់លំនឹងប្រព័ន្ធអេកូឡូស៊ីលើសពីនេះ សត្វព្រៃជាសក្តានុពលយ៉ាងសំខាន់ក្នុងការជំរុញទេសចរណ៍ធម្មជាតិ ដែលជាយន្តការក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានបង្កើតមុខរបរ និងបង្កើតចំណូលជូនប្រជាពលរដ្ឋ។យើងទាំងអស់គ្នានឹងខិតខំប្រឹងប្រែងបន្តទៀត ដើម្បីបញ្ចប់វិបត្តិអន្ទាក់ និងស្នើសុំអ្នកនិយមហូបសាច់សត្វព្រៃបញ្ឈប់ការហូបសាច់សត្វព្រៃនិងចូលរួមការពារអភិរក្សសត្វព្រៃ» ។

ឯកឧត្តម **ញ៉ែម សំអឿន** អភិបាល នៃគណៈអភិបាលខេត្តរតនគិរីបានមានប្រសាសន៍គាំទ្រយ៉ាងពេញទំហឹងចំពោះយុទ្ធនាការអន្ទាក់សូន្យ ផ្តួចផ្តើមដោយក្រសួងបរិស្ថាននិងអង្គការដៃគូនានា។ឯកឧត្តមក៏បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋសូមមេត្តាកុំចូលព្រៃបរបាញ់សត្វ កុំបរិភោគសាច់សត្វព្រៃជាពិសេសចូលរួមទប់ស្កាត់ការចរាចរណ៍លក់ដូរសាច់សត្វព្រៃដោយខុសច្បាប់ក្នុងមូលដ្ឋានខេត្ត ក្នុងគោលដៅធ្វើយ៉ាងណាចូលរួមអភិរក្សសត្វព្រៃឱ្យនៅគង់វង្ស ។

លោក **សេង ទៀក** នាយកអង្គការ WWF កម្ពុជាលើកឡើងថា ប្រទេសកម្ពុជាបានឈានមុខគេបង្អស់នៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍លើការដោះស្រាយវិបត្តិអន្ទាក់ ជាមូលហេតុចម្បងនាំឱ្យសត្វព្រៃបាត់បង់ពូជ និងមានការថយចុះចំនួនរបស់វាគួរឱ្យព្រួយបារម្ភ។ បញ្ហាអន្ទាក់នេះចាំបាច់ត្រូវដោះស្រាយព្រមគ្នាជាមួយយុទ្ធសាស្រ្តអប់រំផ្សព្វផ្សាយ ការពង្រឹងការអនុវត្តច្បាប់ ការបង្កើនទោសពិន័យ និងការបង្កើតជម្រើសថ្មីសម្រាប់ប្រជាជនមូលដ្ឋាន » ។



ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ចូលរួមក្នុងកម្មវិធីអន្ទាក់សូន្យ

លោក **ប៊ូ ថរសក្យ** នាយកអង្គការជីវិតធម្មជាតិនៅ



អន្ទាក់គឺជាការគំរាមកំហែងដល់សត្វព្រៃក្នុងប្រទេសកម្ពុជា

កម្ពុជាបានថ្លែងថា៖ «យើងបានគាំទ្រដល់ដែនជម្រកសត្វព្រៃលំផាត់ចាប់តាំងពីឆ្នាំ២០០៥ ហើយលទ្ធផលនៃការអង្កេតបានបង្ហាញថា ការបរបាញ់មានការកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ក្នុងឆ្នាំ ២០១៦ សត្វខ្ទាតយ៉ាងតិច៥ក្បាលត្រូវស្លាប់ដោយការបំពុលក្នុងដែនជម្រកសត្វព្រៃនេះ។ កំណើនមនុស្សដែលចូលទៅក្នុងតំបន់ការពារធម្មជាតិ ជាកត្តាមួយដែលជំរុញឱ្យការដាក់អន្ទាក់និងការបំពុលកើនឡើង»។ ដើម្បីកាត់បន្ថយសកម្មភាពបរបាញ់យើងកំពុងសហការជាមួយអ្នកពាក់ព័ន្ធ (រួមទាំងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចផងដែរ ) ក្នុងការអប់រំផ្សព្វផ្សាយពីសារៈសំខាន់នៃការអភិរក្សសត្វព្រៃ និងគាំទ្រដល់ឧទ្យានុរក្ស សហគមន៍ល្បាតអនុវត្តច្បាប់ ព្រមទាំងប្រមូលអន្ទាក់ពីទីជម្រកសំខាន់ៗ ។

លោកបណ្ឌិត Jackson Frechette នាយកកម្មវិធីនៃមហាតំបន់មេគង្គនៃអង្គការអភិរក្សអន្តរជាតិប្រចាំប្រទេសកម្ពុជាបានថ្លែងថា ការដាក់អន្ទាក់ចាប់សត្វព្រៃជាបញ្ហាដ៏ធំមួយនៅទូទាំងប្រទេស ជាពិសេសតំបន់ព្រៃឈើនៅក្នុងខេត្តរតនគិរី។មូលហេតុភាគច្រើននៃការដាក់អន្ទាក់ចាប់សត្វព្រៃនេះ ដើម្បីបំពេញតម្រូវការក្រុមមនុស្ស ដែលស្វែងរកការបរិភោគសាច់សត្វព្រៃតែសកម្មភាពទាំងនេះវាប៉ះពាល់យ៉ាងខ្លាំងទៅលើជីវចម្រុះ ហើយយើងទាំងអស់



ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ មន្ត្រីបរិស្ថាន
ចូលរួមក្នុងពិធីយុទ្ធនាការអន្ទាក់សូន្យ

គ្នានឹងប្រឈមនៅសល់តែព្រៃទទេ (គ្មានសត្វព្រៃ) ប្រសិនបើសកម្មភាពនេះនៅតែបន្ត។ «យើងសង្ឃឹមយ៉ាងមុតមាំថា យុទ្ធនាការមួយនេះនឹងលើកកម្ពស់ការយល់ដឹងទូទាំងប្រទេស ហើយអាចជួយកាត់បន្ថយតម្រូវការនៃការបរិភោគសត្វព្រៃផងដែរ។ ឧទ្យានជាតិវីរៀនសៃ-សៀមប៉ាង មានសត្វទោចថ្ពាល់លឿងខាងជើងប្រហែល៣៨៩ក្រុម(ប្រហែលចំនួន១៥៥៦ក្បាល)។តាមរយៈការតាមដាននៅតំបន់គោលដៅបង្ហាញថា ឧទ្យានជាតិវីរៀនសៃ-សៀមប៉ាង ឧទ្យានជាតិវីរៈជ័យ និងដែនជម្រកសត្វព្រៃសៀមប៉ាងចំនួនសត្វទោចថ្ពាល់លឿងមានកម្រិតទាបនៅឡើយ ហើយ

តំបន់ទាំងនេះទំនងជាទីជម្រកដ៏ធំមួយសម្រាប់ប្រភេទសត្វជិតផុតពូជមួយនេះ» ។

លោក Pablo Sinovas នាយកអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ (FFI) ប្រចាំប្រទេសកម្ពុជាបានឱ្យដឹងដែរថា៖ «អន្ទាក់គឺជាការគំរាមកំហែងដ៏ធំបំផុតដល់សត្វព្រៃនៅក្នុងព្រៃរបស់កម្ពុជា ហើយអន្ទាក់ដែលមានតម្លៃថោកងាយស្រួលដាក់ពង្រាយ ពិបាករកនិងមើលមិនឃើញ ហើយអន្ទាក់កំពុងបំផ្លាញតំបន់ការពារធម្មជាតិជាជម្រករបស់សត្វព្រៃ ដែលត្រូវបានកំពុងការពារ។ យើងត្រូវចាត់វិធានការឥឡូវនេះ ដើម្បីកាត់បន្ថយតម្រូវការសាច់សត្វព្រៃ ដែលជំរុញឱ្យមានការដាក់អន្ទាក់ និងពង្រឹងការអនុវត្តច្បាប់» ។

លោក **ទុយ សេរីវឌ្ឍនា** នាយកកម្មវិធីអង្គការសម្ព័ន្ធសត្វព្រៃនិងធម្មជាតិបានលើកឡើងដែរថា៖ « កម្ពុជាត្រូវបានគេស្គាល់ថា ជាប្រទេសសម្បូរទៅដោយជីវៈចម្រុះច្រើន នៅក្នុងចំណោមប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍ ហើយចំពោះជីវៈចម្រុះមួយចំនួននៅក្នុងប្រទេសកម្ពុជាត្រូវទទួលរងការគំរាមកំហែងពីកត្តាផ្សេងៗ។ ក្នុងចំណោមនោមអន្ទាក់ ត្រូវបានគេកំណត់ថាជាការគំរាមកំហែងដ៏ធ្ងន់បំផុតមួយ ចំពោះសត្វព្រៃ ដែលកំពុងដើរតួនាទីជាប្រភេទយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអេកូឡូស៊ី។អង្គការសម្ព័ន្ធសត្វព្រៃនិងធម្មជាតិ សូមគាំទ្រយ៉ាងពេញទំហឹងចំពោះយុទ្ធនាការអន្ទាក់សូន្យ និងអំពាវនាវឱ្យប្រជាជនកម្ពុជាបញ្ឈប់ការបរបាញ់ និងជួញដូរសត្វព្រៃតទៅទៀត»។

លោកស្រី Christel Griffioen លោកនាយកប្រចាំប្រទេសនៃអង្គការ ACCB និងជាសមាជិកស្នូលនៃក្រុមការងារអភិរក្សសត្វត្មាតកម្ពុជាបានចាត់ទុកថា អន្ទាក់ជាឃាតករសម្លាប់សត្វព្រៃមិនរើសមុខ និងធ្វើឱ្យសត្វព្រៃជាច្រើនប្រភេទរងរបួសធ្ងន់ធ្ងរដោយរាប់ចាប់ពីពពួកថនិកសត្វ រហូតដល់សត្វស្លាប។ដរាបណាតម្រូវការជួញដូរសាច់សត្វព្រៃខុសច្បាប់នៅតែបន្តកើតមានការដាក់អន្ទាក់នឹងនៅតែបន្តកើតមាន។ តាមរយៈការពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព រួមជាមួយការអប់រំផ្សព្វផ្សាយ យើងត្រូវកាត់បន្ថយតម្រូវការសាច់សត្វព្រៃ និងការដាក់អន្ទាក់។ លោកស្រីបានបន្ថែមថា៖ «ជារៀងរាល់ឆ្នាំ នៅថ្ងៃសៅរ៍ក្នុងសប្តាហ៍ទី១នៃខែកញ្ញា ពួកយើងប្រារព្ធទិវាយល់ដឹងអំពីសត្វត្មាតអន្តរជាតិ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសត្វត្មាត។ ប្រទេសកម្ពុជាជាជម្រករបស់ សត្វត្មាតដែលកំពុងរងគ្រោះជិតផុតពូជចំនួន៣



ការលុបបំបាត់អន្ទាក់គ្រប់ប្រភេទគឺផ្តល់ជម្រកប្រកបដោយសុខសុវត្ថិភាពសម្រាប់សត្វព្រៃ

ប្រភេទ ហើយចំនួនសត្វត្មាតនៅទូទាំងសកលលោករួមទាំងប្រទេសកម្ពុជាផងកំពុងធ្លាក់ចុះយ៉ាងគំហុក ។ ការមិនទទួលទានសាច់សត្វព្រៃ ជាវិធីមួយដែលអ្នកអាចជួយការពារសត្វត្មាតរបស់ប្រទេសកម្ពុជាយើង» ។

ក្រសួងបរិស្ថាន និងដៃគូទាំងអស់ក៏កំពុងសហការគ្នាដើម្បីស្វែងរកវិធីសាស្ត្រក្នុងការផ្តល់នូវជម្រើសនៃរបរចិញ្ចឹមជីវិតបន្ថែមរាប់បញ្ចូលទាំងរបរក្នុងវិស័យកសិកម្មកសិរុក្ខកម្មនិងទេសចរណ៍ធម្មជាតិ ជូនដល់សហគមន៍មូលដ្ឋានដែលរស់នៅក្បែរតំបន់ការពារធម្មជាតិ ហើយតែងប្រកបរបរប្រពៃណី ដូចជាការប្រមូលអនុផលព្រៃឈើ ការបរបាញ់បែបប្រពៃណីសម្រាប់យកសាច់និងលក់ដូរមួយចំនួនផងដែរនោះ។ កិច្ចសហការនេះ ក៏ផ្តោតលើគោលបំណងកែប្រែឥរិយាបថ និងការនិយមបរិភោគសត្វព្រៃរបស់ប្រជាជនផងដែរ ដើម្បីការពារសុខភាពសាធារណៈពីហានិភ័យនៃប្រភេទជំងឺឆ្លងផ្សេងៗ ជាយថាហេតុនៅថ្ងៃអនាគត ។

លោក **កែវ សុជាតិ** នាយកអង្គការសន្សំម្តប់ព្រៃបានថ្លែងថា៖ «សហគមន៍មូលដ្ឋានអាចចូលរួមជាមួយគម្រោងស្រូវមិត្តភាពសង្គ្រោះសត្វព្រៃ Ibis Rice ដើម្បីលើកកម្ពស់ជីវភាពគ្រួសារ ជាជាងការដាក់អន្ទាក់និងការបរបាញ់សត្វព្រៃ»។ សូមរម្លឹកថា «យុទ្ធនាការអន្ទាក់សូន្យ» បានចាប់ផ្តើមជាផ្លូវការនៅខែមីនា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ ក្រោមការផ្តួចផ្តើមនិងដឹកនាំរបស់ក្រសួងបរិស្ថាន និងដោយមានការគាំទ្រពីដៃគូអភិរក្ស និងដៃគូអភិវឌ្ឍន៍។ យុទ្ធនាការអន្ទាក់សូន្យ ដែលមានរយៈពេល៦ខែ គឺផ្តោតលើខេត្តគោលដៅចំនួន៦ រួមមាន៖ ខេត្តស្ទឹងត្រែង ព្រះវិហារ ក្រចេះ មណ្ឌលគិរី កំពង់ធំ និងខេត្ត រតនគិរី ៕

# កីឡាការិនីជម្រើសជាតិហែលទឹកកម្ពុជា ដណ្តើមបានកិត្តិយស និង កិត្យានុភាពជូនជាតិ តាមរយៈការឈ្នះមេដាយមាស ០៣គ្រឿង និងសំរឹទ្ធ ០១គ្រឿង




អត្ថបទ៖ ស៊ីម មង្គល , រូបថត៖ ឯកសារ

កីឡាការិនី កាំង មុយនីន ដណ្តើមបានមេដាយមាស ០៣គ្រឿង និងសំរឹទ្ធ ០១គ្រឿង

កីឡាការិនីជម្រើសជាតិហែលទឹកកម្ពុជា **កាំង មុយនីន** ដណ្តើមបានកិត្តិយស និងកិត្យានុភាពជូនជាតិតាមរយៈការឈ្នះមេដាយមាស ០៣គ្រឿង និងសំរឹទ្ធ ០១គ្រឿង ពីក្នុងព្រឹត្តិការណ៍ប្រកួត Fin swimming´s World Cup Round Swimming Pool 2022 ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី០២ ដល់ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២២ នាប្រទេសថៃ ដោយមានកីឡាករ កីឡាការិនីមានចំនួន ២៣០នាក់ មកពី ១៦ប្រទេស នៃទ្វីបផ្សេងៗពីគ្នា។ ៤មេដាយ របស់កីឡាការិនី **កាំង មុយនីន** បានធ្វើឱ្យពិភពលោកភ្ញាក់ផ្អើលក្នុងព្រឹត្តិការ Fin swimming´s World Cup Round Swimming Pool 2022។

ប្រភេទកីឡាហែលទឹកពាក់ជើងទា(Fin Swimming) កម្ពុជា ត្រូវបានបង្កើតឡើងថ្មីក្នុងឆ្នាំ២០២២ ហើយបានបង្កើតកំណត់ត្រាជាប្រវត្តិសាស្ត្រថ្មីជូនជាតិ តាមរយៈការឈ្នះមេដាយសំរឹទ្ធ១វិញ្ញាសាកាលពីប្រកួតកីឡាស៊ីហ្គេមលើកទី៣១ នៅ




កីឡាការិនី កាំង មុយនីន ដណ្តើមបានមេដាយមាស០៣គ្រឿង និងសំរឹទ្ធ០១គ្រឿងក្នុងព្រឹត្តិការ Fin swimming´s World Cup Round Swimming Pool 2022

ទីក្រុងហាណូយ ប្រទេសវៀតណាម ក្នុងខែឧសភា ឆ្នាំ២០២២ កន្លងទៅដោយសហព័ន្ធខ្មែរកីឡាហែលទឹកបានចាត់ទុកថា នេះជាជំហានទី១ នៃការចាប់ផ្ដើមដំបូងលើវិញ្ញាសាថ្មីហែលទឹកពាក់ជើងទានេះ។

មេដាយមាស ០៣គ្រឿង និងសំរឹទ្ធ ០១គ្រឿង នេះដណ្ដើមបានដោយកីឡាការិនី **ភាំង មុយនីន** លើប្រភេទកីឡាហែលទឹកពាក់ជើងទា (Fin Swimming) វិញ្ញាសា Bi-fins ១០០ម៉ែត្រ, ២០០ម៉ែត្រ និង៤០០ម៉ែត្រ និងមេដាយសំរឹទ្ធលើវិញ្ញាសា៥០ម៉ែត្រ (ផ្នែក កីឡាការិនីចន្លោះអាយុ១០ឆ្នាំ ដល់ ១៧ឆ្នាំ)។

លោក **ហែម ថុនពន្លឺ** គ្រូបង្វឹកផ្នែកហែលទឹកពាក់ជើងទា នៃក្រុមជម្រើសជាតិហែលទឹកកម្ពុជាបានបញ្ជាក់ឱ្យដឹងថា ក្រុមជម្រើសជាតិកម្ពុជា ដែលចូលរួមប្រកួតក្នុងព្រឹត្តិការណ៍ Fin swimming´s World Cup សរុបចំនួន ០៦នាក់ ក្នុងនោះមានកីឡាករ ០៤នាក់ និងកីឡាការិនី ០២នាក់ ដែលដឹកនាំពីគ្រូបង្វឹកម្នាក់ លោក **ហែម ថុនពន្លឺ** និងប្រតិភូដឹកនាំលោក **ហែម គីរី** ។ ចំពោះសមាសភាពកីឡាករ កីឡាការិនី ០៦នាក់រួមមាន៖ កីឡាការិនី **ភាំង មុយនីន** កីឡាការិនី **ឃីន ប៊ុនពេជ្រមរតក** កីឡាករ **លឹម កែវឧត្ដម** កីឡាករ **ឆោម ច័ន្ទថន** កីឡាករ **ទួន ទិត្យសត្យា** និងកីឡាករ **លឹម សុខវឌ្ឍន៍នន្ទ**។ ព្រឹត្តិការណ៍នេះមានកីឡាករ កីឡាការិនី ១៦ប្រទេសចូលរួមប្រកួតប្រជែងសរុបចំនួន ២៣០នាក់។

ជាលទ្ធផលព្រះរាជាណាចក្រកម្ពុជាឈរនៅចំណាត់ថ្នាក់លេខ៥ ក្នុងចំណោម១៦ប្រទេសចូលរួម ខណៈវៀតណាមឈរលេខ១ ជាមួយនឹងមេដាយមាសលើសលុបជាងគេមាន ២៦គ្រឿង ខណៈលេខ២ ឥណ្ឌូណេស៊ី មេដាយមាស ៥គ្រឿង រីឯម្ចាស់ផ្ទះថៃ ឈរលេខ៣ មេដាយមាស ៤គ្រឿង ជប៉ុនលេខ៤ មេដាយមាស ៤គ្រឿង។ ចំណាត់ថ្នាក់លេខ៥ កម្ពុជាឈរលើ១១ប្រទេសដូចជា៖ ហ្សិកដានី អេហ្ស៊ីប សិង្ហបុរី អេស្តូនី អេក្វាទ័រ កាហ្សាក់ស្ថាន ដោយនៅលេខរៀងពីលេខ៦ ដល់ លេខ១១ ខណៈ៥ប្រទេសមិនដណ្ដើមមេដាយបានសោះរួមមាន គុយវ៉ែត ឥណ្ឌា ប៉េរូ ម៉ុងហ្គោលី និងម៉ាឡេស៊ី។

ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ លោក **ហែម គីរី** ប្រធានប្រតិភូដឹកនាំ និងជាអគ្គលេខាធិការសហព័ន្ធខ្មែរកីឡាហែលទឹកកម្ពុជាបានលើកឡើងថា កាលពីចូលរួមប្រកួតស៊ីហ្គេមឆ្នាំ២០២២ នៅប្រទេស




លោក ហែម គីរី ដឹកនាំកីឡាហែលទឹកកម្ពុជាប្រកួតនៅប្រទេសថៃ

វៀតណាម ហែលទឹកពាក់ជើងទាកម្ពុជា គឺជាជំហានទី១ ដែលជាជំហានចាប់ផ្ដើមដំបូង នៃវិញ្ញាសាថ្មីសម្រាប់កម្ពុជា ដោយឈ្នះមេដាយសំរឹទ្ធ១ វិញ្ញាសារក្រុមហែលបណ្ដាក់៤ដង គុណ ២០០ម៉ែត្រ (Fin Swimming Surface) ដែលដណ្ដើមបានដោយកីឡាករ **លឹម កែវឧត្ដម**, កីឡាករ **ឆោម ច័ន្ទថន** កីឡាករ **ទួន ទិត្យសត្យា** និងកីឡាករ **លឹម សុខវឌ្ឍន៍នន្ទ** ។ ជ័យជម្នះដំបូងនេះបានជំរុញឱ្យកីឡាករ កីឡាការិនី គ្រូបង្វឹក និងថ្នាក់ដឹកនាំសហព័ន្ធខ្មែរកីឡាហែលទឹកទាំងមូលមានកម្លាំងចិត្តកាន់តែខ្លាំងក្លាពុះពារបន្ថែម ដើម្បីស្វែងរកលទ្ធផលថ្មីមួយទៀតជូនជាតិមាតុភូមិ។ លោកអគ្គលេខាធិការបន្តថា ការឈ្នះមេដាយមាស-សំរឹទ្ធក្នុងព្រឹត្តិការណ៍ Fin swimming´s World Cup នៅប្រទេសថៃនាពេលនេះ គឺជាជំហានទី២ ក្រោមការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ (CAMSOC) ក៏ដូចជាក្រសួងអប់រំយុវជន និងកីឡា ដែលជាឱកាសថ្មីរបស់ក្រុមហែលទឹកកម្ពុជាដណ្ដើមមេដាយជូនជាតិពីការប្រកួតដ៏ធំមួយនេះ។ «នេះជាលើកទី១ ដែលកីឡាហែលទឹកកម្ពុជាបានចូលរួមប្រកួតក្នុងព្រឹត្តិការណ៍នេះហើយយើងក៏មិននឹកស្មានថា យើងអាចឈានដល់លទ្ធផលដ៏ល្អបែបនេះដែរ។ ការពិតទៅគោលបំណងចម្បងនៃការចូលរួមប្រកួតនេះ គឺដើម្បីចង់ដឹង និងវាស់ស្ទង់គុណភាពបច្ចេកទេស ដើម្បីត្រៀមឆ្ពោះទៅទទួលរៀបចំធ្វើម្ចាស់ផ្ទះស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣ ដែលជាប្រវត្តិសាស្ត្រដំបូងរបស់កម្ពុជា។ ប៉ុន្តែជាក់ស្ដែងអ្វីដែលលទ្ធផលនៃការខិតខំប្រឹងប្រែងអភិវឌ្ឍន៍ គឺកីឡាការិនី **ភាំង មុយនីន** ធ្វើបានយ៉ាងល្អ ដែលយើងទាំងអស់គ្នាពិតជារំភើបនឹកស្មានមិនដល់»។

សម្រាប់ Fin swimming គឺជាវិញ្ញាសាថ្មីមួយ សម្រាប់



កីឡាការិនី កាំង មុយនីន

បណ្តាប្រទេសនានាក្នុងអាស៊ីអាគ្នេយ៍ ហើយអាស៊ីអាគ្នេយ៍ក៏ទើប នឹងចាប់ផ្តើមមិនច្រើនជាងកម្ពុជាប៉ុន្មានដែរ ដោយអាចប្រហាក់ប្រហែលគ្នាជាមួយនឹងកម្ពុជាដែរ ទើបធ្វើឱ្យកម្ពុជាអាចមានឱកាសដណ្តើមមេដាយដ៏ល្អបែបនេះ។ មួយវិញទៀត លទ្ធផលនេះបានបង្ហាញពីការតាំងចិត្តខ្ពស់ពីថ្នាក់ដឹកនាំសហព័ន្ធ ជាពិសេសឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** ប្រធានសហព័ន្ធខ្មែរកីឡាហែលទឹក ក៏ដូចជាកីឡាករ កីឡាការិនី និងគ្រូបង្វឹកក្នុងឆន្ទៈដ៏មោះមុតនៃការដណ្តើមបានមេដាយជូនជាតិនាពេលនេះ។ «នេះសបញ្ជាក់ឱ្យឃើញថា សហព័ន្ធខ្មែរកីឡាហែលទឹកមិនមែនឈប់នៅមួយកន្លែងនោះទេ ពោលគឺយើងកំពុងពុះពាររាល់ឧបសគ្គទាំងឡាយ ដើម្បីស្វែងរកមេដាយមាស ០៣គ្រឿង និងសំរឹទ្ធ ០១គ្រឿង នាពេលនេះ។ លទ្ធផលថ្មីនេះមិនមែនកើតឡើងដោយឯកឯងនោះទេដោយវាបានកើតចេញពីការខិតខំរួមគ្នា ទើបយើងទទួលបានលទ្ធផលល្អបែបនេះ។ ការឈ្នះមេដាយមាសរបស់កម្ពុជាមិនត្រឹមតែជាការរីករាយរបស់យើងតែម្នាក់ឯងទេ គឺបណ្តាប្រទេសទាំងអស់ដែលចូលរួមបានសម្តែងការកោតសរសើរពីសមត្ថភាពរបស់អត្តពលិកកម្ពុជា»។ ក្រៅពីកីឡាការិនី **កាំង មុយនីន** ដែលឈ្នះមេដាយមាស-សំរិទ្ធ ០៤គ្រឿងនេះ លោកអគ្គលេខាធិការក៏អះអាងឱ្យដឹងបន្ថែមទៀតដែរថា ចំពោះកីឡាករ កីឡាការិនីរបស់កម្ពុជា ០៥នាក់ ផ្សេងទៀតក៏បានបង្ហាញនូវកម្រិតបច្ចេកទេសខ្ពស់ផងដែរ ជាពិសេសកីឡាការិនី **ឃីន ម៉ិនពេជ្រមរកត** ធ្វើបានចំណាត់ថ្នាក់លេខ៤ ជិតនឹងកម្រិតមេដាយសំរឹទ្ធដែរ។ ចំណែកឯកីឡាករកម្ពុជា ដែលចូលរួមប្រកួតចំនួន០៤នាក់ទៀតបានយកឈ្នះប្រទេសជាច្រើនដែរ ដែលស្ថិតនៅក្នុងកម្រិតទី៥ ឬទី១០ ទាំងអស់នេះ គឺជាមោទនភាពរបស់យើងផងដែរ។ អ្វីជាការកត់សម្គាល់បន្ថែម គឺសមិទ្ធផលរបស់កីឡាករ កីឡាការិនីហែលទឹកពាក់ជើងទាកម្ពុជា បានកើនឡើងខ្ពស់បើប្រៀបធៀបទៅនឹងការចូលរួមប្រកួតស៊ីហ្គេមលើកទី៣១ នៅវៀតណាមកន្លងទៅនេះ។ វិញ្ញាសាហែលទឹកជើងទានេះ ដូចគ្នាទៅនឹងវិញ្ញាសាហែលទឹកដែរ ដោយសារគេគិតទៅថេរវេលាដូចគ្នា ដូច្នេះកីឡាករ កីឡាការិនីនាពេលនេះបានបំបែកកំណត់ត្រាចាស់ចន្លោះពី ២ ទៅ ៥វិនាទី។ នៅក្នុងរយៈពេលដែលនៅសល់ប្រមាណ ៨ខែ មុនការទទួលរៀបចំធ្វើម្ចាស់ផ្ទះស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣ សហព័ន្ធនឹងពង្រឹងបន្ថែមលើការត្រៀមខ្លួនឱ្យកាន់តែល្អ ជាពិសេសលើវិញ្ញាសា Fin swimming តែម្តងដោយវាត្រូវការឧបករណ៍សម្ភារៈបន្ថែម។ «យើងប្តេជ្ញាថា នឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាព ដើម្បីដណ្តើមមេដាយក្នុងពេលកម្ពុជាធ្វើម្ចាស់ផ្ទះស៊ីហ្គេមឆ្នាំ២០២៣ ជាមួយក្តីសង្ឃឹមខ្ពស់ថា Fins wimming កម្ពុជានឹងធ្វើបានល្អជាក់ជាមិនខាន។ Fin swimming នេះត្រូវបានចែកជាពីរធំៗទៀតគឺ Surface (ពាក់ជើងទាធំ) និង Bifin (ពាក់ជើងទាពីរដាច់ពីគ្នា)។ ជាគោលដៅចម្បង នៃការត្រៀមខ្លួនឆ្ពោះទៅស៊ីហ្គេម ២០២៣ គឺនឹងបំពេញបន្ថែមលើកង្វះខាតផ្នែកសម្ភារៈហ្វឹកហាត់ និងត្រៀមបញ្ជូនកីឡាករ កីឡាការិនីទៅហ្វឹកហាត់នៅក្រៅប្រទេស» ក្នុងនាមប្រធានប្រតិភូដឹកនាំ លោក **ហែម គីរី** បានសម្តែងការដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ដែលបានផ្ញើសារអបអរសាទរ ក៏ដូចជាថ្នាក់ដឹកនាំសហព័ន្ធខ្មែរកីឡាហែលទឹក ព្រមទាំងប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលផ្តល់ការគាំទ្រលើកទឹកចិត្តដល់ក្រុមហែលទឹកកម្ពុជាក្នុងបេសកកម្មអន្តរជាតិមួយនេះ។ «នេះជាលើកទី១ហើយបន្ទាប់ពីសហព័ន្ធខ្មែរកីឡាហែលទឹកត្រូវបានបង្កើតឡើងវិញតាំងពីឆ្នាំ១៩៨០ដោយកីឡាហែលទឹកកម្ពុជាដណ្តើមបានមេដាយមាសជាប្រវត្តិសាស្ត្រដំបូងជូនជាតិ។ ក្នុង

នាមជាអតីតកីឡាករហែលទឹកម្នាក់ ជាគ្រូម្នាក់រហូតមកដល់ជាអគ្គលេខាធិការសហព័ន្ធនាពេលនេះ គឺជាលើកទី១ ដែលបានស្តាប់ឮភ្លេង គោរពទង់ជាតិខ្មែរ និងទង់ជាតិខ្មែរត្រូវបានគោរពនៅពីលើគេ ដែលជាមោទនភាពជាតិក្រៃលែងណាស់។ យើងធ្លាប់តែអត់បានមេដាយហើយលទ្ធផលល្អបែបនេះធ្វើឱ្យយើងរំភើបរំជួលចិត្តទាំងអស់គ្នា។ ទន្ទឹមនឹងលទ្ធផលល្អបែបនេះ ក៏យើងមិនផ្តោតតែលើ Fin swimming ពោលគឺនឹងប្រឹងប្រែងឱ្យអស់ពីសមត្ថភាពលើផ្នែកហែលទឹក លោតទឹក និងវិញ្ញាសាថ្មីៗ បន្ថែមទៀត ដើម្បីគោលដៅប្រកួតប្រជែងមេដាយជូនជាតិក្នុងឋានៈម្ចាស់ផ្ទះស៊ីហ្គេម ឆ្នាំ២០២៣ និងគោលដៅសំខាន់ៗសម្រាប់ថ្ងៃខាងមុខទៀត។

ជាមួយគ្នានេះម្ចាស់មេដាយមាស-សំរឹទ្ធ០៤គ្រឿងម្នាក់ឯងកីឡាការិនី **ភាំង មុុយនីន** បានបង្ហាញក្តីរំភើបរីករាយជាខ្លាំងដែលដណ្តើមបានមេដាយជូនជាតិពីព្រឹត្តិការណ៍អន្តរជាតិមួយនេះ។ «នៅពេលនាងខ្ញុំហែលដល់ទីហើយឃើញឈ្មោះនាងខ្ញុំនៅលើគេ ជាពិសេសនៅពេលខ្ញុំឡើងទទួលមេដាយជាមួយនឹងការគោរពទង់ជាតិកម្ពុជា គឺខ្ញុំពិតជាសប្បាយរំភើបចិត្តខ្លាំងណាស់។ មុនពេលចេញដំណើរទៅប្រកួត ខ្ញុំធ្លាប់បានគិតថាដោយសារនេះជាការប្រកួតកម្រិតពិភពលោក ក្តីសង្ឃឹម គឺប្រហែលជាអាចបានត្រឹមបំបែកកំណត់ត្រាថិរវេលាខ្លួនឯងប៉ុណ្ណោះ ដោយមិនរំពឹងថាដណ្តើមបានមេដាយអ្វីនោះទេ។ ប៉ុន្តែជាលទ្ធផលនាងខ្ញុំដណ្តើមបានមេដាយមាសរហូតដល់ ៣គ្រឿង និងសំរឹទ្ធ ១គ្រឿង ទៀតវាហួសពីក្តីរំពឹងរបស់នាងខ្ញុំឆ្ងាយណាស់»។

នៅពេលដែលកីឡាការិនីរូបនេះទទួលបានមេដាយមាសទី១ ហើយប្រកួតលើវិញ្ញាសាទី២ និងទី៣ ដែលមានដៃគូប្រកួតដដែលៗ **ភាំង មុុយនីន** ដាក់ក្តីសង្ឃឹមកាន់តែខ្ពស់ថានឹងបន្តការខិតខំដើម្បីឈ្នះមេដាយមាសពីកីឡាការិនីមកពីបណ្តាប្រទេសនានាក្នុងវិញ្ញាសានីមួយៗរបស់ខ្លួន ដែលជំរុញទឹកចិត្តឱ្យ **មុុយនីន** កាន់តែពុះកញ្ជ្រោលបន្ថែមក្នុងការឆ្ពោះទៅរកមេដាយមាសបាន២គ្រឿងបន្ថែម។ កីឡាការិនីក្នុងឈុតយុវជនដែលខ្លាំងៗ ចូលរួមប្រកួតជាមួយ កីឡារិនីម្ចាស់មេដាយមាសកម្ពុជារូបនេះមានដូចជាជប៉ុន សិង្ហបុរី ថៃជាដើម។ កីឡាការិនី **ភាំង មុុយនីន** បានបញ្ជាក់បន្ថែមថា៖ «សម្រាប់ការប្រកួត World Cup នេះ ខ្ញុំប្រកួតនៅក្នុងឈុតយុវជន ប៉ុន្តែខ្ញុំក៏បានសង្កេតមើលថេរវេលាពួកគេដែលអាចមានភាពប្រកៀកប្រកិតគ្នាដែរ ដូច្នេះរយៈពេលនៅសល់ប្រមាណ៨ខែខាងមុខ ដែលកម្ពុជាទទួលធ្វើម្ចាស់ផ្ទះស៊ីហ្គេម ២០២៣ គឺជារយៈពេលសមល្មម ដើម្បីបង្កើនសម្ថភាពរបស់ខ្លួនដណ្តើមមេដាយជូនជាតិបាន»៕


កីឡាការិនី ភាំង មុុយនីន



ក្រុមកីឡាករ កីឡាការិនីកម្ពុជាក្នុងព្រឹត្តិការ Fin swimming's World Cup Round Swimming Pool 2022 នៅប្រទេសថៃ

# ការស្រាវជ្រាវរកឃើញវត្តមានសត្វក្តាន់ក្នុងខេត្តក្រចេះដែលនឹងធ្វើឱ្យកិត្តិនាម របស់កម្ពុជាលេចត្រដែតលើឆាកអន្តរជាតិផ្នែកការងារអភិរក្សជីវៈចម្រុះ

*អត្ថបទ ៖ គង់ សិរីរ័ត្ន និង អ៊ុន រិទ្ធី , រូបថត ៖ ក្រសួងបរិស្ថាន*



អាសង្គា (ក្តាន់)បង្ហាញរាងក្នុងដែនជម្រកសត្វព្រៃព្រែកប្រសព្វនៃតំបន់ទេសភាពព្រៃលិចទឹកមេគង្គក្នុងខេត្តក្រចេះ





ក្រុមមន្ត្រីបរិស្ថាននិងប្រតិភូសារព័ត៌មានចុះទៅពិនិត្យដែនជម្រកសត្វព្រៃ

អ្នកវិទ្យាសាស្ត្រធ្លាប់បានសន្និដ្ឋានថា សត្វក្តាន់បានផុតពូជទៅហើយពីប្រទេសកម្ពុជា តែរហូតដល់ឆ្នាំ២០០៦ ទើបវាត្រូវបានគេរកឃើញមានវត្តមានឡើងវិញក្នុងខេត្តក្រចេះ តាមរយៈរូបភាពថតដោយម៉ាស៊ីនថតស្វ័យប្រវត្តិ។របាយការណ៍ស្រាវជ្រាវឆ្នាំ២០២២ ស្តីពីស្ថានភាព និងរបាយសត្វក្តាន់ក្នុងដែនជម្រកសត្វព្រៃព្រែកប្រសព្វនៃតំបន់ទេសភាពព្រៃលិចទឹកមេគង្គក្នុងខេត្តក្រចេះ ត្រូវបានផ្សព្វផ្សាយ កាលពីថ្ងៃទី១៦ខែមិថុនាឆ្នាំ២០២២ក្រោមវត្តមាន ឯកឧត្តម **នេត្រ ភក្ត្រា**រដ្ឋលេខាធិការក្រសួងបរិស្ថាន បានបង្ហាញថា មានសត្វក្តាន់ សរុបចំនួនប្រមាណ ៨៤ក្បាល។ លទ្ធផលនៃការស្រាវជ្រាវនេះក៏បានបង្ហាញផងដែរពីវត្តមាននៃសត្វក្តាន់វ័យជំទង់ និងកូនជាច្រើន ដែលជាសញ្ញាណវិជ្ជមានបង្ហាញពីការបន្តពូជរបស់សត្វដ៏កម្រប្រភេទនេះនៅក្នុងតំបន់ទីជម្រកធម្មជាតិ ។

លោក **អៀម សំអ៊ន់** ប្រធានផ្នែកស្រាវជ្រាវ និងតាមដាន








សត្វក្ដាន់ដ៏កម្រដែលត្រូវបានថតតាមរយៈម៉ាស៊ីនកាមេរ៉ាស្វ័យប្រវត្តិនៅក្នុងដែនជម្រកសត្វព្រៃ

ជីវៈចម្រុះនៃតំបន់ទេសភាពមេគង្គនៃអង្គការ WWFបានរៀបរាប់ថា«អស់រយៈកាល១៦ឆ្នាំហើយបន្ទាប់ពីការរកឃើញវត្តមានសត្វក្ដាន់ឡើងវិញ នេះជាការចងក្រងរបាយការណ៍ស្ដីពីចំនួនសត្វក្ដាន់នៅកម្ពុជាលើកដំបូងសម្រាប់ការអភិរក្សសត្វដ៏កម្រនៅលើពិភពលោកមួយប្រភេទនេះ»។ លោកបានបន្តថា សត្វក្ដាន់ជាប្រភេទសត្វពិបាកប្រទះឃើញ និងអង្កេតផ្ទាល់ដូចប្រភេទសត្វក្រចកជើងចំពាមដទៃទៀតណាស់។ ការសិក្សាស្ថានភាព និងរបាយសត្វប្រភេទនេះបានធ្វើឡើងដោយការពង្រាយម៉ាស៊ីនថតស្វ័យប្រវត្តិក្នុងតំបន់ដែលវារស់នៅ។ ការស្រាវជ្រាវនេះ បានសហការរៀបចំដោយក្រុមជំនាញសត្វព្រៃមកពីមន្ទីរបរិស្ថានខេត្តក្រចេះនៃក្រសួងបរិស្ថាន អង្គការ WWF អង្គការBINCO និងមានការចូលរួមពីសំណាក់សមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋានផងដែរ។

ក្នុងពិធីផ្សព្វផ្សាយ របាយការណ៍ស្រាវជ្រាវដែលមានអ្នកសារព័ត៌មានជាច្រើនស្ថាប័នចូលរួមផងនោះ ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងបរិស្ថានបានមានប្រសាសន៍ថា «ក្រសួងបរិស្ថាន មានសេចក្ដីត្រេកអរ និងមានមោទនភាពជាខ្លាំងដែលធម្មជាតិនៃប្រទេសកម្ពុជាផ្ដល់ទីជម្រកសុខសាន្តសម្រាប់ការរស់រានរបស់ប្រភេទសត្វសំខាន់ៗជាសកល ដូចជាសត្វក្ដាន់ដែលត្រូវបានអ្នកវិទ្យាសាស្ត្របញ្ជាក់ពីវត្តមាន និងការបន្តពូជរបស់វានៅក្នុងដែនជម្រកសត្វព្រៃព្រែកប្រសព្វ។ ឯកឧត្តមបានលើកឡើងថា ដោយសារកម្ពុជាមានសន្តិភាពពេញលេញ និងស្ថិរភាពនយោបាយល្អប្រសើរ វាបានផ្ដល់ឱកាសពេញលេញដល់ក្រសួងបរិស្ថាន សហគមន៍អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូនានា ដើម្បីគ្រប់គ្រង និងអភិរក្សធនធានជីវៈចម្រុះក្នុងតំបន់នេះដែលក្នុងនោះធនធានធម្មជាតិត្រូវបានការពារ រីឯប្រភេទសត្វមួយចំនួនបានកើនឡើង។ ឯកឧត្តមបានថ្លែងថា «យើង ចាំបាច់ត្រូវបន្តពង្រឹងកិច្ចសហការរួមគ្នា






ឯកឧត្តម នេត្រ ភក្ត្រា និងតំណាងអង្គការការពារសត្វព្រៃធ្វើពិធីផ្សព្វផ្សាយរបាយការណ៍នៃការរកឃើញសត្វក្ដាន់ក្នុងដែនជម្រកសត្វព្រៃ




បន្ថែមទៀតក្នុងការពារ និងអភិរក្សជីវៈចម្រុះដែលមាននៅក្នុងតំបន់ការពារធម្មជាតិរបស់យើងដើម្បីជាប្រយោជន៍ដល់ការជំរុញសេដ្ឋកិច្ចមូលដ្ឋានឱ្យប្រសើរឡើង ជាពិសេសតាមរយៈវិស័យទេសចរណ៍ធម្មជាតិ ក៏ដូចជាប្រយោជន៍ដល់ប្រព័ន្ធអេកូឡូស៊ីសម្រាប់កម្ពុជា និងសកលលោក»។

ឯកឧត្តមបានថ្លែងបន្តថា ក្រសួងបរិស្ថាន រួមជាមួយនឹងអង្គការ WWF បាននិងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការការពារ និងអភិរក្សសត្វក្ដាន់ដ៏កម្រនេះតាមរយៈការបង្កើនជីវភាពសហគមន៍មូលដ្ឋានការអប់រំផ្សព្វផ្សាយ និងការពង្រឹងការអនុវត្តច្បាប់ ដើម្បីទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃ រាល់ការបរបាញ់ និងការដាក់អន្ទាក់គ្រប់ប្រភេទក្នុងតំបន់ការពារធ្វើយ៉ាងណាធានាការរស់រានរបស់សត្វក្ដាន់ និងសត្វព្រៃដ៏មានតម្លៃជាសកលដទៃទៀតនៅក្នុងទីជម្រកធម្មជាតិរបស់ពួកវា។ឯកឧត្តមបានបន្ថែមថា ក្រៅពីមានវត្តមាននៅក្នុងប្រទេសកម្ពុជា សត្វក្ដាន់នេះក៏មានរស់នៅផងដែរក្នុងប្រទេសឥណ្ឌា នេបាល់ ប៊ូតាន់ បង់ក្លាដែស មីយ៉ាន់ម៉ា និងថៃ ហើយអ្នកវិទ្យាសាស្ត្រជឿថា សត្វក្ដាន់ប្រហែលបានផុតពូជបាត់ទៅហើយពីប្រទេសចិនឡាវនិងវៀតណាម ។

លោកស្រី **អេង សុខន** សមាជិកសហគមន៍ល្បាតស្ម័គ្រចិត្តនៅសហគមន៍ជ្រោយបន្ទាយនៃដែនជម្រកសត្វព្រៃព្រែកប្រសព្វបានរៀបរាប់ថា លោកស្រីមានមោទនភាពដែលសត្វកម្រដូចសត្វក្ដាន់នៅតែមានក្នុងព្រៃធម្មជាតិក្នុងខេត្តក្រចេះហើយលោកស្រីបាន និងកំពុង ចូលរួមក្នុងការល្បាតព្រៃ និងដោះអន្ទាក់ក្នុងដែនជម្រកសត្វព្រៃព្រែកប្រសព្វ។ លោកស្រីថា "ខ្ញុំក៏ដូចជាសមាជិកក្រុមល្បាតដទៃទៀតដែរ មានចិត្តមោះមុតក្នុងចូលរួមការពារសត្វព្រៃ ចុះល្បាត ដោះអន្ទាក់ចេញពីព្រៃទីជម្រក ការពារព្រៃសម្រាប់ឱ្យសត្វជ្រកកោន ធ្វើយ៉ាងណាថែរក្សាសត្វព្រៃនិងធនធានធម្មជាតិ សម្រាប់កូនចៅជំនាន់តទៅមុខទៀត»។

សត្វក្ដាន់ ត្រូវបានចាត់ថ្នាក់ក្នុងបញ្ជីក្រហមរបស់អង្គការ IUCN ជាប្រភេទសត្វកំពុងរងគ្រោះថ្នាក់ជិតផុតពូជជាសកល។ ការរស់រានរបស់សត្វក្ដាន់ ត្រូវបានគំរាមកំហែងដោយការបាត់បង់ទីជម្រក ការបរបាញ់ខុសច្បាប់ និងវិបត្តិអន្ទាក់ដែលបណ្ដាលមកពីការជួញដូរសត្វព្រៃខុសច្បាប់ ។

លោក **សេង ទៀក** នាយកអង្គការ WWF បានគូសបញ្ជាក់ថា លទ្ធផលស្រាវជ្រាវនា ពេលនេះមិនត្រឹមតែបានធ្វើឱ្យកិត្តិនាមរបស់កម្ពុជាលេចត្រដែតលើឆាកអន្តរជាតិប៉ុណ្ណោះទេ វាថែមទាំងបានបង្ហាញពីសារៈសំខាន់ជាសកលនៃតំបន់ទេសភាពមេគង្គជាទីជម្រកដ៏សំខាន់សម្រាប់ការរស់រានរបស់សត្វព្រៃទាំង





ឯកឧត្តម នេត្រ ភក្ត្រា និងក្រុមឧទ្យាននុរក្សរួមជាមួយប្រតិភូសារព័ត៌មានចុះពិនិត្យការប្រមូលអន្ទាក់នៅក្នុងដែនជម្រកសត្វព្រៃ

លើគោក និងក្នុងទឹកគ្រប់ប្រភេទ។ លោកបានបន្ថែមថា «អង្គការ WWF សូមកោតសរសើរ និងសូមអរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមស្រាវជ្រាវ និងការពង្រឹងការអនុវត្តច្បាប់របស់មន្ត្រីឧទ្យានុរក្សដោយមានការចូលរួមយ៉ាងសកម្មពី អាជ្ញាធរ និងសហគមន៍មូលដ្ឋានដើម្បីការពារតំបន់សត្វព្រៃទាំងនេះសម្រាប់ជាប្រយោជន៍របស់ធម្មជាតិ និងមនុស្សគ្រប់ជំនាន់»។ លោកបានអះអាងថា វិធានការអភិរក្សរួមគ្នាបន្ទាន់បន្ថែមគឺចាំបាច់ណាស់ ដើម្បីធានាថា ទីជម្រកចុងក្រោយរបស់សត្វក្ដាន់ដ៏កម្រនេះគ្មានការគំរាមកំហែងដោយសកម្មភាពខុសច្បាប់ ពោលគឺគ្មានការដាក់អន្ទាក់ គ្មានការបរបាញ់ និងការជួញដូរសត្វព្រៃក្នុងតំបន់ ។

លោក**សេខ ឡៀក** បានបន្ថែមដែរថា ការស្ដារចំនួននិងទីជម្រកសត្វក្ដាន់ ព្រមទាំងការបន្តពង្រឹងជម្រើសជីវភាពរបស់សហគមន៍ក្នុងតំបន់ គឺជាវិធានចាំបាច់ផងដែរដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួមរៀបចំ និងអនុវត្តន៍។

ឯកឧត្តម **នេត្រ ភក្ត្រា** បានមានប្រសាសន៍ឱ្យដឹងថា "ក្រសួងបរិស្ថានសូមលើកទឹកចិត្តដល់ប្រជាពលរដ្ឋរស់នៅជុំវិញតំបន់ការពារធម្មជាតិចូលរួមអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះដោយបោះបង់ចោលការបរបាញ់ និងដាក់អន្ទាក់បញ្ឈប់ការទិញការបរិភោគសាច់សត្វព្រៃ ដើម្បីចូលរួមថែរក្សា និងអភិរក្សប្រភេទសត្វកម្រដូចជាសត្វក្ដាន់នេះសម្រាប់ជាប្រយោជន៍មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀតទៅអនាគតយូរអង្វែង និងសម្រាប់ពង្រឹងការអភិវឌ្ឍជីវភាពរបស់សហគមន៍មូលដ្ឋាន»។ ជាមួយគ្នានេះដែរ ក្រុមអ្នកជំនាញស្រាវជ្រាវនឹងបន្តពង្រឹងទិន្នន័យវិទ្យាសាស្ត្រស្ដីពីរបាយសត្វក្ដាន់ឱ្យកាន់តែសុក្រឹតថែមទៀតដោយ



ប្រើប្រាស់បច្ចេកវិទ្យាទំនើបរួមជាមួយម៉ាស៊ីនថតប្រើកំដៅនៅទូទាំងដែនជម្រកទាំងមូល។ ដែនជម្រកសត្វព្រៃព្រែកប្រសព្វដែលជាទីជម្រកធម្មជាតិរបស់សត្វក្ដាន់នេះស្ថិតក្រោមការសហការពារយ៉ាងតឹងរ៉ឹងដោយមន្ត្រីឧទ្យានុរក្សនៃក្រសួងបរិស្ថានគាំទ្រដោយអង្គការ WWF និងចូលរួមដោយក្រុមល្បាតសហគមន៍។

ឯកឧត្តម **នេត្រ ភក្ត្រា** បានលើកឡើងទៀតថា "បច្ចុប្បន្នក្រសួងបរិស្ថាន និងដៃគូនានាកំពុងរៀបចំយុទ្ធនាការអន្ទាក់សូន្យដើម្បីជួយសង្គ្រោះសត្វក្ដាន់ និងសត្វព្រៃសំខាន់ៗជាសកលជាច្រើនប្រភេទទៀតក្នុងប្រទេសកម្ពុជាពីការបរបាញ់និងការដាក់អន្ទាក់ ដោយមានគោលដៅលុបបំបាត់ការដាក់អន្ទាក់គ្រប់ប្រភេទ និងបញ្ចប់ការជួញដូរសត្វព្រៃខុសច្បាប់។ យើងសូមថ្លែងអំណរគុណចំពោះការផ្ដល់មូលនិធិ និងការគាំទ្រពី WWF បែលហ្សិក រដ្ឋាភិបាលប្រទេសបែលហ្សិក (DGD) មូលនិធិភាពជាដៃគូប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (CEPF) ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចប្រតិបត្តិការ(SDC) និង Binco" ៕

# គោរពជូនពរ និងអបអរសាទរ
# ជូនចំពោះ
# ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន



## នៅក្នុងឱកាសដ៏នក្ខត្តឫក្ស ចម្រើនជន្មាយុ គម្រប់ខួប៧០ឆ្នាំ ឈានចូល៧១ឆ្នាំ

សូម **ឯកឧត្តម** ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ
អាយុយឺនយូរ និងទទួលបានជោគជ័យធំធេងថ្មីៗបន្ថែមទៀត ដើម្បីជាមគ្គុទេសក៍ ដឹកនាំ
និងអភិវឌ្ឍន៍ជាតិ ជាពិសេសវិស័យព័ត៌មាន ឱ្យមានការរីកចម្រើនជឿនលឿនទៅមុខជានិច្ចនិរន្តរ៍ ។

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធ និងទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា
បីបាច់ថែរក្សា **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំង**ក្រុមគ្រួសារ**
ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការ គឺ
អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**គោរពជូនពរពី**

**ឯកឧត្តម លី វ៉ាន់ហុង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក**
**នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៥៧៨.អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១.-** តែងតាំងលោក **ទ្រឹម ឆេងលីម** ជាប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសលោក **អ៊ុន សម័យ** ដែលត្រូវចូលនិវត្តន៍។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# គោរពជូនពរ និងអបអរសាទរ
# ជូនចំពោះ
# ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន



## ក្នុងឱកាសខួបកំណើតគម្រប់ ៧០ឆ្នាំ ឈានចូល ៧១ឆ្នាំ

សូម **ឯកឧត្តម** ទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ ដើម្បីបន្តរួមចំណែកអភិវឌ្ឍន៍មាតុភូមិកម្ពុជា ឱ្យកាន់តែរីកចម្រើន ជឿនលឿនទៅមុខជានិច្ចនិរន្តរ៍ ជាពិសេសលើវិស័យសារព័ត៌មាននៅកម្ពុជា ។

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធ និងទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា បីបាច់ថែរក្សា **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំង**ក្រុមគ្រួសារ** ប្រកបដោយព្រះពុទ្ធពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**គោរពជូនពរពី**

**ថ្នាក់ដឹកនាំ និងក្រុមការងារទស្សនាវដ្ដីកម្ពុជា KAMBUJA**

**នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP ក្រសួងព័ត៌មាន**

# ONLINE
IN TOUCH WITH YOUR WORLD

## អ្នកផ្ដល់សេវាអ៊ីនធឺណិតឈានមុខគេនៅកម្ពុជា

## THE LEADING INTERNET SERVICE PROVIDER IN CAMBODIA




### BROADBAND INTERNET

ONLINE provides many packages of internet service suitable to the actual needs of the public sectors and private sectors,such as Ministries, NGOs, Banks, MFI Factories, Hotels, Casinos, etc.

### CONNECTIVITY

ONLINE provides a flexibility to transport and route several types of network traffic using latest technology and highly efficient transmit applications such as voice, data and video, etc.

### HOSTING / COLOCATION SERVICES

ONLINE provides a flexibility hosting services to customers by adapting to user's requirements which user can host their crucial date and high security. Our colocation service is fully completed and facilitated.

COGETEL Ltd.

023 / 081 72 72 72 | sales@online.com.kh | www.online.com.kh | /onlineisp



ឯកឧត្តម ខៀវ កាញារីទ្ធ និងលោកជំទាវ រួមនឹងថ្នាក់ដឹកនាំក្រសួងព័ត៌មាន
អញ្ជើញចូលរួមពិធីកាន់បិណ្ឌវេនទី៧ នៅវត្តលង្កាព្រះកុសុមារាម